## រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម
# ២០១៤ - ២០១៨

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

ប្រទេសកម្ពុជាបានឆ្លងកាត់ដំណាក់កាលប្រែប្រួលដ៏ច្រើនសន្ទឹកសន្ធាប់នៅក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងទៅនេះ ។ ប្រទេសយើងបានបញ្ចប់ដោយជោគជ័យនូវដំណាក់កាលអន្តរកាលឆ្លងពីសេដ្ឋកិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារ, ពីរដ្ឋមួយដែលគ្រប់គ្រងដោយគណបក្សតែមួយ មកកាន់ប្រព័ន្ធមួយមានពហុបក្ស និងអភិបាលកិច្ចមួយដែលមានលក្ខណៈប្រជាធិបតេយ្យសេរី, ពីប្រទេសមួយមានសង្គ្រាម និងវិបត្តិនយោបាយ មកជាប្រទេសមួយប្រកបដោយសុខសន្តិភាពពេញលេញ និងប្រកបដោយចីរភាព ។ កម្ពុជាបានបញ្ចប់ជាស្ថាពរនូវទំព័រប្រវត្តិសាស្ត្រខ្មៅងងឹតពីអតីតកាលថ្មីៗរបស់ខ្លួន ហើយបោះជំហានទៅរកអនាគតកាលមួយដ៏ភ្លឺស្វាងត្រចះត្រចង់ ។ យើងបានបិទចោលទាំងស្រុងនូវទំព័រប្រវត្តិសាស្ត្រដ៏ជូរចត់ដែលពោរពេញដោយចលាចល, អំពើហិង្សា, កលិយុគ និងប្រទូស្តរាយ ។ ព្រឹត្តិការណ៍នេះមិនមែនកើតឡើងដោយឯកឯងនោះទេ ។ វាគឺជាលទ្ធផលនៃការគិតគូរទុកជាមុន ដោយដាក់ចេញជាយុទ្ធសាស្ត្រ និងគោលនយោបាយ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រ និងគោលនយោបាយនេះ ។

ស្ថិតក្នុងបរិការណ៍ថ្មីនេះ កម្ពុជាបានកសាងមូលដ្ឋានសេដ្ឋកិច្ចជាតិបានកាន់តែមានលក្ខណៈអំណោយផលដល់ការរីកលូតលាស់ទៅមុខទៀត ។ លើសពីនេះទៀត ក្នុងអំឡុងចុងទសវត្សរ៍ ៩០ ក្រោមនយោបាយ **«ឈ្នះ-ឈ្នះ»** កម្ពុជាមិនត្រឹមតែសម្រេចបានឯកភាពជាតិ, ការធានាបាននូវអធិបតេយ្យជាតិ, បូរណភាពទឹកដី, ស្មារតីមហាសាមគ្គីជាតិ និងសុខសន្តិភាពពេញលេញនៅទូទាំងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ជាមធ្យម **៧,៧%** ក្នុងមួយឆ្នាំ ក្នុងអំឡុង ២ ទសវត្សរ៍កន្លងមក ហើយជីវភាព និងសុខុមាលភាពរបស់ប្រជាជនកាន់តែត្រូវបានលើកកម្ពស់គួរឱ្យកត់សម្គាល់ ក្នុងនោះអត្រានៃភាពក្រីក្រប្រមាណជាង ២% ក្នុងមួយឆ្នាំ ត្រូវបានកាត់បន្ថយ ។ ឈរលើវឌ្ឍនភាពជាបន្តបន្ទាប់នេះ ក្នុងនីតិកាលទី ៥ នេះ រាជរដ្ឋាភិបាលកម្ពុជាកាន់តែមានឆន្ទៈដ៏មោះមុត ក្នុងការបន្តអភិវឌ្ឍប្រទេស ហើយបានដាក់ចេញនូវទស្សនាទាន និងចក្ខុវិស័យរបស់ខ្លួនក្នុងគោលដៅអភិវឌ្ឍកម្ពុជាឱ្យក្លាយទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ ២០៥០ ។

យ៉ាងណាមិញ ចក្ខុវិស័យប្រកបដោយមហិច្ឆតានេះ និងចលនានៃការបន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យប្រកប-ដោយចីរភាពក្នុងបរិការណ៍ថ្មី ទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាត្រូវតែមានលទ្ធភាព និងសមត្ថភាពខ្ពស់ ទាំងធនធានមនុស្ស និងមូលធន ក្នុងការបន្តនូវកិច្ចខិតខំប្រឹងប្រែងលើការងាររបស់ខ្លួន ។ ហេតុនេះ រាជរដ្ឋាភិបាលត្រូវរិះរកមធ្យោបាយ និងយុទ្ធសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីកៀរគរចំណូលឱ្យអស់លទ្ធភាព, អស់សក្តានុពល និងមានភាពស័ក្តិសិទ្ធិក្នុងគោលដៅបង្កើនភាពជាម្ចាស់ក្នុងការងារអភិវឌ្ឍន៍របស់ខ្លួន សម្រាប់ទ្រទ្រង់ និងឆ្លើយតបយ៉ាងសមស្របទៅនឹងកំណើននៃតម្រូវការចំណាយក្នុងគោលដៅសម្រេចឱ្យបាននូវការអភិវឌ្ឍវិស័យអាទិភាពនានា ដូចបានគូសបញ្ជាក់ក្នុង ***«យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣»*** និង ***«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨»*** ជាពិសេសធានាឱ្យបានកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំ ៧% ឱ្យប្រកបដោយចីរភាព, បរិយាប័ន្ន, សមធម៌ និងធន់នឹងវិបត្តិ ។

ឈរនៅលើមូលដ្ឋាននៃការគិតគូរនេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងដាក់ចេញនូវ ***«យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨»*** ដែលជាផ្នែកមួយនៃការបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ។ យុទ្ធសាស្ត្រនេះ ផ្តោតលើគោលការណ៍សំខាន់ចំនួន ៤ គឺ ***(១)*** - ប្រមូលឱ្យអស់លទ្ធភាពនូវសក្តានុពលប្រមូលចំណូលដែលមាននាពេលបច្ចុប្បន្ន, ***(២)*** - មិនបង្កើតប្រភេទពន្ធថ្មី ***(៣)*** - មិនដំឡើងអត្រាពន្ធ និងអាករ លើកលែងតែក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល និងការការពារសុខភាព និង/ ឬ ការការពារបរិស្ថាន និង ***(៤)*** - ធានាឱ្យបាននូវភាពងាយស្រួល សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូល ។ ក្នុងស្មារតីនេះ យើងសង្ឃឹមថា ការប្រមូលចំណូលចរន្តសរុបនឹងកើនបាន ០,៥% នៃផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ និងភាគរយនៃចំណូលចរន្តធៀបនឹងផលិតផលក្នុងស្រុកសរុបកើនពី ១៥,៧% នៅក្នុងឆ្នាំ ២០១៤ ដល់ ១៧,៣៦% ក្នុងឆ្នាំ ២០១៨ និងឈានទៅសម្រេចបាននូវចក្ខុវិស័យដ៏មានមហិច្ឆតារបស់ខ្លួនយ៉ាងប្រាកដ ។

ចំពោះមុខ ខ្ញុំសង្ឃឹម និងជឿជាក់ថា គ្រប់ក្រសួង- ស្ថាប័ន និងអង្គភាពប្រមូលចំណូល ព្រមទាំងតួអង្គដែលពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នឹងចូលរួមគាំទ្រ និងអនុវត្តការងារ ***យុទ្ធសាស្ត្រកៀរគរចំណូល***នេះឱ្យសម្រេចបានជោគជ័យ តាមតួនាទី, ភារកិច្ច និងការទទួលខុសត្រូវដ៏ខ្ជាប់ខ្ជួនរបស់ខ្លួន និងរួមចំណែកអភិវឌ្ឍកម្ពុជាឱ្យមានវឌ្ឍនភាព និងភាពរុងរឿងជានិច្ចនិរន្តរ៍ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៥*

**ហ៊ុន សែន**

# មាតិកា


**១. សេចក្តីផ្តើម**............................................................................................................១
**២. ចក្ខុវិស័យ** ............................................................................................................ ៣
**៣. គោលបំណង និងគោលដៅ**................................................................................... ៣
**៤. អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រ**...........................................................................................៤
**៥. ការពង្រឹងរដ្ឋបាលចំណូល** ...................................................................................................៦
**៥.១ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ** ........................................................... ៦
**៥.១.១ ការពង្រឹងមុខងារប្រតិបត្តិការស្នូល**........................................................................................៨
៥.១.១.១ ការចុះបញ្ជីអ្នកជាប់ពន្ធ...................................................................................................៨
៥.១.១.២ ការផ្តល់សេវាអ្នកជាប់ពន្ធ...................................................................................................៩
៥.១.១.៣ ការចាត់ចែងលិខិតប្រកាស...............................................................................................១០
៥.១.១.៤ ការធ្វើសវនកម្ម.................................................................................................................១១
៥.១.១.៥ ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា........................................................................... ១៣
**៥.១.២ ការពង្រឹងមុខងារគាំទ្រ** ....................................................................................................... ១៣
៥.១.២.១ ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ.......................................................................... ១៣
៥.១.២.២ ការគ្រប់គ្រងធនធានមនុស្ស............................................................................................១៥
៥.១.២.៣ បច្ចេកវិទ្យាព័ត៌មាន........................................................................................................១៦
**៥.២ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**..........................................១៧
**៥.២.១ ការពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញ**...........................................................................១៩
៥.២.១.១ ការប្រកាសគយ.................................................................................................................១៩
ក. ការគ្រប់គ្រងឯកសារនាំចេញ-នាំចូល..........................................................................................១៩
ខ. ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ.....................................................................................................២០
៥.២.១.២ ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ.......................................................................... ២១
ក. ការគ្រប់គ្រងហានិភ័យ................................................................................................................ ២១
ខ. ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ..............................................................................................២២
៥.២.១.៣ សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ...........................................................................២៣
**៥.២.២ ការពង្រឹងយន្តការឆ្លងកាត់**..................................................................................................... ២៤
៥.២.២.១ អំពើរត់គេចពន្ធ............................................................................................................... ២៤
៥.២.២.២ តម្លៃគិតពន្ធគយ............................................................................................................... ២៥
**៥.២.៣ ការពង្រឹងយន្តការគាំទ្រ** ....................................................................................................... ២៥
៥.២.៣.១ ប្រព័ន្ធអាស៊ីគូដា............................................................................................................... ២៥

៥.២.៣.២ ប្រព័ន្ធបញ្ជរតែមួយជាតិ........................................................................................................ ២៦
៥.២.៣.៣ យន្តការសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន........................................................................២៧
៥.២.៣.៤ ផែនការអភិវឌ្ឍន៍ស្ថាប័ន.........................................................................................................២៧
៥.២.៣.៥ ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ...............................................................................២៨
៥.២.៣.៦ ការគ្រប់គ្រងធនធានមនុស្ស.......................................................................................................២៨
៥.២.៣.៧ សវនកម្មផ្ទៃក្នុង..................................................................................................................... ២៩
៥.៣ ការពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ.............................................................................................៣០
៥.៣.១ បរិការណ៍ និងបញ្ហាប្រឈមរួមនៃចំណូលមិនមែនសារពើពន្ធ........................................................................ ៣០
៥.៣.២ វិស័យអាកាសចរណ៍ស៊ីវិល ................................................................................................................ ៣៣
៥.៣.៣ វិស័យទេសចរណ៍.......................................................................................................................... ៣៤
៥.៣.៤ ចំណូលពីអាករស្ពានទូក .................................................................................................................. ៣៥
៥.៣.៥ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ................................................................................................... ៣៦
៥.៣.៦ ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងចំណូលពីផល-អនុផលព្រៃឈើ..............................................................៣៧
៥.៣.៧ ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍ ......................................................................៣៩
៥.៣.៨ ចំណូលពីសហគ្រាសសាធារណៈ.........................................................................................................៣៩
៥.៣.៩ គ្រឹះស្ថានសាធារណៈរដ្ឋបាល............................................................................................................. ៤០
៥.៣.១០ ធនធានធម្មជាតិ........................................................................................................................ ៤២
៥.៣.១១ ចំណូលពីឯកជនភាវូបនីយកម្ម (ការលក់ -ដោះដូរ) និងការជួលទ្រព្យសម្បត្តិរដ្ឋ.......... ៤៣
៥.៣.១២ ចំណូលពីកាស៊ីណូ..........................................................................................................................៤៤
៥.៣.១៣ ចំណូលពីការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) ..........................................................៤៥
៥.៣.១៤ ចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ....................................................................................៤៥
៦. ការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន ........................................................................... ៤៧
៦.១ ការកែលម្អប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ..............................................................................៤៧
៦.២ ការពង្រឹងយន្តការស្ថាប័ន ..........................................................................................................................៤៧
៦.៣ ការកែលម្អគោលនយោបាយ និងក្របខ័ណ្ឌអនុវត្តលើចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ មួយចំនួន................................................................................................................................................៤៩
៦.៣.១ អាករពិសេសលើទំនិញ និងសេវាមួយចំនួន...........................................................................................៤៩
៦.៣.២ អាករលើតម្លៃបន្ថែម..........................................................................................................................៥០
៦.៣.៣ របបម៉ៅការ.....................................................................................................................................៥១
៦.៣.៤ ពិនិត្យឡើងវិញរបបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគ.................................................................៥២
៦.៣.៥ កិច្ចព្រមព្រៀងពន្ធអន្តរជាតិ ................................................................................................................៥២
៦.៣.៦ ពន្ធលើអចលនទ្រព្យ........................................................................................................................៥៣

**៦.៣.៧ ពន្ធលើចំណូលរូបវន្តបុគ្គល**......................................................................................៥៤
**៦.៣.៨ ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ**..........................................................................៥៤
**៦.៣.៩ ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពន្ធដារ**..........................................................................៥៥
**៦.៣.១០ ការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**..........................៥៥
**៦.៣.១១ ការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**.......................................................................... ៥៦
**៧. ការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ**.......................................................................... ៥៧
**៨. សេចក្តីសន្និដ្ឋាន**..........................................................................................................៦១
**ឧបសម្ព័ន្ធ**.......................................................................................................................... ៦២
ឧបសម្ព័ន្ធ ១: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ........................ ៦២
ឧបសម្ព័ន្ធ ២: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា .......៧២
ឧបសម្ព័ន្ធ ៣: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ..................................៨១
ឧបសម្ព័ន្ធ ៤: វិធានការសំខាន់ៗក្នុងការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន ................. ១០៤

# ១. សេចក្តីផ្តើម

១. នៅក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃសន្តិភាព, ឯកភាពជាតិ និងស្ថិរភាពនយោបាយ ដែលជាសមិទ្ធផលប្រវត្តិសាស្ត្រនៃគោលនយោបាយឈ្នះឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លើមូលដ្ឋាននេះ ក្នុងទសវត្សរ៍កន្លងទៅ កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ប្រមាណ ៨% ក្នុងមួយឆ្នាំ និងការកាត់បន្ថយភាពក្រីក្រជាង ២% ក្នុងមួយឆ្នាំ ដែលជាសមិទ្ធផលគួរជាទីមោទនៈមួយ ក្នុងចំណោមបណ្តាប្រទេសដែលមានការអភិវឌ្ឍទាបនានាលើសកលលោក។ ដើម្បីបន្តធានាឱ្យបាននូវចីរភាព និងវឌ្ឍនភាពទាំងនេះ ក្នុងទិសដៅប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ក៏ដូចជាដើម្បីធានាស្ថិរភាព និងចីរភាពថវិកាសម្រាប់បម្រើសេចក្តីត្រូវការនៃចំណាយសាធារណៈចាំបាច់នានា ការពង្រឹងការប្រមូលចំណូលក្នុងស្រុកនឹងដើរតួនាទីជាគន្លឹះដ៏សំខាន់បំផុតមួយ។ នាពេលបច្ចុប្បន្ន នៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ចំណូលក្នុងស្រុកត្រូវបានទទួលស្គាល់ថាជាប្រភពធនធានមួយដ៏មានសារៈសំខាន់សម្រាប់ធានាចីរភាពនៃការអភិវឌ្ឍ ខណៈដែលជំនួយហិរញ្ញប្បទានពីខាងក្រៅត្រូវបានរំពឹងថានឹងមានទំហំមិនគ្រប់គ្រាន់ និងមានភាពមិនប្រាកដប្រជា ដែលអាចប៉ះពាល់ដល់ភាពជាម្ចាស់ពេញលេញក្នុងការគ្រប់គ្រងធនធានឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ថែមទៀត។

២. ដូចបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** នៅក្នុងបរិការណ៍ដែលកំពុងមានការផ្លាស់ប្តូរក្នុងតំបន់ និងសកលលោកជាពិសេសដំណើរផ្លាស់ប្តូរនៅក្នុងប្រទេសទាំងក្នុងវិស័យសេដ្ឋកិច្ច, សង្គម និងប្រជាសាស្ត្រ កម្ពុជាមានតម្រូវការចាំបាច់ក្នុងការកសាងប្រព័ន្ធចំណូលថវិកាជាតិមួយរឹងមាំប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ម៉្យាងដើម្បីធានាបាននូវមូលដ្ឋានអនុគ្រោះដល់ការធ្វើធុរកិច្ច និងការវិនិយោគ និងម្យ៉ាងទៀត ដើម្បីកសាងប្រភពចំណូលជាក់លាក់ និងមានស្ថិរភាព សំដៅឆ្លើយតបទៅនឹងការកើនឡើងនៃសេចក្តីត្រូវការចំណាយ សម្រាប់ធានានិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងសម្រាប់ការអភិវឌ្ឍដូចជា ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការពង្រឹងវិស័យអប់រំ, ការបណ្តុះបណ្តាលជំនាញដល់យុវជន និងយុវនារី, ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាល, ការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវសំណាញ់សុវត្ថិភាពសង្គម និងការពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈ។ល។ ប្រការទាំងអស់នេះមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការធានាបាននូវកំណើនសេដ្ឋកិច្ច ដែលមានលក្ខណៈបរិយាប័ន្ន និងចីរភាពព្រមទាំងការកាត់បន្ថយនូវភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ ទន្ទឹមនេះ ការចាកចេញរបស់កម្ពុជាពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនឹងធ្វើឱ្យកម្ពុជាបាត់បង់ជាបណ្តើរៗនូវហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានសម្បទាន។ លើសពីនេះ សភាពការណ៍សេដ្ឋកិច្ចនៅក្នុងតំបន់ និងសកលលោក ពិសេសការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ព្រមទាំងការចូលរួមបង្កើតសហគមន៍សេដ្ឋកិច្ចតំបន់ ដូចជាសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០១៥ ជាដើម នឹងធ្វើឱ្យប្រទេសកម្ពុជាបាត់បង់ចំណូលពន្ធពាណិជ្ជកម្មក្រៅប្រទេសមួយផ្នែកថែមទៀតផងដែរ។ ដូច្នេះ កត្តាទាំងនេះទាមទារឱ្យកម្ពុជាខិតខំប្រឹងប្រែងដោយខ្លួនឯងក្នុងការគៀរគរចំណូលទាំងរយៈពេលខ្លី និងមធ្យមឱ្យបានច្រើនថែមទៀត ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការដូចពោលខាងលើ។

៣. ក្នុងរយៈពេលកន្លងមកនេះ តាមរយៈការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើការកៀរគរចំណូលបន្ថែម ដែលធ្វើឱ្យចំណូលក្នុងស្រុកមានការកើនឡើងជាលំដាប់។ ជាក់ស្តែង កិច្ចខិតខំប្រឹងប្រែងពង្រីកមូលដ្ឋានពន្ធ និងការកែលម្អអត្រាពន្ធ បានធ្វើឱ្យចំណូលចរន្តកើនឡើងគួរឱ្យកត់សម្គាល់ពី ១០,២៧% នៃ ផលិតផលក្នុងស្រុកសរុប (ផសស) នៅឆ្នាំ ២០០៤ ទៅ ១៥,០៤% នៃ ផសស នៅឆ្នាំ ២០១៣ តាមអត្រាកំណើនជាមធ្យម ១៧% ក្នុង ១ ឆ្នាំ។ ក្នុងនោះ ចំណូលសារពើពន្ធក៏បានកើនឡើងជាលំដាប់ផងដែរពី ៨,៤៦% នៃ ផសស ទៅ ១២,៦៩% នៃ ផសស ក្នុងអំឡុងឆ្នាំ ២០០៤-២០១៣។ ប៉ុន្តែចំណូលដែលប្រមូលបានរបស់កម្ពុជា នៅតែមានកម្រិតទាបនៅឡើយធៀបជាមួយប្រទេសនៅក្នុងតំបន់អាស៊ាន និងប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា។ កម្រិតចំណូលទាបនេះបណ្តាលមកពីមូលហេតុមួយចំនួន រួមមាន : (១)- មូលដ្ឋានពន្ធតូចចង្អៀតដោយសារតែរចនាសម្ព័ន្ធសេដ្ឋកិច្ចមិនមានលក្ខណៈទូលាយ និងឧស្សាហកម្មនៅមិនទាន់បានធ្វើពិពិធកម្ម, (២)- វប្បធម៌បង់ពន្ធ និងការគោរពច្បាប់នៅមានកម្រិត, (៣)- រដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធនៅទន់ខ្សោយ និង (៤)- កំណើននៃការលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

៤. ស្ថិតក្នុងបរិការណ៍នេះ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រូវបានរៀបចំឡើងដើម្បីកំណត់ចក្ខុវិស័យ, គោលបំណង និងគោលដៅ, អភិក្រម, វិធានការកែទម្រង់រដ្ឋបាល, ការកែលម្អគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍កម្ពុជានាពេលបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមខាងមុខ។

## ២. ចក្ខុវិស័យ

**៥.** ចក្ខុវិស័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ គឺផ្សារភ្ជាប់នឹងចក្ខុវិស័យនៃការអភិវឌ្ឍកម្ពុជា ដោយផ្តោតលើការប្រមូលចំណូលក្នុងស្រុកឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។ កម្ពុជាមានចក្ខុវិស័យសម្រេចឱ្យបាននូវឋានៈ ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដោយចំណូលសម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំនឹងកើនឡើងដល់រង្វង់ ៤.០០០ ទៅ ៥.០០០ ដុល្លារអាមេរិកនៅឆ្នាំ ២០៣០ តាមរយៈការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ដែលមានមូលដ្ឋានរឹងមាំ និងភាពធន់ខ្ពស់, សមធម៌នៃការបែងចែកផ្លែផ្កានៃកំណើន, ការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ចដើម្បីធានាបានប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ដែលមានបរិយាប័ន្ន, ផ្តល់ឱកាសស្មើគ្នា និងប្រកបដោយយុត្តិធម៌។ ក្នុងន័យនេះ ចំណូលក្នុងស្រុករបស់កម្ពុជានឹងក្លាយជាគ្នាស់យ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ការផ្តល់ការងារជូនប្រជាពលរដ្ឋ តាមរយៈការបែងចែកឡើងវិញនូវផលទុនជាតិក្នុងក្របខ័ណ្ឌនៃប្រព័ន្ធថវិកាជាតិដ៏សមស្របមួយ។ ម៉្យាងទៀត ការកៀរគរចំណូលឱ្យអស់សក្តានុពល គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍប្រទេស និងបំពេញឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការនៃចំណាយសាធារណៈចាំបាច់នានា ដើម្បីចូលរួមវិភាគទានដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យខាងលើ។

## ៣. គោលបំណង និងគោលដៅ

**៦.** យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមានគោលបំណងពង្រឹងរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ និងលើកកម្ពស់វប្បធម៌បង់ពន្ធ និងការគោរពច្បាប់ ដើម្បីពង្រឹងការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព, ឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចទីផ្សារដែលកំពុងលូតលាស់ និងការកើនឡើងនៃចំនួនអ្នកបង់ពន្ធ ក៏ដូចជាភាពស្មុគស្មាញនៃសកម្មភាពធុរកិច្ចក្នុងសម័យទំនើប ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវការផ្តល់សេវាជូនអ្នកបង់ពន្ធ, រួមចំណែកកែលម្អបរិយាកាសវិនិយោគ និងការអភិវឌ្ឍវិស័យឯកជន, និងធានាសមធម៌ និងយុត្តិធម៌សម្រាប់ពលរដ្ឋទាំងអស់។

**៧.** ដើម្បីសម្រេចគោលបំណងខាងលើ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមានគោលដៅដូចតទៅ ៖ (១)- ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិចបំផុត ០,៥ ពិន្ទុភាគរយ បន្ថែមលើផលធៀបរវាងចំណូលចរន្តនឹងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដោយត្រូវកើនពី ១៥,១៨% នៅឆ្នាំ ២០១៤ ដល់ ១៧,៣៥% នៅឆ្នាំ ២០១៨, (២)- ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅអភិវឌ្ឍន៍ជាតិដែលស្របនឹង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** និងដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ, (៣)- ពង្រីកលំហថវិកា ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គ្រប់គ្រងបំណុលប្រកបដោយចីរភាព និងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស និង (៤)- បង្កើនធនធានថវិកាសម្រាប់តម្រូវការបន្ទាន់, ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត។

# ៤. អតិក្រមនៃការរៀបចំយុទ្ធសាស្ត្រ

៨. យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមានអភិក្រមផ្អែកលើគោលការណ៍ធំៗចំនួនបួនគឺ : (១)- ប្រមូលឱ្យអស់លទ្ធភាពនូវសក្តានុពលចំណូលដែលមាននាពេលបច្ចុប្បន្ន, (២)- មិនបង្កើតប្រភេទពន្ធថ្មី, (៣)- មិនដំឡើងអត្រាពន្ធ និងអាករ លើកលែងតែនៅក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល និងការការពារសុខភាព និង/ឬការការពារបរិស្ថាន និង (៤)- ធានាឱ្យបាននូវភាពងាយស្រួល, សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព, តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូល។

៩. ផ្អែកលើគោលការណ៍ធំៗខាងលើ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនឹងផ្តោតលើការងារកែទម្រង់ ៤ យ៉ាងគឺ : (១)- ការលើកកម្ពស់វប្បធម៌បង់ពន្ធ, (២)- ការកែលម្អការផ្តល់សេវាបង់ពន្ធ, (៣)- ការកែលម្អរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ និង (៤)- ការកែលម្អអភិបាលកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធ ។

១០. ដើម្បីសម្រេចបាននូវចក្ខុវិស័យ, គោលបំណង, គោលដៅ និងគោលការណ៍ធំៗខាងលើ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមត្រូវបានរៀបចំឡើងដោយផ្អែកលើសសរស្តម្ភបី រួមមាន÷

- ***សសរស្តម្ភទីមួយគឺការពង្រឹងរដ្ឋបាលចំណូល*** : ជាមួយនឹងគោលការណ៍នៃការប្រមូលចំណូលសក្តានុពលនាពេលបច្ចុប្បន្នឱ្យអស់លទ្ធភាព ការពង្រឹង និងការកែទម្រង់រដ្ឋបាល គឺជាការចាំបាច់សម្រាប់កាត់បន្ថយភាពទន់ខ្សោយ និងភាពមិនគ្រប់ជ្រុងជ្រោយនៃការគ្រប់គ្រងការប្រមូលចំណូល ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចទីផ្សារដែលកំពុងលូតលាស់, ការកើនឡើងនៃចំនួនអ្នកបង់ពន្ធ, ការកើនឡើងឥតឈប់ឈរនៃភាពស្មុគស្មាញនៅក្នុងសកម្មភាពពាណិជ្ជកម្ម និងការវិវត្តនៃកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ។ ការពង្រឹងរដ្ឋបាលនឹងផ្តោតទៅលើបញ្ហាប្រឈមធំៗ ដែលមាននៅក្នុងការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ហើយលើកជាវិធានការជាក់ស្តែងដោយមានកំណត់ពេលវេលាច្បាស់លាស់សម្រាប់អនុវត្តឱ្យបានសម្រេច ដើម្បីដោះស្រាយបញ្ហាប្រឈមនីមួយៗប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។
- ***សសរស្តម្ភទីពីរគឺការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន*** : ជាមួយនឹងការពង្រឹងរដ្ឋបាល ការកែលម្អគោលនយោបាយក៏ជាកត្តាគន្លឹះមួយនៅក្នុងការពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលផងដែរ។ ទោះបីជារួម ប្រភេទពន្ធថ្មីមិនត្រូវបានបង្កើត ហើយអត្រាពន្ធ និងអាករមិនត្រូវបានដំឡើងក៏ដោយក៏ប្រសិទ្ធភាពនៃការប្រមូលចំណូលតម្រូវឱ្យមានការកែលម្អគោលនយោបាយមួយចំនួន ដូចជា អាករពិសេស, អាករលើតម្លៃបន្ថែម, របបម៉ៅការ, កាតព្វកិច្ចពន្ធអន្តរជាតិ, ពន្ធលើអចលនទ្រព្យ និងរបបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគ។ល។
- ***សសរស្តម្ភទីបីគឺការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ*** : ការអនុវត្តយុទ្ធសាស្ត្រនេះទាមទារឱ្យមានរចនាសម្ព័ន្ធត្រួតពិនិត្យ និងវាយតម្លៃជាក់លាក់។ ក្នុងន័យនេះ រចនាសម្ព័ន្ធត្រួតពិនិត្យ និងវាយតម្លៃត្រូវបង្កើតឡើងដោយរួមមាន គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ និងគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដែលមានតួនាទី និងភារកិច្ចច្បាស់លាស់។ ទន្ទឹមនេះ ដើម្បីវាយតម្លៃលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នប្រមូលចំណូលទាំងអស់ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនឹងដាក់ចេញនូវសូចនាករតាមវិធានការនីមួយៗ និងសូចនាករលទ្ធផលនៃការប្រមូលចំណូលជាក់ស្តែងតាមមុខចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដោយបញ្ជាក់អំពីពេលវេលាអនុវត្តច្បាស់លាស់។

រូបភាព ១: អភិក្រមនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨



# ៥. ការពង្រឹងរដ្ឋបាលចំណូល

**១១.** ការពង្រឹងរដ្ឋបាលចំណូល គឺជាការងារដ៏សំខាន់នៅក្នុងប្រទេសនីមួយៗ។ គោលនយោបាយចំណូលមានសក្តានុពលក្នុងការបង្កើនចំណូល ប៉ុន្តែចំណូលដែលទទួលបានពិតប្រាកដ ភាគច្រើនពឹងផ្អែកទៅលើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃរដ្ឋបាលចំណូល។ ហេតុនេះ ការពង្រឹងរដ្ឋបាលចំណូលមានវិសាលភាពគ្របដណ្តប់លើការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ[1], ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងការពង្រឹងរដ្ឋបាលក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

## ៥.១ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

**១២.** អគ្គនាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងដើម្បីប្រមូលពន្ធនិងអាករក្នុងស្រុក និងចូលរួមក្នុងការរៀបចំគោលនយោបាយសារពើពន្ធ, សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រមូលពន្ធ និងអាករ។ កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់ពេញលេញសំខាន់ៗចំនួន ២ លើក លើប្រព័ន្ធពន្ធដារ គឺនៅឆ្នាំ ១៩៩៤ និងឆ្នាំ ១៩៩៧ ព្រមទាំងការកែទម្រង់បន្ទាប់បន្សំមួយចំនួនទៀតលើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ។ ជាមួយនឹងការកែទម្រង់ទាំងនេះ ការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយនេះមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយមានអត្រាកំណើនមធ្យមប្រចាំឆ្នាំប្រមាណជាង ២០% (រូបភាព ២)។ ចំណូលពន្ធដារសរុបរបស់អគ្គនាយកដ្ឋានពន្ធដារធៀបនឹង ផសស បានកើនឡើងប្រមាណ ៣ ដង គឺពី ១,៩% នៅឆ្នាំ ២០០២ ដល់ ៥,៨% នៅឆ្នាំ ២០១៣។ ចំណូលពន្ធដារគិតជាសមាមាត្រនៃចំណូលពន្ធសរុបបានកើនពី ២៧% នៅឆ្នាំ ២០០២ ដល់ ៤៦% នៅឆ្នាំ ២០១៣។

**រូបភាព ២ : សមិទ្ធផលនៃការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ (២០០២-២០១៣)**




*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

[1] អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ជាស្ថាប័នចំណុះក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**១៣.** សមិទ្ធផលទាំងនេះសម្រេចបានដោយសារកំណើនខ្ពស់របស់ប្រភេទពន្ធសំខាន់ៗដូចជា អាករលើតម្លៃបន្ថែមក្នុងស្រុក, ពន្ធលើប្រាក់ចំណេញ, អាករពិសេសក្នុងស្រុក, ពន្ធលើប្រាក់បៀវត្សរ៍ និងចំណូលពន្ធពីថ្នាក់ក្រោមជាតិ។ ក្នុងចំណោមប្រភេទពន្ធទាំងអស់ ដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ អាករលើតម្លៃបន្ថែមក្នុងស្រុក និងពន្ធលើប្រាក់ចំណេញបានរួមចំណែកប្រមាណជាង ៦២% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ ២០១៣។ ប្រភេទពន្ធទាំងនេះត្រូវបានរំពឹងថានឹងបន្តល្បឿនកំណើនក្នុងរយៈពេលមធ្យមខាងមុខ ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់, កំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល, កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែ-ទម្រង់ជាបន្តបន្ទាប់ទៀតរបស់អគ្គនាយកដ្ឋានពន្ធដារនាពេលអនាគត។

**១៤.** អគ្គនាយកដ្ឋានពន្ធដារគ្រប់គ្រងការប្រមូលពន្ធតាមមុខងារ និងតាមប្រភេទអ្នកជាប់ពន្ធ។ ការគ្រប់គ្រងតាមមុខងារត្រូវបានបែងចែកជាមុខងារប្រតិបត្តិការស្នូល ដែលរួមមាន : (១)- ការចុះបញ្ជីអ្នកជាប់ពន្ធ, (២)- ការផ្តល់សេវាអ្នកជាប់ពន្ធ, (៣)- ការចាត់ចែងលិខិតប្រកាស, (៤)- ការធ្វើសវនកម្ម និង (៥)- ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា និងមុខងារគាំទ្រ ដែលរួមមាន : (១)- ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ, (២)- ការគ្រប់គ្រងធនធានមនុស្ស និង (៣)- បច្ចេកវិទ្យាព័ត៌មាន។

**១៥.** ជាមួយគ្នានេះ អ្នកជាប់ពន្ធត្រូវបានបែងចែកជាបីប្រភេទគឺ អ្នកជាប់ពន្ធធំ, អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច។ អ្នកជាប់ពន្ធធំសំដៅដល់សហគ្រាស ដែលជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, សាខាក្រុមហ៊ុនបរទេស និងសហគ្រាសផ្សេងទៀត ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១.០០០ លានរៀលឡើងទៅ។ នៅឆ្នាំ ២០១៣ អ្នកជាប់ពន្ធធំទាំងនេះ គឺជាប្រភពចំណូលពន្ធដារប្រមាណជា ៨០% នៃចំណូលពន្ធសរុបរបស់អគ្គនាយក-ដ្ឋានពន្ធដារ។ ចំណូលពន្ធដែលប្រមូលបានពីអ្នកជាប់ពន្ធធំជាងគេទាំង ១០០ ក្រុមហ៊ុនមានសមាមាត្រជាង ៦០% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារ។

**១៦.** អ្នកជាប់ពន្ធមធ្យម គឺសំដៅដល់អ្នកជាប់ពន្ធដែលមានផលរបរប្រចាំឆ្នាំលើសពី ៥០០ លានរៀលចំពោះការផ្គត់ផ្គង់ទំនិញ, ផលរបរលើសពី ២៥០ លានរៀលចំពោះការផ្គត់ផ្គង់សេវា ឬផលរបរលើសពី ១២៥ លានរៀល ចំពោះការផ្គត់ផ្គង់ទំនិញ និងសេវាជាមួយរដ្ឋ។ នៅឆ្នាំ ២០១៣ អ្នកជាប់ពន្ធមធ្យមទាំងនេះជាប្រភពចំណូលពន្ធប្រមាណ ១៩,៣% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារ។ អ្នកជាប់ពន្ធតូច គឺសំដៅដល់អ្នកជាប់ពន្ធម៉ៅការដែលមិនស្ថិតនៅក្នុងអ្នកជាប់ពន្ធធំ និងមធ្យម និងជាប្រភពចំណូលពន្ធប្រមាណ ០,៧% នៃចំណូលសរុបរបស់អគ្គ-នាយកដ្ឋានពន្ធដារ។

**១៧.** ទោះបីជាអត្រាកំណើនចំណូលពន្ធក្នុងស្រុកមានកម្រិតខ្ពស់ អនុបាតចំណូលពន្ធធៀបនឹង ផសសរបស់ប្រទេសកម្ពុជាមានកម្រិតទាបជាងប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែល ដោយសារកម្ពុជាមានមូលដ្ឋានកំណត់ពន្ធតូចនៅឡើយ និងវប្បធម៌បង់ពន្ធក៏នៅមានកម្រិតទាប។ ម្យ៉ាងវិញទៀត បើធៀបជាមួយបណ្តារដ្ឋបាលសារពើពន្ធរបស់ប្រទេសមួយចំនួននៅក្នុងតំបន់ រដ្ឋបាលសារពើពន្ធកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនទាំងផ្នែកសមត្ថភាព, ចំនួនមន្ត្រី, ធនធានសម្ភារៈ និងធនធានបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រដល់ប្រតិបត្តិការទូទៅ។

**១៨.** ដើម្បីដោះស្រាយបញ្ហាប្រឈមធំៗដូចបានរៀបរាប់ខាងលើ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយក-ដ្ឋានពន្ធដារ នឹងផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ការកែលម្អមុខងារនីមួយៗនឹងផ្តល់ផលវិជ្ជមានដល់មុខងារដទៃទៀត។

រូបភាព ៣ : គំនូសបំព្រួញការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ




### ៥.១.១ ការពង្រឹងមុខងារប្រតិបត្តិការស្នូល

**១៩.** មុខងារប្រតិបត្តិការស្នូលគឺជាប្រភេទមុខងារ ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងប្រតិបត្តិការប្រមូលពន្ធដោយផ្ទាល់លើរូបវន្តបុគ្គលនិងនីតិបុគ្គល ដែលច្បាប់ស្តីពីសារពើពន្ធកំណត់ថាត្រូវជាប់កាតព្វកិច្ចបង់ពន្ធ។ ដំណើរការល្អនៃមុខងារប្រតិបត្តិការស្នូល អាចជួយសម្រួលដល់ការគ្រប់គ្រងក្នុងអគ្គនាយកដ្ឋានពន្ធដារ ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ មុខងារប្រតិបត្តិការស្នូល រួមមាន : (១)- ការចុះបញ្ជីអ្នកជាប់ពន្ធ, (២)- ការផ្តល់សេវាអ្នកជាប់ពន្ធ, (៣)- ការចាត់ចែងលិខិតប្រកាស, (៤)- ការធ្វើសវនកម្ម និង (៥)- ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា។

#### ៥.១.១.១ ការចុះបញ្ជីអ្នកជាប់ពន្ធ

**២០.** ប្រព័ន្ធនៃការចុះបញ្ជីអ្នកជាប់ពន្ធពេញលេញមួយ ដែលគ្រប់គ្រងទិន្នន័យបានត្រឹមត្រូវ និងផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធតែមួយ មានសារៈសំខាន់សម្រាប់រដ្ឋបាលសារពើពន្ធ ដើម្បីធ្វើជាមូលដ្ឋានក្នុងការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការប្រមូលបំណុលពន្ធ និងការត្រួតពិនិត្យផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាពទៅលើអ្នកជាប់ពន្ធ។ បច្ចុប្បន្ន អ្នកជាប់ពន្ធចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារមានចំនួនសរុបប្រមាណ ៩០.៥៥០ សហគ្រាស។ ទន្ទឹមនេះ ដើម្បីពង្រឹងប្រព័ន្ធនៃការចុះបញ្ជីអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានដំឡើងបណ្តាញតភ្ជាប់តំបន់ទូលាយ (Wide Area Network-WAN) ដើម្បីបញ្ជូនព័ត៌មាន និងទិន្នន័យអ្នកជាប់ពន្ធពីសាខាពន្ធដារខណ្ឌចំនួន ៧ (ជំហានទី១) និងខេត្តចំនួន ១៦ (ជំហានទី២) មកប្រមូលផ្តុំនៅអគ្គនាយកដ្ឋានពន្ធដារ។

**២១.** ប្រសិទ្ធភាពនៃការចុះបញ្ជី និងការគ្រប់គ្រងបញ្ជីអ្នកជាប់ពន្ធនៅមានកម្រិត ដោយសារបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ការបញ្ជូនទិន្នន័យលើការចុះបញ្ជីអ្នកជាប់ពន្ធមកថ្នាក់កណ្តាលនៅមិនទាន់មានលក្ខណៈស្វ័យប្រវត្តិ និងទាន់ពេលវេលា ដោយសារគម្រោងជំហានទី ២ នៅមិនទាន់បញ្ចប់នៅឡើយ, (២)- ព័ត៌មានអំពីក្រុមហ៊ុនមួយចំនួនមិនត្រឹមត្រូវ (ដូចជាអាសយដ្ឋានរបស់ក្រុមហ៊ុនពុំបានកំណត់ច្បាស់លាស់) ដោយសារការផ្តល់ព័ត៌មានមិនច្បាស់លាស់ពីក្រសួងពាណិជ្ជកម្ម និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗ និង (៣)- ការខកខានមិនបានលុបចេញពីបញ្ជីអ្នកជាប់ពន្ធ (Deregistration) បន្ទាប់ពីបានធ្វើការលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីចំនួនពីរលើកក្នុងឆ្នាំ ២០០២ និង ២០០៥ ចំពោះក្រុមហ៊ុនមួយចំនួនដែលបានបាត់ខ្លួន ឬមិនដាក់លិខិតប្រកាស។

**២២.** ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការមួយចំនួននៅក្នុងរយៈពេលខ្លី ដូចខាងក្រោម÷

- បង្កើតប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីក្រុមហ៊ុនតាមរយៈប្រព័ន្ធប្រមូលផ្តុំទិន្នន័យនៅថ្នាក់កណ្តាល,

- ធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ពិសេសបន្តការងារលុបចេញពីបញ្ជីចំពោះសហគ្រាសដែលបាត់ខ្លួន ឬសហគ្រាសមិនដាក់លិខិតប្រកាសបន្ទាប់ពីបានធ្វើការត្រួតពិនិត្យរួច,
- ចុះត្រួតពិនិត្យដល់ទីតាំងរបស់ក្រុមហ៊ុន ដែលស្នើសុំចុះបញ្ជីពន្ធដារ និងធ្វើយុទ្ធនាការទូទាំងប្រទេស ដើម្បីប្រមូលព័ត៌មានចុះបញ្ជីដោយចុះអង្កេតស្រាវជ្រាវតាមដងផ្លូវ, ទិន្នន័យពីតតិយជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីបញ្ចូលអ្នកជាប់ពន្ធទៅក្នុងបញ្ជី ឬដើម្បីពិនិត្យផលរបរ ដែលត្រូវផ្ទេរពីរបបម៉ៅការទៅរបបស្វ័យប្រកាស,
- ធ្វើបច្ចុប្បន្នកម្មវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម (អតប) ដែលបានចេញ និងត្រៀមផ្តល់ជូនថ្មីដែលមានសុវត្ថិភាពជាងមុន,
- ចូលរួមអនុវត្តយន្តការ "ដំបូលតែមួយ" ជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រសួងពាណិជ្ជកម្ម ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធ សម្រាប់កិច្ចការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម។

### ៥.១.១.២ ការផ្តល់សេវាអ្នកជាប់ពន្ធ

**២៣.** ការផ្តល់សេវាដល់អ្នកជាប់ពន្ធជាការងារសំខាន់ដែលជួយពង្រឹងការគោរពច្បាប់ និងវប្បធម៌បង់ពន្ធព្រមទាំងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលពន្ធ។ បច្ចុប្បន្ន ការផ្តល់សេវាអ្នកជាប់ពន្ធមានវឌ្ឍនភាពតាមរយៈការអនុវត្តផែនការពង្រឹងសេវាអ្នកជាប់ពន្ធ ដូចជា រៀបចំសិក្ខាសាលាផ្សព្វផ្សាយ, ឆ្លើយសំណួរផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរទៅអ្នកជាប់ពន្ធ, បណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជននៅសាលាជាតិពន្ធដារ, ផ្តល់ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងផ្សេងៗ, បទប្បញ្ញត្តិស្តីពីពន្ធដារ និងសៀវភៅណែនាំមួយចំនួន និងផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ទន្ទឹមនេះ ដើម្បីបន្តពង្រឹងអភិបាលកិច្ច អគ្គនាយកដ្ឋានពន្ធដារបានបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវតារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈព្រមទាំងបានរៀបចំឱ្យមានកន្លែង ឬប្រអប់សំបុត្រទទួលបណ្តឹង ជាពិសេសក្នុងករណីមានការអនុវត្តខុសឆ្គងពីស្តង់ដារសេវា, ការយកកម្រៃលើសពីការកំណត់ ឬការយឺតយ៉ាវជាដើម។

**២៤.** ជាមួយនឹងវឌ្ឍនភាពខាងលើនេះ អគ្គនាយកដ្ឋានពន្ធដារនៅមានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការផ្តល់សេវាអ្នកជាប់ពន្ធ ដូចជា : (១)- កង្វះផែនការយុទ្ធសាស្ត្ររួមដែលបង្ហាញពីទិសដៅ និងកម្មវិធីជាក់លាក់នៃការលើកកម្ពស់ដល់ការយល់ដឹងជាសកលនៃវប្បធម៌បង់ពន្ធ, (២)- ការផ្តល់ និងបែងចែកធនធាននៅមិនទាន់គ្រប់គ្រាន់សម្រាប់សកម្មភាពសេវាអ្នកជាប់ពន្ធ, (៣)- នត្ថិភាពនៃការិយាល័យពិគ្រោះយោបល់ពន្ធតាមទូរស័ព្ទបានកាត់បន្ថយលទ្ធភាពក្នុងការទទួលបានព័ត៌មានលម្អិតទាក់ទងនឹងការបង់ពន្ធ និង (៤)- ចំនួន និងសមត្ថភាពរបស់មន្ត្រីមិនទាន់ឆ្លើយតបទៅនឹងទំហំនៃការងារផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព។

**២៥.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- រៀបចំ និងដាក់ឱ្យអនុវត្តផែនការផ្តល់សេវាអ្នកជាប់ពន្ធធំបំផុតចំនួន ១៥០,

- រៀបចំបញ្ជីសំណួរចម្លើយ ដែលត្រូវបានសួរញឹកញាប់ និងចងក្រងដាក់ចូលក្នុងសៀវភៅណែនាំ និងដាក់ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ,
- រៀបចំបង្កើតការិយាល័យផ្តល់ព័ត៌មានតាមទូរស័ព្ទ និងការិយាល័យទំនាក់ទំនងសាធារណៈនៅនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ និងបង្កើតបញ្ជរពិគ្រោះយោបល់ពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ,
- បង្កើនចំនួនមន្ត្រីទទួលបន្ទុកសេវាអ្នកជាប់ពន្ធ និងផ្តល់ធនធាន និងមធ្យោបាយបន្ថែមសម្រាប់ការងារផ្តល់សេវាអ្នកជាប់ពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ ដើម្បីបំពេញបន្ថែមនូវតម្រូវការជាក់ស្តែង និងផ្តល់សេវាអ្នកជាប់ពន្ធឱ្យមានប្រសិទ្ធភាព,
- បន្តអនុវត្ត និងពង្រឹងការបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវតារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈ,
- បន្តរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតាមរយៈ ប្រអប់សំបុត្រ, ទូរស័ព្ទ ឬអ៊ីម៉ែល,
- រៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសេវាអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីប្រភេទពន្ធនីមួយៗ,
- រៀបចំ និងផ្សព្វផ្សាយដល់សាធារណជន តាមរយៈការរៀបចំសិក្ខាសាលា, សារព័ត៌មាន, វិទ្យុ, ទូរទស្សន៍, គេហទំព័រ, ផ្ទាំងផ្សព្វផ្សាយ និងខិត្តបណ្ណផ្សព្វផ្សាយ ដើម្បីបញ្ច្រាបវប្បធម៌បង់ពន្ធ,
- ពង្រឹងសមត្ថភាព និងកិច្ចសហការជាមួយផ្នែកឯកជន, គណនេយ្យករ, សវនករជំនាញ, អ្នកច្បាប់ និងភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីពង្រឹងការគោរពច្បាប់ និងស្វែងយល់ពីតម្រូវការរបស់អ្នកជាប់ពន្ធ។

***វិធានការរយៈពេលមធ្យម:***

- រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រពង្រឹងសេវាអ្នកជាប់ពន្ធដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងនោះរួមមានយន្តការសម្របសម្រួលរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន, កម្មវិធីផ្តល់សេវាអ្នកជាប់ពន្ធ, ការបណ្តុះបណ្តាលក្រុមមន្ត្រីបង្គោល ដែលមានជំនាញសេវាអ្នកជាប់ពន្ធ និងការផ្សព្វផ្សាយ។ល។

### ៥.១.១.៣ ការចាត់ចែងលិខិតប្រកាស

**២៦.** អ្នកជាប់ពន្ធដែលបានចុះបញ្ជីរួចមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ។ នាពេលកន្លងមក អគ្គនាយកដ្ឋានពន្ធដារបានខិតខំកែលម្អការចាត់ចែងលិខិតប្រកាស ដោយបានបញ្ចូលគ្នានូវលិខិតប្រកាសប្រចាំខែ និងប្រចាំឆ្នាំ, ដាក់លិខិតប្រកាសនៅលើគេហទំព័រដែលអ្នកជាប់ពន្ធអាចទាញយកមកប្រើបាន និងពង្រីកសេវាបង់ប្រាក់ពន្ធតាមប្រព័ន្ធធនាគារ។ល។

**២៧.** អ្នកជាប់ពន្ធមួយចំនួន ទាំងអ្នកជាប់ពន្ធធំនៅក្នុងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងអ្នកជាប់ពន្ធមធ្យមនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌមិនបានដាក់លិខិតប្រកាសពន្ធ ហើយមួយចំនួនទៀតបានដាក់លិខិតប្រកាសតែប្រកាសថា "គ្មានសកម្មភាព"។ លើសពីនេះ ដំណើរការនៃការដាក់លិខិតប្រកាសនៅតែមានភាពស្មុគស្មាញ និងយឺតយ៉ាវ ដែលមិនអាចគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលា ដោយសារមូលហេតុដូចតទៅ : (១)- ការដាក់លិខិតប្រកាសជាទម្រង់ក្រដាស, (២)- នត្ថិភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់កំណត់ហានិភ័យនៅដំណាក់កាល

ដំបូង ដើម្បីចុះធ្វើសវនកម្មចំពោះអ្នកជាប់ពន្ធដែលមានហានិភ័យឱ្យបានទាន់ពេលវេលា និង (៣)- ចំនួន និងសមត្ថភាពនៃមន្ត្រីនៅក្នុងការិយាល័យចាត់ចែងលិខិតប្រកាសនៅមានកម្រិត។

**២៨.** ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- រៀបចំស្តង់ដាររបាយការណ៍ដាក់លិខិតប្រកាសប្រចាំខែ ចំពោះគ្រប់ប្រភេទពន្ធសម្រាប់អង្គភាពនីមួយៗ,
- កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាសឱ្យបានខ្ពស់ជាអតិបរមា បន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា,
- អនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្ន ចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ ខែជាប់គ្នា,
- រៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ។

### ៥.១.១.៤ ការធ្វើសវនកម្ម

**២៩.** កិច្ចការសវនកម្មដើរតួនាទីដ៏សំខាន់ក្នុងចំណោមកិច្ចការចម្បងៗក្នុងរដ្ឋបាលសារពើពន្ធ ដែលត្រូវបានប្រើប្រាស់ក្នុងការពិនិត្យបញ្ជាក់ពីភាពស្មោះត្រង់ និងភាពត្រឹមត្រូវក្នុងការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស។ សវនកម្មត្រូវបានបែងចែកជាពីរប្រភេទ : (ក)- សវនកម្មមានកម្រិត អនុវត្តដោយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខេត្ត-ខណ្ឌ និងត្រូវធ្វើឡើងក្នុងឆ្នាំចរន្តថ្មីៗ (រយៈពេល ១២ ខែ) ដោយផ្តោតលើប្រភេទពន្ធជាក់លាក់មួយចំនួន និង (ខ)- សវនកម្មពេញលេញត្រូវធ្វើឡើងសម្រាប់ការិយបរិច្ឆេទបីទៅដប់ឆ្នាំកន្លងទៅ ដោយនាយកដ្ឋានសវនកម្មសហគ្រាស និងត្រូវពិនិត្យលើពន្ធគ្រប់ប្រភេទដោយរួមទាំងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំផង។

**៣០.** កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានខិតខំពង្រឹងប្រសិទ្ធភាពនៃការធ្វើសវនកម្ម តាមរយៈការកំណត់ហានិភ័យ សម្រាប់ធ្វើសវនកម្មតាមវិស័យ, វិភាគហានិភ័យផ្អែកលើលិខិតប្រកាសពន្ធ, របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស, សហគ្រាសដែលមានឥណទានយោងខ្ពស់, ការផ្ទៀងផ្ទាត់លើវិក្កយបត្រអាករលើតម្លៃបន្ថែម, ការផ្ទៀងផ្ទាត់ព័ត៌មានពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ស្ថានភាពសេដ្ឋកិច្ច និងរដូវកាលអាជីវកម្ម។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារ បានជ្រើសរើស និងបណ្តុះបណ្តាលសវនករបន្ថែម, រៀបចំសារាចរណែនាំចំនួន ១៥ ទាក់ទិននឹងការធ្វើសវនកម្ម និងការកំណត់ហានិភ័យ និងកំពុងរៀបចំសៀវភៅស្តីពីបែបបទអនុវត្តសវនកម្មលើវិស័យសំខាន់ៗមួយចំនួនដូចជា ធនាគារ, សំណង់, ដឹកជញ្ជូន និងទូរគមនាគមន៍។

**៣១.** ទោះជាមានការកែលម្អមួយចំនួន និងកិច្ចប្រឹងប្រែងលើការងារសវនកម្មដូចខាងលើ អគ្គនាយកដ្ឋានពន្ធដារនៅមានបញ្ហាប្រឈមមួយចំនួនទៀតដូចជា : (១)- ពុំទាន់មានសេចក្តីណែនាំជាផ្លូវការរួមមួយក្នុងការកំណត់វិធីសាស្ត្រវាយតម្លៃហានិភ័យ និងការជ្រើសរើសអ្នកជាប់ពន្ធ ដើម្បីធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព, (២)- មិនទាន់មានផែនការរួមមួយសម្រាប់ដោះស្រាយហានិភ័យ ដែលមានលក្ខណៈខុសៗគ្នាទៅតាមវិស័យ, (៣)- មិនទាន់មាន

ការវិភាគ និងសិក្សាលម្អិតបន្ថែមអំពីក្រុមហ៊ុនធំៗ និងក្រុមហ៊ុន ដែលប្រកាសខាតច្រើនឆ្នាំតែមិនក្ស័យធន, (៤)- ព័ត៌មានសម្រាប់វិភាគហានិភ័យស្ថិតនៅរាយប៉ាយគ្រប់អង្គភាពរបស់អគ្គនាយកដ្ឋានពន្ធដារ, (៥)- ចំនួន និងសមត្ថភាពសវនករនៅមានកម្រិត និង (៦)- យន្តការលើកទឹកចិត្តនៅមិនទាន់សមរម្យចំពោះសវនករ ដែលសម្រេចបានលទ្ធផលសវនកម្មល្អ។

៣២. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី:***

- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិភាពក្នុងការធ្វើសវនកម្ម និងរៀបចំសារាចរណែនាំ ដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដាររួម ដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្ម,
- ជ្រើសរើសបន្ថែមសវនករទាំងក្នុងមុខងារសវនកម្មពេញលេញ និងសវនកម្មមានកម្រិត ដើម្បីបំពេញតម្រូវការជាក់ស្តែងនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌសម្រាប់ឆ្លើយតបនឹងកំណើនចំនួនសហគ្រាស និងប្រសិទ្ធភាពនៃការធ្វើសវនកម្ម,
- រៀបចំ និងអនុវត្តយន្តការលើកទឹកចិត្តដល់សវនករ ដោយផ្អែកលើលទ្ធផលសវនកម្មពិតប្រាកដ,
- រៀបចំសៀវភៅណែនាំស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងសវនកម្ម ដើម្បីឱ្យអ្នកជាប់ពន្ធយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងពេលធ្វើសវនកម្ម,
- រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញ ដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យមុនពេលចុះសវនកម្មកន្លងមក សម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ (ដូចជាការគោរពច្បាប់, កំហុសអចេតនា, ការអនុវត្តខុសពីច្បាប់, ការប្រកាសប្រាក់ពន្ធខ្វះ, ការគេចវេសពន្ធធ្ងន់ធ្ងរ។ល។),
- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម។

***វិធានការរយៈពេលមធ្យម:***

- បន្តធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រកំណត់ហានិភ័យរបស់ក្រុមហ៊ុន និងបង្កើតប្រព័ន្ធកុំព្យូទ័រវិភាគហានិភ័យដោយស្វ័យប្រវត្តិ,
- ពង្រឹងការទទួលព័ត៌មានអ្នកជាប់ពន្ធឱ្យមានលក្ខណៈស្វ័យប្រវត្តិពីអង្គភាពផ្ទៃក្នុង និងស្ថាប័នពាក់ព័ន្ធ,
- រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួនរួមមាន ធនាគារ, សំណង់, ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម,
- រៀបចំសារាចរណែនាំស្តីពីការផ្ទេរថ្លៃ (Transfer Pricing)។

### ៥.១.១.៥ ការប្រមូលបំណុលពន្ធ និងបណ្ដឹងតវ៉ា

៣៣. នាពេលកន្លងមក ចំណូលពីការប្រមូលបំណុលពន្ធមានការកើនឡើងជាលំដាប់ ដោយសារអគ្គនាយកដ្ឋានពន្ធដារចាត់វិធានការមួយចំនួន ដូចជា មិនអនុញ្ញាតឱ្យចុះបញ្ជីបង្កើតក្រុមហ៊ុនថ្មី, មិនអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិអចលនទ្រព្យ, ចុះផ្សាយឈ្មោះអ្នកជំពាក់បំណុលពន្ធនៅលើទំព័រសារព័ត៌មាន, សហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីកាត់ប្រាក់ទូទាត់បំណុលពន្ធ, សហការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីឃាត់ទុកទំនិញ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការឱ្យអ្នកជំពាក់បំណុលពន្ធមកទូទាត់បំណុលពន្ធ។

៣៤. ទោះជាចំណូលពីការប្រមូលបំណុលពន្ធមានការកើនឡើង ក៏ការប្រមូលបំណុលពន្ធជាបញ្ហាប្រឈមមួយសម្រាប់អគ្គនាយកដ្ឋានពន្ធដារ។ ប្រការនេះកើតមានឡើង ដោយសារមូលហេតុដូចតទៅ : (១)- ការមិនទាន់លុបចោលបំណុលពន្ធមួយចំនួន ដែលអ្នកជំពាក់បំណុលពន្ធបាត់ខ្លួនជាយូរឆ្នាំមកហើយ, (២)- ក្រុមហ៊ុនខ្លះដាក់លិខិតប្រកាស តែមិនបង់ប្រាក់ពន្ធ, (៣)- ការកំណត់ពន្ធជាឯកតោភាគី លើអ្នកជាប់ពន្ធមិនបានដាក់លិខិតប្រកាស, ការមិនរក្សាទុកបញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ និងការមិនសហការផ្ដល់ព័ត៌មានដល់សវនករពន្ធដារ, (៤)- បំណុលពន្ធដែលជំពាក់រយៈពេលយូរនាំឱ្យកើនឡើងនូវពិន័យពន្ធបន្ថែម និងការប្រាក់, (៥)- ការមិនទាន់អនុវត្តនូវវិធានការតឹងទារដែលមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធសារពើពន្ធ ដូចជា ការរឹបអូស, ការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ ឬការប្ដឹង អ្នកជំពាក់បំណុលពន្ធទៅតុលាការ និង (៦)- អ្នកជំពាក់បំណុលពន្ធភាគច្រើនអាចនឹងមិនបានដឹងអំពីនីតិវិធីប្ដឹងតវ៉ា ដែលកត្តានេះអាចនឹងបណ្ដាលឱ្យមានការពូនគរបំណុលពន្ធ។

៣៥. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- កំណត់គោលដៅប្រមូលបំណុលពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ និងអនុវត្តវិធានការតឹងទារចំពោះអ្នកជំពាក់បំណុលពន្ធធំៗ ដែលមិនតវ៉ា និងមានបំណុលពន្ធថ្មីៗ,
- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្ដីពីពន្ធដារ ដូចជា ការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្ដឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ,
- រៀបចំសៀវភៅណែនាំស្ដីពីការគ្រប់គ្រងប្រមូលបំណុលពន្ធ,
- កែប្រែប្រកាសស្ដីពីវិធាន និងនីតិវិធីនៃការដោះស្រាយបណ្ដឹងតវ៉ា។

## ៥.១.២ ការពង្រឹងមុខងារគាំទ្រ

៣៦. មុខងារគាំទ្រ គឺជាប្រភេទមុខងារពាក់ព័ន្ធការរៀបចំរចនាសម្ព័ន្ធចាត់តាំងការងារ និងការរៀបចំផែនការទូទៅរបស់អង្គភាព ដូចជា ផែនការគ្រប់គ្រងធនធានរួមទាំងធនធានជាសម្ភារៈឧបករណ៍បច្ចេកវិទ្យា និងធនធានមនុស្សដែលជាមុខងារគន្លឹះក្នុងការគាំទ្រ និងពង្រឹងប្រសិទ្ធភាពនៃការបំពេញមុខងារប្រតិបត្តិការស្នូល។ ការពង្រឹងមុខងារគាំទ្រ រួមមាន : (១)- ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ, (២)- ការគ្រប់គ្រងធនធានមនុស្ស និង (៣)- បច្ចេកវិទ្យាព័ត៌មាន។

### ៥.១.២.១ ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ

៣៧. ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ គឺជាការងារចាំបាច់សម្រាប់ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចប្រតិបត្តិការទូទៅ និងការប្រមូលពន្ធ។ នៅក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារបានកែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រង

ជាច្រើន ដែលរួមមានការបង្កើតការិយាល័យគ្រប់គ្រងប្រមូលពន្ធតាមរបបពិតនៅឆ្នាំ ១៩៩៤, អង្គភាពប្រមូលអាករលើតម្លៃបន្ថែមនៅឆ្នាំ ១៩៩៦, ការពង្រីករបបស្វ័យប្រកាសនៅទូទាំងប្រទេស និងការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំនៅឆ្នាំ ១៩៩៩ ។ នៅឆ្នាំ ២០០៥ នាយកដ្ឋានពន្ធដារបានកែទម្រង់រចនាសម្ព័ន្ធម្តងទៀត ដោយផ្តោតទៅលើចក្ខុវិស័យ, បេសកកម្ម, តួនាទី និងភារកិច្ច។ នៅឆ្នាំ ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមាននាយកដ្ឋានថ្នាក់កណ្តាលចំនួន ៧ សាខាពន្ធដារខណ្ឌនៅរាជធានីភ្នំពេញចំនួន ៧ និងសាខាពន្ធដារខេត្តចំនួន ២៣។

៣៨. ជាមួយនឹងវឌ្ឍនភាពខាងលើ កំណែទម្រង់នៅមិនទាន់គ្រប់គ្រាន់ និងមិនអាចឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងលឿនរបស់សេដ្ឋកិច្ចជាតិ, តម្រូវការរបស់អ្នកជាប់ពន្ធ និងការអភិវឌ្ឍនាថ្ងៃអនាគតនៅឡើយទេ។ អគ្គនាយកដ្ឋានពន្ធដារ ដែលការងាររបស់ខ្លួនមានចរិតលក្ខណៈជំនាញឯកទេសស្មុគស្មាញ ចាំបាច់ត្រូវបញ្ជាក់ និងផ្សព្វផ្សាយពីចក្ខុវិស័យរយៈពេលវែង និងកំណត់ពីគោលដៅជាក់លាក់មួយ ដើម្បីជំរុញឱ្យមានសង្គតិភាពនៃការរៀបចំរចនាសម្ព័ន្ធ និងការធ្វើផែនការ និងអនុវត្តយុទ្ធសាស្ត្រឱ្យស្របតាមចក្ខុវិស័យរយៈពេលវែង។ ជាមួយគ្នានេះនាយកដ្ឋានមួយចំនួនមិនទាន់មានការិយាល័យសំខាន់ៗ ដូចជា ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ, ការិយាល័យសវនកម្មផ្ទៃក្នុង, ការិយាល័យផ្តល់ព័ត៌មានតាមទូរស័ព្ទ, ការិយាល័យទំនាក់ទំនងសាធារណៈ និងការិយាល័យស្រាវជ្រាវ និងវិភាគប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

៣៩. សវនកម្មផ្ទៃក្នុងត្រូវបានទទួលស្គាល់ថាមានមុខងារសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យក្នុងស្ថាប័ន ហើយការធ្វើសវនកម្មផ្ទៃក្នុងនេះអាចជួយលើកកម្ពស់សេចក្តីថ្លៃថ្នូរជូនស្ថាប័ន និងផ្តល់ទំនុកចិត្តដល់អ្នកជាប់ពន្ធ។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានបង្កើតការិយាល័យត្រួតពិនិត្យនៅក្នុងនាយកដ្ឋានត្រួតពិនិត្យ ដែលមានតួនាទី និងភារកិច្ចដូចសវនកម្មផ្ទៃក្នុងដែរ ប៉ុន្តែការិយាល័យនេះមិនបានអនុវត្តមុខងារសវនកម្មផ្ទៃក្នុងប្រកបដោយបច្ចេកទេស និងស្តង់ដារ ហើយជាធម្មតា គឺមិនសូវមានសកម្មភាព។ កង្វះប្រសិទ្ធភាពក្នុងការធ្វើសវនកម្មផ្ទៃក្នុង, ការមិនទាន់អនុវត្តឱ្យបានពេញលេញនូវតួនាទី និងភារកិច្ចរបស់នាយកដ្ឋានត្រួតពិនិត្យ បានធ្វើឱ្យមានការលំបាកដល់ការពិនិត្យតាមដាន និងវាយតម្លៃប្រតិបត្តិការរបស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ។

៤០. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី:***

- កំណត់ និងផ្សព្វផ្សាយនូវចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារដល់គ្រប់មន្ត្រីពន្ធដារ និងសាធារណជន,
- ពិនិត្យឡើងវិញនូវផែនការប្រតិបត្តិរបស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ និងកំណត់គោលដៅអាទិភាព និងពេលវេលាសម្រេចបាន,
- កែសម្រួលរចនាសម្ព័ន្ធការងាររបស់អង្គភាពពន្ធដារនីមួយៗ និងបង្កើតការិយាល័យមួយចំនួនបន្ថែមទៀតនៅតាមនាយកដ្ឋានថ្នាក់កណ្តាល និងតាមសាខាពន្ធដារខេត្ត ដើម្បីដំណើរការការងារ និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព,

- បន្តពង្រឹង និងកែសម្រួលតួនាទី និងភារកិច្ចរបស់ការិយាល័យសវនកម្មផ្ទៃក្នុងនៃនាយកដ្ឋានត្រួត-ពិនិត្យ,
- បង្កើតគណៈកម្មការ/ក្រុមការងារគ្រប់គ្រងកំណែទម្រង់អចិន្ត្រៃយ៍ ដោយជ្រើសរើសមន្ត្រីដែលមានបទពិសោធន៍ រួមទាំងមានការផ្តល់ការលើកទឹកចិត្តឱ្យបានសមរម្យ,
- បង្កើតការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារក្នុងនាយកដ្ឋានត្រួតពិនិត្យ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ,
- រៀបចំនីតិសម្បទាជូនមន្ត្រីពន្ធដារជានគរបាលយុត្តិធម៌។

*វិធានការរយៈពេលមធ្យម:*

- បន្តរៀបចំកែលម្អរចនាសម្ព័ន្ធ និងបង្កើតនាយកដ្ឋាន និងការិយាល័យថ្មីមួយចំនួនតាមការចាំបាច់របស់អគ្គនាយកដ្ឋានពន្ធដារ,
- រៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន។

### ៥.១.២.២ ការគ្រប់គ្រងធនធានមនុស្ស

៤១. ការគ្រប់គ្រងធនធានមនុស្ស គឺជាការងារស្នូលដែលអគ្គនាយកដ្ឋានពន្ធដារបានខិតខំយកចិត្តទុកដាក់អនុវត្តតាមរយៈការជ្រើសរើសមន្ត្រីបន្ថែម, ការបណ្តុះបណ្តាលមន្ត្រីនៅក្នុង និងក្រៅប្រទេស, ការរៀបចំវិន័យ និងក្រមសីលធម៌មន្ត្រី, ការពង្រឹងវិជ្ជាជីវៈ, ការដាក់ទោសទណ្ឌមន្ត្រីប្រព្រឹត្តខុស។ល។ ដើម្បីគ្រប់គ្រងធនធានមនុស្សឱ្យបានកាន់តែប្រសើរ។ ជាមួយនឹងគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស ដោយផ្តោតលើការជ្រើសរើសមន្ត្រីថ្មី, ការបណ្តុះបណ្តាលមន្ត្រី, ការធ្វើផែនការអំពីចំនួនមន្ត្រីសម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត, វិន័យ និងក្រមសីលធម៌, ការគ្រប់គ្រងស្ថិតិមន្ត្រី, អត្រាបែងចែកមន្ត្រីតាមសក្តានុពលរបស់ចំណូល និងអត្រាបាត់បង់មន្ត្រី។

៤២. ក្នុងខណៈដែលអគ្គនាយកដ្ឋានពន្ធដារកំពុងរៀបចំឱ្យមានយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស អគ្គនាយកដ្ឋានជួបបញ្ហាប្រឈមមួយចំនួននាពេលបច្ចុប្បន្ននេះ ដូចជា : (១)- មន្ត្រីដែលមានជំនាញ និងបទពិសោធន៍ច្រើនមានចំនួនតិច និងត្រូវបានចាត់តាំងឱ្យទទួលបន្ទុកកិច្ចការជាច្រើន ដែលមិនមែនជាភារកិច្ចចម្បងរបស់ខ្លួន ដូចជាការរៀបចំគោលនយោបាយសារពើពន្ធ និងកិច្ចការបន្ទាន់ផ្សេងៗ ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ, (២)- មន្ត្រីមួយភាគធំនៅតាមសាខាពន្ធដារខណ្ឌ-ខេត្តត្រូវបានចាត់តាំងឱ្យប្រមូលចំណូលពន្ធតូចៗ រីឯប្រភេទចំណូលពន្ធធំៗវិញ គឺមានចំនួនមន្ត្រីទទួលបន្ទុកនៅមានកម្រិត ដែលបញ្ហាប្រឈមនេះនឹងមានភាពស្មុគស្មាញកាន់តែខ្លាំងនៅពេលមានការកែប្រែការប្រមូលពន្ធតាមរបបម៉ៅការមកជារបបស្វ័យប្រកាស, ការកើនឡើងអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងការកើនឡើងចំនួនសហគ្រាសថ្មី និង (៣)- ការធ្វើសនិទានកម្មលើរង្វាន់លើកទឹកចិត្តនាពេលបច្ចុប្បន្ន ដែលផ្តល់ជូនមន្ត្រីពន្ធដារគ្រប់រូបមិនបានបែងចែកកម្រិតនៃប្រាក់រង្វាន់ ដោយផ្អែកលើលទ្ធផលការងាររបស់មន្ត្រីម្នាក់ៗនៅឡើយ។

៤៣. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- បញ្ចប់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស,

- ធ្វើសនិទានកម្មរបបរង្វាន់លើកទឹកចិត្ត ដែលត្រូវផ្អែកលើលទ្ធផលការងារជាមូលដ្ឋាន, បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពន្ធដារគ្រប់កម្រិត និងកែលម្អកម្មវិធីសិក្សារបស់សាលាជាតិពន្ធដារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង,
- ធ្វើការជ្រើសរើសមន្ត្រីពន្ធដារឱ្យបានឆាប់រហ័សស្របតាមតម្រូវការជាក់ស្តែងរបស់អង្គភាពពន្ធដារនីមួយៗ,
- បញ្ចប់ការរៀបចំលក្ខខណ្ឌការងារ និងការទទួលខុសត្រូវលើមុខងារនីមួយៗ និងទម្រង់វាយតម្លៃលទ្ធផលការងាររបស់មន្ត្រីរាជការពន្ធដារតាមឋានានុក្រម,
- បញ្ចប់សេចក្តីព្រាងស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ និងរៀបចំសេចក្តីណែនាំស្តីពីវិន័យ និងការដាក់ទណ្ឌកម្ម ដែលបញ្ជាក់អំពីនីតិវិធីអនុវត្តច្បាស់លាស់,
- រៀបចំបទដ្ឋានគោលការណ៍ឱ្យបានច្បាស់លាស់សម្រាប់ការផ្លាស់ប្តូរមន្ត្រី,
- រៀបចំគម្រោងចំណាយថវិការបស់អង្គភាពពន្ធដារ ដើម្បីទទួលបានថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់គាំទ្រការអនុវត្តការងារប្រមូលចំណូលពន្ធ និងការកែទម្រង់ពន្ធដារឱ្យមានប្រសិទ្ធភាព។

### ៥.១.២.៣ បច្ចេកវិទ្យាព័ត៌មាន

៤៤. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈទំនើបមានសារៈសំខាន់ក្នុងការគាំទ្រដល់ការងារចុះបញ្ជីអ្នកជាប់ពន្ធ, សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការគ្រប់គ្រងបំណុលពន្ធ និងការសន្សំពេលវេលា តាមរយៈការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យ និងចំនួនមន្ត្រីតាមរយៈការផ្លាស់ប្តូរពីការងារ ដែលប្រតិបត្តិដោយដៃ មកជាការប្រតិបត្តិដោយប្រព័ន្ធកុំព្យូទ័រ។ ដោយយល់ដឹងអំពីផលប្រយោជន៍នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អគ្គនាយកដ្ឋានពន្ធដារបានខិតខំធ្វើបច្ចុប្បន្នកម្មព័ត៌មានថ្មីៗលើគេហទំព័រ និងផ្លាស់ប្តូរបង្កាន់ដៃ ដែលធ្លាប់សរសេរដោយដៃមកជាលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធបោះពុម្ពចេញដោយកុំព្យូទ័រ (ពន្ធរបបស្វ័យប្រកាស, ពន្ធរបបម៉ៅការ និងពន្ធលើអចលនទ្រព្យ)។ ជាមួយគ្នានេះអគ្គនាយកដ្ឋានពន្ធដារបានដំឡើងបណ្តាញតភ្ជាប់តំបន់ទូលាយ (Wide Area Network-WAN) ដើម្បីបញ្ជូនព័ត៌មាន និងទិន្នន័យអ្នកជាប់ពន្ធពីសាខាពន្ធដារខណ្ឌចំនួន ៧ (ជំហានទី១) និងខេត្តចំនួន ១៦ (ជំហានទី២) មកប្រមូលផ្តុំនៅអគ្គនាយកដ្ឋានពន្ធដារ។

៤៥. ទោះជាមានវឌ្ឍនភាពដូចនេះក៏ដោយ អគ្គនាយកដ្ឋានពន្ធដារនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ការគ្រប់គ្រងប្រតិបត្តិការប្រមូលចំណូលពន្ធដារតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងមុខងារគ្រប់គ្រងព័ត៌មាននៅមានកម្រិតទាប និងមិនទាន់បានធ្វើទំនើបភាវូបនីយកម្ម និងស្វ័យប្រវត្តិកម្មនៅឡើយ, (២)- មិនទាន់មានផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានសម្រាប់ដំឡើងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពន្ធដារមួយ ដែលមានលក្ខណៈទំនើប និងស្វ័យប្រវត្តិកម្ម, (៣)- មន្ត្រីនៅនាយកដ្ឋានព័ត៌មានវិទ្យាមានចំនួនតិច និង (៤)- តម្រូវការធនធានសម្រាប់ការវិនិយោគលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មី នៅមិនទាន់មានការវាយតម្លៃ និងសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ។

៤៦. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

*វិធានការរយៈពេលខ្លី :*

- ជ្រើសរើសបន្ថែមនូវមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មានគ្រប់អង្គភាពពន្ធដារទាំងអស់ ដើម្បីគាំពារដល់ផែនការទំនើបភាវូបនីយកម្ម និងស្វ័យប្រវត្តិកម្មពន្ធដារ,
- បញ្ចប់ការរៀបចំបណ្តាញតភ្ជាប់តំបន់ទូលាយ (WAN) តាមលក្ខណៈបច្ចេកទេសពីសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់មកកាន់អគ្គនាយកដ្ឋានពន្ធដារ,
- រៀបចំ និងអនុវត្តការដាក់លិខិតប្រកាសពន្ធតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

*វិធានការរយៈពេលមធ្យម :*

- រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានពន្ធដារតាមដំណាក់កាលនៃការអនុវត្ត, តម្រូវការរបស់អ្នកប្រើប្រាស់ និងតម្រូវការធនធានសម្ភារៈបរិក្ខារ និងរៀបចំផែនការធ្វើលទ្ធកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយផ្អែកទៅតាមផែនការយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការងារសេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម និងការគ្រប់គ្រងបំណុលពន្ធ។

## ៥.២ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

**៤៧.** អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលជាអង្គភាពមួយក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីកែទម្រង់ និងទំនើបកម្មគយប្រាំឆ្នាំ ចំនួន ៣ លើក រួចមកហើយ ដើម្បីពង្រឹងរដ្ឋបាលគយទាំងផ្នែករចនាសម្ព័ន្ធ, ជំនាញវិជ្ជាជីវៈ និងនីតិវិធីប្រតិបត្តិការ ក្នុងគោលបំណងកៀរគរចំណូលឱ្យអស់លទ្ធភាព និងប្រែក្លាយជាអង្គភាពបម្រើសេវាយ៉ាងមានប្រសិទ្ធភាព។

**៤៨.** តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ និងទំនើបកម្មគយកន្លងមកនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាសម្រេចបានសមិទ្ធផលនៃការប្រមូលចំណូលគួរជាទីពេញចិត្ត ទោះបីជាមូលដ្ឋានពន្ធនៅមានលក្ខណៈតូចចង្អៀត ជាពិសេសដោយពឹងផ្អែកតែទៅលើទំនិញនាំចូលមួយចំនួនដូចជា យានយន្ត, ផលិតផលប្រេងឥន្ធនៈ, បារី, សម្ភារៈសំណង់ និងឧបករណ៍អគ្គិសនី ជាដើម។ ចំណូលដែលប្រមូលបានជាក់ស្តែងតែងតែសម្រេចបានតាមគោលដៅ និងផែនការ ដែលបានកំណត់ហើយបានរួមចំណែកច្រើនជាងពាក់កណ្តាលនៃចំណូលពន្ធសរុប។ ចំណូលពន្ធអាករគយជាមធ្យមប្រចាំឆ្នាំសម្រេចបានប្រមាណជា ៦% នៃ ផសស ជាមួយនឹងអត្រាកំណើនជាង ១០% ក្នុង ១ ឆ្នាំ (រូបភាព៤)។ ជាមួយការអនុវត្តផែនការប្រតិបត្តិគ្រប់ជ្រុងជ្រោយរយៈពេល ៦០ ថ្ងៃ ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០១៣ ដែលឆ្លើយតបនឹងអនុសាសន៍របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងគោលដៅបង្កើនចំណូលបន្ថែម, ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ និងកែលម្អអភិបាលកិច្ចគយ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាសម្រេចបាននូវការប្រមូលចំណូលសរុបចំនួន ៣.៩៥៥ ពាន់លានរៀល ឬ ៦,៤៥% នៃ ផសស ក្នុងឆ្នាំ ២០១៣។

**៤៩.** ទំនិញនាំចូលសំខាន់ៗដែលរួមចំណែកមួយផ្នែកធំដល់ចំណូលពន្ធអាករគយរួមមាន ផលិតផលតេលសិលា, យានយន្ត, បារី និងគ្រឿងសំណង់។ ចំណូលពីការនាំចូលផលិតផលតេលសិលា និងយានយន្តជាចំណូលខ្ពស់ជាងគេក្នុងអត្រាជាង ៤% នៃ ផសស និងប្រមាណជា ៦២% នៃចំណូលពន្ធអាករគយសរុប។ ចំណូលពន្ធអាករគយសំខាន់បន្ទាប់ គឺចំណូលពីការនាំចូលបារី និងគ្រឿងសំណង់ ដែលបានរួមចំណែកដល់ចំណូលពន្ធគយជាមធ្យមប្រមាណ ០,៤% និង ០,២% នៃ ផសស ក្នុង ១ ឆ្នាំ។ សម្រាប់ចំណូលតាមប្រភេទពន្ធ ចំណូលពីអាករលើតម្លៃបន្ថែមមានកម្រិតខ្ពស់ជាងគេក្នុងអត្រាមធ្យម ២,២% នៃ ផសស (៣៦% នៃចំណូលពន្ធគយសរុប) សម្រាប់ឆ្នាំ ២០០៧-

២០១២ និងរួមចំណែកជាបន្តបន្ទាប់ដោយចំណូលពីអាករពិសេស (១,៦% នៃ ផសស), ចំណូលពីពន្ធពាណិជ្ជកម្មអន្តរជាតិនាំចូល (១,១% នៃ ផសស) និងចំណូលពីការនាំចេញ (០,១% នៃ ផសស)។

៥០. ទន្ទឹមនេះ អគ្គនាយកដ្ឋានក៏សម្រេចបាននូវវឌ្ឍនភាពលើការកែលម្អផ្នែករដ្ឋបាលពន្ធគយគួរឱ្យកត់សម្គាល់។ ការធ្វើសវនកម្មក្រោយការបញ្ចេញទំនិញពីគយ ត្រូវបានពង្រីកវិសាលភាពរបស់ខ្លួនបន្ថែម។ អង្គភាពគ្រប់គ្រងព័ត៌មានសម្ងាត់គយត្រូវបានបង្កើតឡើងនៅទីស្នាក់ការកណ្តាល ដើម្បីប្រមូលព័ត៌មានសម្រាប់ការគ្រប់គ្រងហានិភ័យ។ លើសពីនេះទៀត អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឈានទៅសម្រេចបានទាំងស្រុងនូវការផ្ទៀងផ្ទាត់តម្លៃពន្ធគយ ដែលអនុលោមទៅតាមកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ក្នុងឆ្នាំ ២០១២ នីតិវិធីគយកម្ពុជា ត្រូវបានវាយតម្លៃថាអនុលោមស្ទើរតែទាំងស្រុងទៅនឹងពិធីសារនៃវិសោធនកម្មអនុសញ្ញាអន្តរជាតិស្តីពីសាមញ្ញកម្ម និងសុខដុមនីកម្មគយ ហើយនៅឆ្នាំ ២០១៤ នេះ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាភាគីហត្ថលេខីនៅក្នុងពិធីសារនេះ។

**រូបភាព ៤: ចំណូលពន្ធ និងអាកររបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ជាភាគរយនៃ ផសស)**




ប្រភព: អគ្គនាយកដ្ឋានរតនាគារជាតិ

**៥១.** ទន្ទឹមនឹងវឌ្ឍនភាពដ៏ច្រើននេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការកៀរគរចំណូលពន្ធអាករគយបន្ថែមទៀត។ បញ្ហាប្រឈមមួយចំនួនក្នុងផ្នែករដ្ឋបាលគយរួមមាន : ការរត់គេចពន្ធ, ភាពមានកម្រិតនៃការអនុវត្តនីតិវិធីគយ, មុខងារប្រមូល និងវិភាគព័ត៌មានសម្ងាត់គយ, ការគ្រប់គ្រងហានិភ័យ, ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ។ល។ ទាក់ទងនឹងគោលនយោបាយពន្ធគយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាក៏នៅមានបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ប្រភពចំណូលដ៏សំខាន់របស់ជាតិត្រូវបានផ្លាស់ប្តូរពីការពឹងផ្អែកលើចំណូលពន្ធអាករគយមកជាចំណូលពន្ធក្នុងស្រុក ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយសមាជិកអាស៊ាន និងដៃគូពាណិជ្ជកម្មផ្សេងទៀត, (២)- ការលើកលែងពន្ធ និងអាករ ដោយការអនុវត្តគោលនយោបាយលើកទឹកចិត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, (៣)- ភាពមានកម្រិតនៃចំណូលអាករពិសេស ពីការនាំចូលដោយសារអត្រាអាករពិសេសនៅកម្ពុជានៅមានកម្រិតទាបធៀបនឹងប្រទេសក្នុងតំបន់, (៤)- ការផលិតក្នុងស្រុកជំនួសឱ្យការនាំចូល និង (៥)- ការប្រើប្រាស់តម្លៃជាមូលដ្ឋានសម្រាប់កំណត់ពន្ធមិនមានបច្ចុប្បន្នភាពគ្រប់គ្រាន់តាមការប្រែប្រួលតម្លៃទីផ្សារ។ ទន្ទឹមនេះ ការត្រួតពិនិត្យ ឬអភិបាលកិច្ចគយក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា ផែនការអភិវឌ្ឍន៍ស្ថាប័នរយៈពេលវែង, ការពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយឱ្យបានទៀងទាត់, ការគ្រប់គ្រងធនធានមនុស្ស និងសវនកម្មផ្ទៃក្នុងមិនបានដំណើរការពេញលេញតាមបទប្បញ្ញត្តិជាធរមាន។

៥២. ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលមានរៀបរាប់ខាងលើ ការពង្រឹងរដ្ឋបាលគយ និងរដ្ឋាករនឹងផ្តោតទៅលើ : (១)- ការពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញ, (២)- ការពង្រឹងយន្តការឆ្លងកាត់ និង (៣)- ការពង្រឹងយន្តការគាំទ្រ។

### ៥.២.១ ការពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញ

៥៣. ការពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញនឹងផ្តោតទៅលើ ៣ ចំណុចធំៗគឺ : (១)- ការប្រកាសគយ, (២)- ការកំណត់ និងធ្វើចំណាត់ថ្នាក់ទំនិញ និង (៣)- ការធ្វើសវនកម្មក្រោយការបញ្ចេញទំនិញពីគយ។

#### ៥.២.១.១ ការប្រកាសគយ

*ក. ការគ្រប់គ្រងឯកសារនាំចេញ-នាំចូល*

៥៤. យោងតាមឧត្តមានុវត្តន៍អន្តរជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាគួរទទួលបានព័ត៌មានរបស់ទំនិញនាំចូលដូចជាឈ្មោះក្រុមហ៊ុននាំចូល, ប្រភេទទំនិញ, បរិមាណ, ទម្ងន់ និងលេខកុងតឺន័រពីក្រុមហ៊ុនដឹកជញ្ជូនមុនពេលទំនិញមកដល់ ដើម្បីទុកសម្រាប់ធ្វើការផ្ទៀងផ្ទាត់។ ក្រោយពេលទំនិញមកដល់ផែ ឯកសារនាំចូល ដូចជា ឯកសារដឹកជញ្ជូន, វិក្កយបត្រទំនិញ និងបញ្ជីវេចខ្ចប់ ត្រូវផ្តល់ជូនមន្ត្រីគយសម្រាប់ធ្វើការត្រួតពិនិត្យ។ ជាកិច្ចផ្តួចផ្តើមនៃការគ្រប់គ្រងឯកសារនាំចេញ-នាំចូលឱ្យមានប្រសិទ្ធិភាព អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងនិវេទន៍បណ្ណជាស្វ័យប្រវត្តិសាកល្បងនៅកំពង់ផែស្វយ័តភ្នំពេញកាលពីឆ្នាំ ២០១២ កន្លងទៅ ដែលជាដំណាក់កាលទី ១ នៃការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ។

៥៥. ទោះបីជាមានការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងនិវេទន៍បណ្ណជាស្វ័យប្រវត្តិ ការគ្រប់គ្រងឯកសារនាំចេញ-នាំចូលក៏នៅមានបញ្ហាប្រឈមលើភាពមិនស៊ីគ្នា ឬលម្អៀងរវាងទំនិញនាំចូលពិតប្រាកដ និងព័ត៌មានទំនិញ ដែលបានប្រកាស។ ក្នុងករណីខ្លះ វិក្កយបត្រទំនិញពុំមានបញ្ជាក់ពីព័ត៌មានអប្បបរមាច្បាស់លាស់តាមប្រភេទពាណិជ្ជកម្មទាក់ទងនឹងយថាប្រភេទទំនិញ និងវិក្កយបត្រច្បាប់ចម្លង ក៏ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការបំពេញបែបបទគយឱ្យបានឆាប់រហ័ស។ ដូច្នេះ លទ្ធភាពក្នុងការក្លែងបន្លំឯកសារនាំចូលអាចនឹងមានកម្រិតខ្ពស់ ដែលឈានទៅដល់ការប្រកាសទំនិញខុសលើតម្លៃ, បរិមាណ និងប្រភេទទំនិញ។ លើសពីនេះ នៅច្រកព្រំដែនខ្លះ មន្ត្រីគយមិនបានទទួលព័ត៌មានទំនិញនាំចូលពីក្រុមហ៊ុនដឹកជញ្ជូនមុនពេលទំនិញមកដល់ និងខ្លះបានទទួលព័ត៌មានដែរ តែមិនបានគ្រប់ជ្រុងជ្រោយ និងជាប្រចាំ ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងព័ត៌មានដែលបានប្រកាសឡើយ។ ទន្ទឹមនឹងនោះ ក្នុងករណីខ្លះភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" ដែលតែងតែទទួលបានឯកសារដឹកជញ្ជូនច្បាប់ដើមមុន មិនបានផ្តល់ឯកសារនេះជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាទាន់ពេលវេលា។ ជាមួយគ្នានេះ បញ្ហាប្រឈមមួយទៀត គឺក្រុមហ៊ុនមួយចំនួនបានឆ្លៀតប្រើឈ្មោះរបស់ខ្លួនជាជើងសាគយផង និងជាក្រុមហ៊ុននាំចូលផងតាមបទប្បញ្ញត្តិជាធរមាន ដោយមិនបានប្រើប្រាស់ឈ្មោះក្រុមហ៊ុន ដែលធ្វើការនាំចូលពិតប្រាកដ។

៥៦. បន្ថែមលើនេះ ការក្លែងបន្លំឯកសារដឹកជញ្ជូនមួយចំនួនលើទំនិញឆ្លងកាត់តាមប្រទេសជិតខាង ក៏នៅតែជាបញ្ហា ដោយសារកង្វះប្រសិទ្ធភាពនៃការអនុវត្តមុខងារត្រួតពិនិត្យទំនិញឆ្លងកាត់របស់គយ, នត្ថិភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រយន្តការប្រកាសទំនិញដោយស្វ័យប្រវត្តិ, ភាពមិនដំណើរការនៃយន្តការទទួលព័ត៌មានទំនិញមុនពេលមកដល់ និងការពន្យារពេលនៃការផ្លាស់ប្តូរព័ត៌មានជាមួយប្រទេសជិតខាង បើទោះជាអនុស្សារណៈយោគយល់គ្នាត្រូវបានចុះហត្ថលេខារួចហើយក្តី។

៥៧. ដើម្បីដោះស្រាយបញ្ហាទាំងអស់ខាងលើ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

*វិធានការរយៈពេលខ្លី :*

- កំណត់ទិន្នន័យអប្បបរមា ដែលត្រូវមានលើវិក្កយបត្រពាណិជ្ជកម្មក្នុងទម្រង់ជាក់លាក់តាមបទប្បញ្ញត្តិជាធរមាន,
- ពង្រឹងប្រព័ន្ធប្រកាសពន្ធគយដោយស្វ័យប្រវត្តិ តាមរយៈការតភ្ជាប់ទៅវិញទៅមកជាមួយនឹងប្រព័ន្ធរបស់សហគមន៍កំពង់ផែ,
- ពង្រឹងប្រសិទ្ធភាពនៃការផ្ទៀងផ្ទាត់សង្គតិភាពនិងអនុលោមភាពនៃឯកសារនាំចេញ-នាំចូល,
- រៀបចំកិច្ចប្រជុំរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" ដើម្បីរៀបចំសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នាលើនីតិវិធីគ្រប់គ្រង និងទទួលឯកសារដឹកជញ្ជូនដែលត្រឹមត្រូវ និងទាន់ពេលវេលា,
- ពង្រឹងយន្តការគ្រប់គ្រងក្រុមហ៊ុនជើងសាគយ និងធ្វើការព្រមាន និងដាក់ទោសទណ្ឌជាទៀងទាត់តាមច្បាប់ជាធរមានចំពោះបុគ្គលផ្តល់សេវាកម្មជើងសាគយ ដែលពុំមាននីតិសម្បទាជាជើងសាគយ។

*វិធានការរយៈពេលមធ្យម :*

- រៀបចំនិងដាក់ឱ្យអនុវត្តនូវនីតិវិធីបញ្ចេញទំនិញពីគយមុនពេលទំនិញមកដល់,
- បង្កើតនិងអនុវត្តម៉ូឌុលត្រួតពិនិត្យទំនិញឆ្លងកាត់ក្នុងប្រព័ន្ធអាស៊ីគូដា,
- ដាក់ឱ្យអនុវត្តអនុស្សារណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" លើការគ្រប់គ្រងការទទួលឯកសារដឹកជញ្ជូនត្រឹមត្រូវ និងទាន់ពេលវេលា។

### *ខ. ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ*

៥៨. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានធ្វើវិមជ្ឈការនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនៅតាមអង្គភាពគយ និងរដ្ឋាករមូលដ្ឋានក្នុងបណ្តាខេត្តនានានៅតាមព្រំដែន (ការផ្តល់សិទ្ធិនេះ គឺមានកម្រិតកំណត់សម្រាប់ទំនិញចេញ-ចូលតាមច្រកកំពង់ផែក្រុងព្រះសីហនុ) ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តតម្លៃគិតពន្ធគយតាមតម្លៃចម្លងការហើយត្រូវបានអនុវត្តជាជំហានៗ ស្របពេលនឹងយន្តការគាំទ្រអនុលោមភាពផ្សេងទៀតត្រូវបានពង្រឹងផងដែរ។ ជំហានបន្ទាប់ គឺការបន្តពង្រីកការធ្វើវិមជ្ឈការនេះឱ្យគ្របដណ្តប់គ្រប់អង្គភាពគយ និងរដ្ឋាករមូលដ្ឋានទាំងអស់ និងការពង្រឹងនីតិវិធីនៃការផ្ទៀងផ្ទាត់ចំណាត់ថ្នាក់ និងដើមកំណើតទំនិញ។ លើសពីនេះ ក្រុមផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយត្រូវបានបង្កើតឡើង និងមានតួនាទីបញ្ជាក់ពីភាពត្រឹមត្រូវនៃតម្លៃគិតពន្ធ និងគណនាបរិមាណប្រាក់ពន្ធអាករគយ ដែលត្រូវបង់ដោយផ្អែកលើប្រព័ន្ធទិន្នន័យវាយតម្លៃគយ ដែលបានធ្វើបច្ចុប្បន្នកម្មទៀងទាត់ផ្អែកលើព័ត៌មានពីប្រភពផ្សេងៗ។

៥៩. ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយក៏នៅជួបបញ្ហាប្រឈម ដោយហេតុថាការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយអាចធ្វើឡើងដោយផ្អែកលើប្រព័ន្ធទិន្នន័យតម្លៃទំនិញ ដែលមិនបានធ្វើបច្ចុប្បន្នកម្មជាប្រចាំឱ្យស្របតាមតម្លៃទីផ្សារ។ ម្យ៉ាងទៀត ទិន្នន័យវាយតម្លៃពន្ធគយនេះ គឺមានលក្ខណៈពាក់កណ្តាលស្វ័យប្រវត្តិនៅឡើយ។

៦០. ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- ពង្រីក និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយឱ្យស្របតាមតម្លៃទិញលក់ពិតរាល់ដំណាច់ត្រីមាសតាមបទប្បញ្ញត្តិជាធរមានដោយធ្វើ ៣ ជំពូក ក្នុង ១ ត្រីមាស,
- ពិនិត្យលទ្ធភាពធ្វើមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំពោះមុខទំនិញវេទយិតលើចំណូលពន្ធគយមួយចំនួនវិញ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូលចំណូលពន្ធគយ។

***វិធានការរយៈពេលមធ្យម :***

- ធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយលើទំនិញ ដែលមិនមានវេទយិតភាពលើចំណូលពន្ធអាករគយឱ្យទៅការិយាល័យគយទូទាំងខេត្ត-ក្រុង ក្រោយពេលប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយត្រូវបានធ្វើបច្ចុប្បន្នកម្ម។

### ៥.២.១.២ ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ

*ក. ការគ្រប់គ្រងហានិភ័យ*

**៦១.** ការគ្រប់គ្រងហានិភ័យត្រូវបានរៀបចំឡើង និងដាក់ឱ្យប្រើប្រាស់ ដើម្បីជំរុញដល់កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការកាត់បន្ថយការត្រួតពិនិត្យ ដែលមិនចាំបាច់ និងកាត់បន្ថយពេលវេលាត្រួតពិនិត្យ និងបញ្ចេញទំនិញនៅកំពង់ផែ ដោយធ្វើចំណាត់ថ្នាក់ហានិភ័យលើទំនិញនាំចូលជា ៤ ច្រកដូចជា ច្រកក្រហម (ពិនិត្យឯកសារ និងពិនិត្យជារូបវន្ត), ច្រកលឿង (ពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារ), ច្រកខៀវ និងច្រកបៃតង (ធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ)។

**៦២.** អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការងារគ្រប់គ្រងហានិភ័យ។ ប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយ ដែលប្រើសម្រាប់បង្កើតកម្រិត និងប៉ារ៉ាម៉ែត្រហានិភ័យទំនិញនាំចូលត្រូវបានដាក់ឱ្យដំណើរការ និងពង្រីកវិសាលភាពនៃការប្រើប្រាស់ទៅសាខាគយចំនួន ៥។ ព័ត៌មានរបស់ធុរជន, ជើងសាគយ និងបុគ្គលពាក់ព័ន្ធផ្សេងៗទៀត ដែលមានហានិភ័យខ្ពស់ ត្រូវបានធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន។ បន្ថែមពីលើនេះ ក៏មានការពិនិត្យបញ្ជាក់ពីហានិភ័យនៃទំនិញឆ្លងកាត់មួយចំនួនផងដែរ។ យោងតាមផែនការគ្រប់ជ្រុងជ្រោយរយៈពេល ៦០ ថ្ងៃ ប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយត្រូវបានដំឡើងបន្ថែមទៀតនាចុងឆ្នាំ ២០១៣ នៅមាត់ច្រកផ្លូវគោកចំនួន ២ គឺត្រពាំងស្រែ និងត្រពាំងផ្លុង។

**៦៣.** ជាមួយនឹងវឌ្ឍនភាពខាងលើ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៅជួបប្រទះបញ្ហាប្រឈមមួយចំនួនផងដែរ គឺ : (១)- ការពិនិត្យជារូបវន្តមិនចាំបាច់មួយចំនួននៅតែបន្តធ្វើ ដោយសារតែកង្វះប្រសិទ្ធភាពនៃការអនុវត្តមុខងារគ្រប់គ្រងហានិភ័យក្នុងការកំណត់ពណ៌ច្រក។ ជាលទ្ធផលនៅឆ្នាំ ២០១៣ ទំនិញមួយចំនួនធំប្រមាណ ១២% នៃឯកសាររដ្ឋបាលតែមួយទាំងអស់ត្រូវបានចាត់ថ្នាក់ទៅក្នុងច្រកពណ៌ក្រហម ដែលទាមទារឱ្យមានការពិនិត្យជារូបវន្ត ប៉ុន្តែស្ទើរតែមិនអាចរកឃើញករណីមិនប្រក្រតីទៅវិញ ដែលបង្ហាញថាប្រព័ន្ធគ្រប់គ្រងហានិភ័យបច្ចុប្បន្នមានលក្ខណៈបង្ការជាជាងលក្ខណៈបង្ក្រាប និង (២)- ការកែសម្រួលទិន្នន័យនិវេទន៍បណ្ណមិនបានគ្រប់ជ្រុងជ្រោយ, ការមិនបានធ្វើបច្ចុប្បន្នកម្មព័ត៌មានធុរជនឱ្យបានពេញលេញ, ការវិភាគហានិភ័យមិនបានគ្រប់គ្រាន់ និងភាពមានកម្រិតនៃមុខងារវិភាគព័ត៌មានសម្ងាត់គយ។

៦៤. ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងហានិភ័យឱ្យបានប្រសើរ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ហានិភ័យ និងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយដោយរក្សាឱ្យបាននូវការសម្ងាត់វិជ្ជាជីវៈ,
- ដំឡើងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយបន្ថែមទៀតនៅតាមការិយាល័យគយនានា,
- អង្កេត និងវាយតម្លៃសូចនាករហានិភ័យរបស់ធុរជនបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជននិងធ្វើបច្ចុប្បន្នកម្មឱ្យបានទៀងទាត់,
- កែសម្រួលកម្រិតហានិភ័យនៃមុខទំនិញក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់តាមរយៈការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់។

*ខ. ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ*

៦៥. ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយត្រូវបានរៀបចំ និងប្រើប្រាស់ក្នុងការធ្វើបច្ចុប្បន្នកម្មសូចនាករហានិភ័យថ្មីៗ ដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ហានិភ័យ និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធអាស៊ីគូដា។ បន្ទាប់មកប្រព័ន្ធអាស៊ីគូដានឹងផ្តល់សញ្ញាជាពណ៌ច្រកត្រឡប់ទៅឱ្យប្រព័ន្ធគ្រប់គ្រងហានិភ័យ និងផ្តល់របាយការណ៍ទៅកាន់ច្រកព្រំដែនគយនានា។

៦៦. ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ តាមរយៈការអនុវត្តគំនិតផ្តួចផ្តើមនានា ដូចជា កិច្ចព្រមព្រៀងទ្វេភាគីជាមួយសមភាគីគយរបស់ប្រទេសក្នុងតំបន់, ការបង្កើតជនបង្គោលសម្រាប់ការដោះដូរព័ត៌មានសម្ងាត់គយ និងជំនួយពីសំណាក់ដៃគូអភិវឌ្ឍន៍ទ្វេភាគី និងអង្គការអន្តរជាតិ និងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពគយនៃបណ្តាប្រទេសជាសមាជិកអាស៊ានផ្សេងទៀត។

៦៧. ជាមួយនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ខាងលើ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយក៏នៅមានបញ្ហាប្រឈមមួយចំនួន ដោយប្រព័ន្ធនេះមិនទាន់អាចបំពេញមុខងារប្រតិបត្តិទាំងស្រុង ដោយសារអង្គភាពគ្រប់គ្រងប្រព័ន្ធនេះនៅជួបប្រទះបញ្ហាកង្វះបុគ្គលិក និងសមត្ថភាពជំនាញផងដែរ។

៦៨. ដើម្បីឱ្យមុខងារគ្រប់គ្រងព័ត៌មានសម្ងាត់គយដំណើរការប្រកបដោយប្រសិទ្ធភាព អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- ប្រមូលទិន្នន័យចាំបាច់ពីគ្រប់ប្រភពទាំងអស់ ដើម្បីធ្វើការគ្រប់គ្រងព័ត៌មានសម្ងាត់គយឱ្យមានប្រសិទ្ធភាព,
- បង្កើនចំនួនមន្ត្រីគ្រប់គ្រងព័ត៌មានសម្ងាត់គយនៅគ្រប់សាខា ឬការិយាល័យគយ និងអនុវត្តមុខងារគ្រប់គ្រងព័ត៌មានសម្ងាត់គយឱ្យបានពេញលេញ។

***វិធានការរយៈពេលមធ្យម :***

- កសាង និងអនុវត្តផែនការសកម្មភាពជាលក្ខណៈប្រព័ន្ធសម្រាប់ការគ្រប់គ្រងព័ត៌មានសម្ងាត់គយដោយមានការតភ្ជាប់ជាមួយនឹងស្ថាប័នពាក់ព័ន្ធ។

### ៥.២.១.៣ សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ

**៦៩.** សវនកម្មលើប្រតិវេទន៍គយត្រូវបានប្រើប្រាស់ជាឧបករណ៍ សម្រាប់កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការកាត់បន្ថយការត្រួតពិនិត្យទំនិញច្រើនលើសលប់នៅតាមកំពង់ផែ និងមាត់ច្រកព្រំដែននានា ហើយយន្តការនេះត្រូវបានអនុវត្តសម្រាប់ទំនិញដែលចាត់ថ្នាក់ក្នុងច្រកពណ៌ខៀវ និងពណ៌បៃតងប៉ុណ្ណោះ។ សម្រាប់ឆ្នាំ ២០១៣ អង្គភាពសវនកម្មបានចុះធ្វើការត្រួតពិនិត្យឡើងវិញនូវឯកសាររដ្ឋបាលតែមួយបានចំនួន ១៨៤.៤៦៧ ប្រតិវេទន៍គយស្មើនឹង ៥៨% នៃប្រតិវេទន៍គយសរុប។

**៧០.** ការធ្វើសវនកម្មក្រោយការបញ្ចេញទំនិញពីគយនៅទីតាំងអាជីវកម្មដ្ឋានមានវឌ្ឍនភាពល្អប្រសើរ ក្នុងនោះមាន : (១)- បង្កើតបានក្រុមការងារសវនកម្ម ក្រោយការបញ្ចេញទំនិញពីគយនៅតាមអាជីវកម្មដ្ឋាន និង (២)- រៀបចំចងក្រងសៀវភៅណែនាំសម្រាប់ការធ្វើសវនកម្មក្រោយការបញ្ចេញទំនិញពីគយ ដើម្បីបានជាឯកសារយោងដល់មន្ត្រីគយដែលពាក់ព័ន្ធទាំងឡាយ។

**៧១.** ទោះបីជាមានវឌ្ឍនភាពខាងលើក្តី សវនកម្មក្រោយការបញ្ចេញទំនិញពីគយនៅប្រឈមនឹងបញ្ហាមួយចំនួនផងដែរ។ ទំហំនៃសវនកម្មក្រោយការបញ្ចេញទំនិញនៅអាជីវកម្មដ្ឋានប្រព្រឹត្តទៅក្នុងកម្រិតទ្រង់ទ្រាយតូចនៅឡើយ ដែលអាចមានចន្លោះប្រហោង និងអាចឈានដល់ការខាតបង់ចំណូលពន្ធគយជាយថាហេតុ។ លើសពីនេះក្រុមហ៊ុននាំចូល និងធុរជនមួយចំនួនពុំបានគ្រប់គ្រងបញ្ជីគណនេយ្យត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន ដែលបង្កផលលំបាកដល់ការធ្វើសវនកម្ម។ ចំនួនមន្ត្រីបម្រើការងារក៏នៅមិនទាន់គ្រប់គ្រាន់សម្រាប់ឆ្លើយតបនឹងតម្រូវការពង្រីកមុខងារសវនកម្មនេះឱ្យធំជាងមុន ហើយសមត្ថភាពបច្ចេកទេសវិញក៏នៅមានកម្រិតនៅឡើយ។ ការចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារក៏នៅពុំទាន់ផ្តល់បានទាន់ពេលវេលា និងមិនមានបច្ចុប្បន្នភាព។

**៧២.** ដើម្បីបង្កើនអនុលោមភាពនៃការបំពេញកាតព្វកិច្ចបង់ពន្ធអាករគយឱ្យបានត្រឹមត្រូវ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដោយត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- ពង្រីកអង្គភាពសវនកម្មក្រោយការបញ្ចេញទំនិញពីគយពី ៦ទៅ ៩ក្រុម,
- បញ្ជ្រាបជាប្រចាំដល់ធុរជននូវយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ជាពិសេសពាក់-ព័ន្ធនឹងកាតព្វកិច្ចគ្រប់គ្រង និងថែរក្សាបញ្ជីស្នាមគណនេយ្យ និងឯកសារពាក់ព័ន្ធនឹងការនាំចេញ-នាំចូល,
- ចែករំលែកជាប្រចាំនូវលទ្ធផលសវនកម្មក្រោយការបញ្ចេញទំនិញពីគយ ជាមួយនឹងប្រព័ន្ធគ្រប់គ្រងហានិភ័យ។

***វិធានការរយៈពេលមធ្យម :***

- បង្កើតបណ្តាញផ្លាស់ប្តូរព័ត៌មានហានិភ័យស្វ័យប្រវត្តិរវាងការិយាល័យគយពាក់ព័ន្ធ ដែលបានពីលទ្ធផលនៃការងារសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,
- រក្សាឯករាជ្យភាពនៃតួនាទីរបស់មន្ត្រីសវនកម្មក្រោយបញ្ចេញទំនិញពីគយ ដោយមិនត្រូវមានតួនាទីដទៃទៀត នៅកន្លែងធ្វើបែបបទបញ្ចេញទំនិញពីគយ។

### ៥.២.២ ការពង្រឹងយន្តការឆ្លងកាត់

**៧៣.** ការពង្រឹងយន្តការឆ្លងកាត់នឹងផ្តោតលើអំពើរត់គេចពន្ធ និងការវាយតម្លៃពន្ធគយ។

#### ៥.២.២.១ អំពើរត់គេចពន្ធ

**៧៤.** នៅប្រទេសកម្ពុជា អំពើរត់គេចពន្ធបានកើតឡើងគ្រប់រូបភាព ទាំងផ្លូវទឹក, ផ្លូវគោក និងផ្លូវអាកាស និងកើតឡើងចំពោះទំនិញស្ទើរតែទាំងអស់ ជាពិសេសគឺលើផលិតផលគេលសិលា ដែលជាទំនិញមានវេទយិតភាពខ្ពស់ចំពោះចំណូលពន្ធអាករគយ។

**៧៥.** អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានធ្វើការទប់ស្កាត់ និងប្រឆាំងនឹងអំពើរត់គេចពន្ធមួយចំនួននាពេលកន្លងមក ដោយក្នុងនោះអំពើរត់គេចពន្ធលើផលិតផលរថយន្ត និងគ្រឿងម៉ាស៊ីនមានការថយចុះគួរឱ្យកត់សម្គាល់សម្រាប់រយៈពេល ១០ ឆ្នាំ កន្លងមក។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានបង្ក្រាបអំពើរត់គេចពន្ធក្នុងទ្រង់ទ្រាយតូចចំនួន ៦.៣៧៨ ករណី និងទ្រង់ទ្រាយធំចំនួន ៣៩១ ករណី ក្នុងឆ្នាំ ២០១៣ ហើយចំណូលបានពីពន្ធ និងការផាកពិន័យសរុបទទួលបានចំនួន ៣៣ ពាន់លានរៀលក្នុងឆ្នាំ ២០១៣។

**៧៦.** ជាមួយនឹងវឌ្ឍនភាពខាងលើ អំពើរត់គេចពន្ធនៅតែជាបញ្ហាប្រឈមដោយសារមូលហេតុ : (១)- អំពើរត់គេចពន្ធ ដែលមានបណ្តាញរឹងមាំអាចនៅមានខ្លះនៅឡើយ, (២)- ការកំណត់មិនបានត្រឹមត្រូវនៃចំណាត់ថ្នាក់ទំនិញ និងប្រភពកំណើតប្រទេសនាំចូល គឺមួយផ្នែកបណ្តាលមកពីការផ្តល់ឯកសារប្រកាសពន្ធគយក្លែងបន្លំ, (៣)- កង្វះឧបករណ៍ចុះល្បាត និងបង្ក្រាប, (៤)- នត្ថិភាពនៃការចុះត្រួតពិនិត្យ និងវាយតម្លៃចំពោះការប្រើប្រាស់ទំនិញក្នុងរបបអនុគ្រោះពន្ធឱ្យបានហ្មត់ចត់, (៥)- ការព្យាយាមបំបែកការដឹកជញ្ជូនឱ្យទៅជាការនាំចូលខ្នាតតូចមិនផ្លូវការតាមបណ្តោយព្រំដែន និងអំពើរត់គេចពន្ធលើផ្ទៃសមុទ្រ និង (៦)- កង្វះប្រសិទ្ធភាពនៃការចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត។

**៧៧.** ដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់រូបភាព អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- បន្តអនុវត្តផែនការសកម្មភាពរយៈពេល ៦០ ថ្ងៃ ទន្ទឹមនឹងផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីកាត់បន្ថយគ្រប់ទម្រង់នៃអំពើរត់គេចពន្ធ,
- បញ្ចប់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការសកម្មភាព ដើម្បីបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធរយៈពេលមធ្យម ដោយមានកំណត់សូចនាករ និងរយៈពេលអនុវត្តច្បាស់លាស់,
- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការរៀបចំដាក់បណ្តឹងទៅតុលាការ,
- ពង្រឹងអនុលោមភាពនៃការប្រើប្រាស់ទំនិញក្រោមរបបអនុគ្រោះពន្ធគយ,
- ដាក់ឱ្យអនុវត្តនូវតែមប្រើសម្គាល់យានយន្តនាំចូលដែលរួចពន្ធ និងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រប់គ្រងយានយន្តដែលមានម្ចាស់ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងធ្វើការផ្ទៀងផ្ទាត់ស្លាកលេខយានយន្តខុសច្បាប់ដើម្បីកាត់បន្ថយអំពើរត់គេចពន្ធ,
- រៀបចំឱ្យមានសន្និធិគយបណ្តោះអាសន្ននៅតាមមាត់ច្រកព្រំដែន និងតាមតំបន់ប្រជុំជនបន្ថែមសំដៅកាត់បន្ថយការជញ្ជូនទំនិញតាមរូបភាពបំបែកទំនិញ និងបង្កភាពងាយស្រួលដល់ធុរជនក្នុងការបំពេញបែបបទគយ,

- កែសម្រួលសមាសភាពគណៈកម្មាធិការអន្តរក្រសួងទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ដែលត្រូវបានកំណត់ ដោយបទបញ្ជាលេខ ០២បប របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ។

#### ៥.២.២.២ តម្លៃគិតពន្ធគយ

៧៨. កម្ពុជាបានចាប់ផ្តើមអនុវត្តពេញលេញនូវការកំណត់តម្លៃគិតពន្ធគយឱ្យស្របតាមកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយរបស់អង្គការពាណិជ្ជកម្មពិភពលោកតាំងពីខែ មករា ឆ្នាំ ២០១១។ ជាមួយនឹងការអនុវត្តពេញលេញនូវការកំណត់តម្លៃគិតពន្ធគយនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានបញ្ឈប់ការបោះផ្សាយជាសាធារណៈនូវតារាងតម្លៃគិតពន្ធគយជាតម្លៃរដ្ឋបាល និងចាប់ផ្តើមដាក់ឱ្យអនុវត្តនូវប្រព័ន្ធទ្រទ្រង់ការកំណត់តម្លៃគិតពន្ធគយ និងធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយជាបណ្តើរៗទៅដល់សាខាគយខេត្តចំនួន ១៦។

៧៩. មកដល់បច្ចុប្បន្ននេះ ការអនុវត្តពេញលេញនូវការកំណត់តម្លៃគិតពន្ធគយនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដូចជា : (១)- តម្លៃជាមូលដ្ឋានសម្រាប់ពិចារណា ដែលប្រើដើម្បីផ្ទៀងផ្ទាត់ជាមួយតម្លៃប្រកាសពន្ធមិនត្រូវបានធ្វើបច្ចុប្បន្នកម្មទៀងទាត់ផ្អែកលើតម្លៃទិញលក់ពិតប្រាកដ ហើយតម្លៃជាមូលដ្ឋានសម្រាប់ពិចារណានេះមិនឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយទៅនឹងតម្លៃជាក់ស្តែង, (២)- វិនិយោគិនមួយចំនួន ដែលស្ថិតក្រោមរបបអនុគ្រោះពន្ធ និងអាករ បានដាក់ថ្លៃដើមទំនិញនាំចូលលើវិក្កយបត្រខ្ពស់ជាងតម្លៃទិញលក់ពិតប្រាកដ ដែលកត្តានេះអាចធ្វើឱ្យពួកគេមានឱកាសគេចវេសពីកាតព្វកិច្ចពន្ធលើប្រាក់ចំណេញ, (៣)- ប្រព័ន្ធទ្រទ្រង់ការកំណត់តម្លៃគិតពន្ធគយពុំទាន់បានភ្ជាប់ជាលក្ខណៈស្វ័យប្រវត្តិពេញលេញជាមួយប្រព័ន្ធអាស៊ីគូដានៅឡើយ, (៤)- ការចែករំលែកព័ត៌មានពីអង្គភាពសវនកម្មក្រោយការបញ្ចេញទំនិញពីគយ និងអង្គភាពគយពាក់ព័ន្ធផ្សេងទៀតនៅមានកម្រិត និង (៥)- ច្រករបៀងតូចៗមួយចំនួនអាចកំណត់តម្លៃគិតពន្ធគយលើទំនិញតម្លៃខ្ពស់ ខណៈដែលមាត់ច្រកនោះមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យទំនិញឱ្យបានហ្មត់ចត់។

៨០. ដើម្បីធ្វើឱ្យប្រសើរឡើងនូវការកំណត់តម្លៃគិតពន្ធគយ និងដើម្បីបញ្ចៀសនូវការបាត់បង់ចំណូល អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសិក្សា និងវាយតម្លៃពីលទ្ធភាពនៃការអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចប្រកាសតម្លៃគិតពន្ធគយលើទំនិញនាំចេញ-នាំចូលក្រោមរបបអនុគ្រោះពន្ធតាមតម្លៃចម្លងការ។

### ៥.២.៣ ការពង្រឹងយន្តការគាំទ្រ

៨១. ការពង្រឹងយន្តការគាំទ្រ រួមមាន : ការពង្រឹង និងពង្រីកប្រព័ន្ធអាស៊ីគូដា, ការជំរុញអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ, យន្តការពង្រឹងកិច្ចសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន, ផែនការអភិវឌ្ឍន៍ស្ថាប័ន, ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ, ការគ្រប់គ្រងធនធានមនុស្ស និងសវនកម្មផ្ទៃក្នុង។

#### ៥.២.៣.១ ប្រព័ន្ធអាស៊ីគូដា

៨២. អាស៊ីគូដាមានមុខងារស្នូលក្នុងកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការធ្វើឱ្យមានជាបទដ្ឋាន និងសាមញ្ញកម្មនៃទម្រង់ឯកសារ និងទិន្នន័យគយ ព្រមទាំងស្វ័យប្រវត្តិកម្មនៃមុខងារ និងទិន្នន័យគយតាមមាត់ច្រកព្រំដែនទាំងអស់លើផ្ទៃប្រទេស ដើម្បីជួយបង្កើនល្បឿននៃការបញ្ចេញទំនិញពីគយ និងផ្តល់ព័ត៌មាន និងទិន្នន័យពាណិជ្ជកម្មសំខាន់ៗសម្រាប់ការវិភាគ និងរៀបចំគោលនយោបាយកៀរគរចំណូល និងគោលនយោបាយពាណិជ្ជកម្មផ្សេងៗ។ ប្រព័ន្ធអាស៊ីគូដាត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្តនៅទីស្នាក់ការកណ្តាលនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

និងបណ្តាសាខាគយចំនួន ២១ កន្លែង ដែលគ្របដណ្តប់ប្រមាណជា ៩៥% នៃឯកសាររដ្ឋបាលតែមួយ និងប្រមាណ ៨៥% នៃពាណិជ្ជកម្មកម្ពុជាទាំងអស់។ ធុរជន ឬជើងសាគយអាចធ្វើការបញ្ចូលទិន្នន័យទំនិញនាំចូលទៅក្នុងប្រព័ន្ធអាស៊ីគូដាពីទីតាំងផ្ទាល់របស់ក្រុមហ៊ុន ដោយមិនចាំបាច់មកបញ្ចូលទិន្នន័យផ្ទាល់នៅទីចាត់ការគយតាមមាត់ច្រកនីមួយៗឡើយ។ ការអនុវត្តបែបនេះអាចកាត់បន្ថយការជួបមុខគ្នាផ្ទាល់រវាងធុរជន និងមន្ត្រីគយ និងពន្លឿនការពិនិត្យ និងអនុម័តលើឯកសារនាំចេញ-នាំចូលនានា ក៏ដូចជាការបញ្ចេញទំនិញ។

**៨៣.** ប្រព័ន្ធអាស៊ីគូដានៅមិនទាន់ប្រើប្រាស់ឱ្យអស់សក្តានុពល ដោយសារមូលហេតុ ដូចជា : (១)- ម៉ូឌុលសំខាន់ៗដែលរួមមានម៉ូឌុលការគ្រប់គ្រងនិវេទន៍បណ្ណ, ម៉ូឌុលពិនិត្យទំនិញនៅក្នុងឃ្លាំង, ម៉ូឌុលពិនិត្យទំនិញឆ្លងកាត់ និងម៉ូឌុលរក្សាទិន្នន័យធុរជននៅមិនទាន់បានប្រើប្រាស់ឱ្យបានពេញលេញ និង (២)- ការមិនតភ្ជាប់ទៅមកជាស្វ័យ-ប្រវត្តិរវាងប្រព័ន្ធផ្សេងៗ ដូចជាប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយជាមួយនឹងប្រព័ន្ធអាស៊ីគូដា។

**៨៤.** ដើម្បីធានាឱ្យប្រព័ន្ធអាស៊ីគូដាអាចអនុវត្តបានទាំងស្រុងនូវមុខងារទាំងអស់ និងដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- តភ្ជាប់ប្រព័ន្ធអាស៊ីគូដាជូនតំណាងស្ថាប័នពាក់ព័ន្ធនៅតាមមាត់ច្រក និងនាយកដ្ឋានរដ្ឋាករ។

***វិធានការរយៈពេលមធ្យម :***

- តភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិអាស៊ីគូដាជាមួយនឹងប្រព័ន្ធគ្រប់គ្រងហានិភ័យគយ, ប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រព័ន្ធបញ្ជរតែមួយអាស៊ាន,
- ពង្រីកមុខងាររបស់ប្រព័ន្ធអាស៊ីគូដាដែលនៅសេសសល់។

### ៥.២.៣.២ ប្រព័ន្ធបញ្ជរតែមួយជាតិ

**៨៥.** ប្រព័ន្ធបញ្ជរតែមួយជាតិ គឺជាផែនការមួយក្នុងចំណោមផែនការទាំង ១២ របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អនូវបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្មនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។ ដើម្បីឱ្យស្របទៅនឹងទស្សនវិស័យសហគមន៍អាស៊ាននាឆ្នាំ ២០១៥ រាជរដ្ឋាភិបាលបានសម្រេចបន្តដំណើរការប្រព័ន្ធបញ្ជរតែមួយជាតិដោយមានអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាជាអ្នកដឹកនាំ និងចាប់ផ្តើមដំបូងពីគម្រោងបញ្ជរតែមួយជាតិដោយមិនទាន់មានលក្ខណៈស្វ័យប្រវត្តិពេញលេញសិន។ គោលបំណងសំខាន់ គឺធ្វើការតភ្ជាប់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងស្ថាប័នពាក់ព័ន្ធទាំងអស់ដោយបង្កើតបណ្តាញកុំព្យូទ័រក្នុងប្រព័ន្ធបញ្ជរតែមួយ ដើម្បីទទួលប្រតិវេទន៍គយសម្រាប់ការប្រកាសទំនិញ, ការចុះបញ្ជីទំនិញ, ការត្រួតពិនិត្យឯកសារ និងការផ្តល់អាជ្ញាបណ្ណអនុញ្ញាតទៅលើការនាំចេញ-នាំចូលក្នុងពេលតែមួយ។

**៨៦.** កន្លងមក ការអនុវត្តគម្រោងប្រព័ន្ធបញ្ជរតែមួយជាតិនៅមានភាពយឺតយ៉ាវ ដោយសារមានបញ្ហាប្រឈមមួយចំនួនគឺ : (១)- កង្វះឆន្ទៈក្នុងការចូលរួម និងសហប្រតិបត្តិការពីស្ថាប័នដែលពាក់ព័ន្ធ ដើម្បីផ្តល់នូវធាតុចូលសម្រាប់កំណត់ហានិភ័យគយ ដែលនឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យ និង (២)- ការចូលរួមតិចតួចពីវិស័យឯកជនក្នុងដំណើរការបង្កើត និងអនុវត្តគម្រោងបញ្ជរតែមួយជាតិ។

**៨៧.** ដើម្បីឈានទៅអនុវត្តជាក់ស្តែងប្រព័ន្ធបញ្ជរតែមួយជាតិនាពេលដ៏ខ្លីខាងមុខ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

*វិធានការរយៈពេលខ្លី:*

- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិឱ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន។

*វិធានការរយៈពេលមធ្យម:*

- ភ្ជាប់ប្រព័ន្ធបញ្ជរតែមួយជាតិជាមួយប្រព័ន្ធបញ្ជរតែមួយអាស៊ានសម្រាប់គម្រោងសាកល្បង ដែលនឹងត្រូវអនុវត្ត,
- ពង្រឹងប្រសិទ្ធភាពការងាររវាង ស្ថាប័នរដ្ឋនិងធុរជន, ស្ថាប័នរដ្ឋនិងស្ថាប័នរដ្ឋ និង ធុរជននិងធុរជន ដើម្បីគាំទ្រការអនុវត្តប្រព័ន្ធនេះសម្រាប់រយៈពេលយូរ។

### ៥.២.៣.៣ យន្តការសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន

៨៨. ការលើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមក្នុងការជំរុញអនុលោមភាព និងប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា គឺជាគោលដៅយុទ្ធសាស្ត្រនៃយន្តការសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន ដោយក្នុងនោះអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ពាណិជ្ជកម្ម ដើម្បីប្រើជាយន្តការពង្រឹងកិច្ចពិគ្រោះយោបល់ជាមួយវិស័យឯកជន។ នាពេលថ្មីៗនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានបង្កើតកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចទទួលសិទ្ធិ (Authorized Economic Operator-AEO) ដោយរៀបចំជាបទប្បញ្ញត្តិតាមឧត្តមានុវត្តន៍អន្តរជាតិ និងចុះអនុស្សារណៈរវាងរដ្ឋបាលគយប្រទេសពាក់ព័ន្ធ ដើម្បីទទួលស្គាល់ប្រតិបត្តិករសេដ្ឋកិច្ចទទួលសិទ្ធិ សម្រាប់ជំរុញយន្តការភាពជាដៃគូរវាងគយ និងប្រតិបត្តិករឱ្យកាន់តែមានប្រសិទ្ធភាព។

៨៩. នាខែ វិច្ឆិកា ឆ្នាំ ២០១៣ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានរៀបចំសិក្ខាសាលានៅគ្រប់សាខាគយទាំងអស់ ដើម្បីឱ្យវិស័យឯកជនកាន់តែជ្រួតជ្រាបពីស្តង់ដារ និងនីតិវិធីគយទាក់ទងនឹងការបញ្ចេញទំនិញ, ការដឹកជញ្ជូន និងកាតព្វកិច្ចបង់ពន្ធ ក្នុងគោលបំណងជំរុញឱ្យវិស័យឯកជនចូលរួមសហការល្អថែមទៀតក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធអាករគយ។

៩០. ទោះជាយ៉ាងនេះក្តី វិស័យឯកជននៅមិនទាន់បានចូលរួមសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឱ្យបានសកម្មពេញទំហឹង និងប្រកបដោយប្រសិទ្ធភាពនៅឡើយទេ ទាក់ទងនឹងការផ្តល់មតិយោបល់ក៏ដូចជាព័ត៌មានដែលចាំបាច់ដល់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីជំរុញការផ្តល់សេវាបង់ពន្ធអាករគយជូនធុរជនឱ្យបានប្រសើរឡើង និងការស្វែងយល់ពីនីតិវិធីគយថ្មីៗ ដែលបានដាក់ឱ្យអនុវត្ត ដើម្បីធានាដល់អនុលោមភាពនៃការបង់ពន្ធអាករគយ។

៩១. ដើម្បីឱ្យវិស័យឯកជនចូលរួមឱ្យបានសកម្ម និងមានប្រសិទ្ធភាពជាងមុន អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- រៀបចំកិច្ចប្រជុំយន្តការភាពជាដៃគូ ពិភាក្សាដោះស្រាយបញ្ហា ឬកង្វល់នានារបស់ធុរជន,
- ដាក់ឱ្យអនុវត្តយន្តការលើកទឹកចិត្តដល់ធុរជន ដែលមានអនុលោមភាពខ្ពស់។

### ៥.២.៣.៤ ផែនការអភិវឌ្ឍន៍ស្ថាប័ន

៩២. កន្លងមកអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានរៀបចំផែនការកំណែទម្រង់ និងទំនើបកម្មគយជារៀងរាល់ ៥ ឆ្នាំ ដើម្បីពង្រឹងការប្រមូលចំណូលពន្ធអាករគយ និងអនុលោមភាព, កែលម្អរដ្ឋបាលគយ និងគោលនយោបាយពន្ធឱ្យមានភាពសមស្រប និងប្រកបដោយសមធម៌ជាងមុន និងស្របទៅនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង **យុទ្ធសាស្ត្រចតុកោណ**។

៩៣. ដើម្បីសម្រេចមហិច្ឆតាកសាងរដ្ឋបាលគយទំនើបមួយស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ទាំងផ្នែករចនាសម្ព័ន្ធ, ជំនាញវិជ្ជាជីវៈ និងនីតិវិធីប្រតិបត្តិការ និងបម្រើសេវាប្រកបដោយប្រសិទ្ធភាពដល់រាជរដ្ឋាភិបាល និងសហគមន៍ធុរកិច្ច ព្រមទាំងស្វែងរកប្រភពចំណូលផ្សេងទៀតសំដៅទប់ទល់នឹងការបាត់បង់ចំណូលពន្ធអាករគយ ដែលនឹងបន្តនាពេលអនាគត តាមរយៈការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវមានផែនការអភិវឌ្ឍន៍ស្ថាប័នច្បាស់លាស់រយៈពេលវែងលើសពី ៥ ឆ្នាំ ដោយកំណត់ឱ្យមានទស្សនវិស័យវែងឆ្ងាយ, គោលដៅយុទ្ធសាស្ត្រត្រឹមត្រូវ និងសកម្មភាពច្បាស់លាស់។

៩៤. ដូចនេះ ដើម្បីឱ្យគោលដៅយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកាន់តែមានភាពច្បាស់លាស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី គឺរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័ន ដែលមានទស្សនវិស័យរយៈពេលវែង។

### ៥.២.៣.៥ ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ

៩៥. យុទ្ធសាស្ត្រ និងកម្មវិធីការងារកំណែទម្រង់ និងទំនើបកម្មរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ២០១៤-២០១៨ គឺជាដំណាក់កាលទីបួន ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបាននិងកំពុងអនុវត្ត បន្ទាប់ពីដំណាក់កាលទីបី ២០០៩-២០១៣ បានអនុវត្តប្រកបដោយលទ្ធផលជាផ្លែផ្កា។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ ដែលនឹងត្រូវអនុវត្តក្នុងដំណាក់កាលទីបួននេះ គឺជាការចាំបាច់ និងត្រូវអនុវត្តផ្អែកលើសូចនាករត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់ ដើម្បីតាមដាន និងត្រួតពិនិត្យជាប្រចាំលើលទ្ធផលការងារនៃការអនុវត្តកម្មវិធីកែទម្រង់គយ។

៩៦. ក្នុងការអនុវត្តកន្លងមក អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានរៀបចំ និងដាក់ឱ្យអនុវត្តនូវសូចនាករកម្រិតបឋមសម្រាប់វាស់វែងលទ្ធផលសំខាន់ៗ និងការអនុវត្តការងាររបស់កម្មវិធីកែទម្រង់គយ។ ជាមួយនឹងវឌ្ឍនភាពនេះ ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយនៅតែជួបបញ្ហាប្រឈមមួយចំនួន គឺ : (១)- គណៈកម្មាធិការកែទម្រង់មិនសូវមានលក្ខណៈសកម្មក្នុងការងារ, (២)- ការមិនបានរៀបចំរបាយការណ៍ការងារជាប្រចាំ ដើម្បីប្រើជាសូចនាករត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងារ និងលទ្ធផលការងារ និង (៣)- ទិន្នន័យដែលប្រមូលបាន គឺជាទិន្នន័យជាន់គ្នា និងមិនសូវមានអត្ថប្រយោជន៍សម្រាប់ការវាយតម្លៃការងារ។

៩៧. ដើម្បីកែលម្អការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី គឺពង្រឹងកិច្ចដំណើរការនៃគណៈកម្មាធិការកែទម្រង់គយឡើងវិញ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តការងារកែទម្រង់នេះ។

### ៥.២.៣.៦ ការគ្រប់គ្រងធនធានមនុស្ស

៩៨. ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព គឺជាគោលដៅយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រទាំងឡាយនៃកម្មវិធីការងារកំណែទម្រង់ និងទំនើបកម្មរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ឆ្នាំ ២០១៤-២០១៨ ដោយក្នុងនោះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានកសាង និងរៀបចំ : (១)- ផែនការអភិវឌ្ឍន៍ធនធានមនុស្ស, (២)- កម្មវិធីលើកទឹកចិត្ត, (៣)- ការពង្រឹងសមត្ថភាព និងជំនាញឯកទេស, (៤)- ការជំរុញ និងលើកកម្ពស់ការអប់រំកាយសម្បទា និងភាពថ្លៃថ្នូររបស់មន្ត្រីគយ, (៥)- ការរៀបចំវគ្គហ្វឹកហ្វឺននិងពង្រឹងសមត្ថភាពដល់មន្ត្រីគយ និងរដ្ឋាករ, (៦)- ការពង្រឹងការអនុវត្តក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីគយ

និង (៧)- ការអនុវត្តប្រព័ន្ធវាយតម្លៃការងារជាដើម។ មន្ត្រីគយសរុបទូទាំងប្រទេសមានចំនួន ១.៩៩៤ នាក់ គិតមកត្រឹមចុងឆ្នាំ ២០១៣។

**៩៩.** ក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីគយ ជាផ្នែកមួយនៃកំណែទម្រង់អភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ អគ្គនាយកដ្ឋានបានរៀបចំកិច្ចប្រជុំជាមួយមន្ត្រីគយមកពីបណ្តាសាខាគយ និងរដ្ឋាករទាំងអស់ ដើម្បីក្រើនរំលឹក និងពង្រឹងការអនុវត្តវិន័យ, ក្រមសីលធម៌ និងកិរិយាមាយាទរបស់មន្ត្រីគយទាំងអស់។ មន្ត្រីគយទាំងអស់ត្រូវបំពេញបែបបទគោលការណ៍អភិបាលកិច្ចល្អ ដែលបញ្ជាក់អំពីការមិនចូលរួមក្នុងទំនាស់ផលប្រយោជន៍ ឬការរើសអើងផ្សេងៗចំពោះអ្នកបង់ពន្ធ។ សម្រាប់គោលដៅអភិបាលកិច្ចល្អ ប្រអប់តវ៉ាគយត្រូវបានដាក់នៅតាមសាខាគយទាំងអស់ និងទីស្នាក់ការកណ្តាល ដើម្បីទទួលយោបល់ត្រឡប់ពីអ្នកបង់ពន្ធ និងចាត់វិធានការឱ្យបានទាន់ពេលវេលាឆ្លើយតបនឹងកង្វល់ទាំងឡាយរបស់ធុរជន។ ទន្ទឹមនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានយន្តការភាពជាដៃគូគយផ្នែកឯកជន និងអង្គភាពទំនាក់ទំនងសាធារណៈ ដែលជាលេខាធិការដ្ឋាននៃយន្តការនេះ និងជាចំណុចទំនាក់ទំនងសម្រាប់ដោះស្រាយកង្វល់នានារបស់វិស័យឯកជន ក៏ដូចជាសម្រាប់ទទួលរាល់សំណូមពរ ឬការតវ៉ានានារបស់ផ្នែកឯកជន ជាពិសេសអ្នកនាំចេញ អ្នកនាំចូល មកសម្របសម្រួល និងដោះស្រាយតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីឈានទៅលើកស្ទួយសីលធម៌សារពើពន្ធ និងការសម្រួលពាណិជ្ជកម្មឱ្យបានជាអតិបរមា។

**១០០.** យ៉ាងណាក៏ដោយ នៅមានការកត់សម្គាល់ឃើញនូវការសម្របសម្រួលគយ ដែលមិនស្របច្បាប់មួយចំនួនរវាងមន្ត្រីគយ និងធុរជនខុសច្បាប់ ទាំងថ្នាក់គ្រប់គ្រង និងថ្នាក់អនុវត្តជាក់ស្តែង មួយផ្នែកដោយសារកង្វះប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារ, ដំណើរការ និងការត្រួតពិនិត្យ។ ទន្ទឹមនេះ ការគ្រប់គ្រងធនធានមនុស្សរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនដូចជា : (១)- ក្នុងការអនុវត្តការងារជាក់ស្តែង មន្ត្រីគយមួយចំនួនមានតួនាទី និងមុខតំណែងច្រើនជាង ១ ដែលជាហេតុធ្វើឱ្យមន្ត្រីទាំងនោះមានបន្ទុកការងារខ្ពស់ ដែលនាំទៅដល់ភាពយឺតយ៉ាវក្នុងការបំពេញការងារ, កាត់បន្ថយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការអនុវត្តការងាររបស់អង្គភាពគយ និងរដ្ឋាករទាំងមូល, (២)- ការគោរពប្រតិបត្តិក្រមសីលធម៌របស់មន្ត្រីគយនៅមានកម្រិត និង (៣)- មន្ត្រីគយនៅមានភាពខ្វះខាតខាងសមត្ថភាព, ចំណេះដឹង និងជំនាញចាំបាច់មួយចំនួនសម្រាប់ការអនុវត្តការងារ។

**១០១.** ដើម្បីពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីគយ, សមត្ថភាព និងការកំណត់តួនាទី និងការទទួលខុសត្រូវ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- កាត់បន្ថយនូវការប្រគល់ភារកិច្ចច្រើនកន្លែងដល់មន្ត្រីគយម្នាក់ៗក្នុងពេលតែមួយ,
- ពង្រឹងការគោរពប្រតិបត្តិក្រមសីលធម៌របស់មន្ត្រីគយ,
- ពង្រឹងសមត្ថភាពមន្ត្រីគយតាមរយៈការបណ្តុះបណ្តាលជំនាញចាំបាច់ទាំងឡាយ,
- ពង្រីកវិសាលភាពប្រអប់តវ៉ាគយនៅតាមការិយាល័យគយ និងរដ្ឋាករនៅមាត់ច្រកសំខាន់ៗមួយចំនួន,
- បង្កើតឱ្យមានមន្ត្រីទំនាក់ទំនងសាធារណៈនៅតាមសាខាការិយាល័យគយ និងរដ្ឋាករសំខាន់ៗមួយចំនួន។

### ៥.២.៣.៧ សវនកម្មផ្ទៃក្នុង

**១០២.** ក្នុងយុទ្ធសាស្ត្រ និងកម្មវិធីការងារកំណែទម្រង់ និងទំនើបកម្មរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

កម្ពុជា ២០០៩-២០១៣ ការិយាល័យសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតស្របតាមប្រកាសលេខ ៣៨៨ សហវ.ប្រក និងស្ថិតនៅក្រោមលេខាធិការដ្ឋាន ដែលត្រូវរាយការណ៍ផ្ទាល់ជាប្រចាំជូនអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលជាប្រធានគណៈកម្មាធិការកែទម្រង់ និងទំនើបកម្មគយ។

**១០៣.** កន្លងមក មុខងារសវនកម្មផ្ទៃក្នុងនៅមិនទាន់បំពេញការងារបានពេញលេញនៅឡើយទេ ដោយសារតែមានបញ្ហាប្រឈមមួយចំនួន ដែលមានជាអាទិ៍ : (១)- កិច្ចដំណើរការរបស់ការិយាល័យសវនកម្មផ្ទៃក្នុងពុំទាន់បានពេញលេញតាមបទប្បញ្ញត្តិជាធរមាន និង (២)- មន្ត្រីនាយកដ្ឋានរដ្ឋបាលបានជួយបំពេញមុខងារមួយចំនួនរបស់ការិយាល័យសវនកម្មផ្ទៃក្នុង ដែលខុសពីតួនាទី និងភារកិច្ចកំណត់ដោយបទប្បញ្ញត្តិជាធរមាន។

**១០៤.** ដើម្បីពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលខ្លី ដូចខាងក្រោម÷

- ជំរុញកិច្ចដំណើរការពេញលេញរបស់ការិយាល័យសវនកម្មផ្ទៃក្នុង តាមតួនាទី និងភារកិច្ច ដែលត្រូវបានកំណត់ដោយបទប្បញ្ញត្តិជាធរមានដោយផ្តល់មធ្យោបាយធ្វើការងារ និងធនធានមនុស្សសមស្រប,
- បង្កើតប្រព័ន្ធរបាយការណ៍លទ្ធផលសវនកម្មផ្ទៃក្នុងទៀងទាត់ ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា,
- ជំរុញកិច្ចសហការរវាងការិយាល័យសវនកម្មផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាជាមួយអង្គភាពសវនកម្មផ្សេងទៀត។

## ៥.៣ ការពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ

**១០៥.** វិស័យចំណូលមិនមែនសារពើពន្ធមានវិសាលភាពទូលំទូលាយ។ ប្រភពចំណូលមិនមែនសារពើពន្ធគឺបានមកពីវិស័យ និងសកម្មភាពជាច្រើនផ្សេងគ្នា មានជាអាទិ៍ ចំណូលបានមកពីការចាត់ចែង និងការធ្វើអាជីវកម្មទ្រព្យសម្បត្តិរដ្ឋ, ផលពីសម្បទាន, កម្រៃសេវាសាធារណៈ, ផលពីការពិន័យ និងចំណូលមិនមែនសារពើពន្ធដទៃទៀត។ ជារួម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាស្ថាប័នគ្រប់គ្រង, តាមដាន និងជំរុញការប្រមូលចំណូលមិនមែនសារពើពន្ធតាមរយៈ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។ ជាមួយនឹងវិសាលភាពទូលំទូលាយនេះ វិស័យចំណូលមិនមែនសារពើពន្ធមានបញ្ហាប្រឈមរួម និងដោយឡែកតាមវិស័យនីមួយៗ។ នៅក្នុងន័យនេះ ការពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធត្រូវផ្តោតលើបញ្ហាជារួម និងវិស័យធំៗ ដែលមានសក្តានុពលចំណូលខ្ពស់។

### ៥.៣.១ បរិការណ៍ និងបញ្ហាប្រឈមរួមនៃចំណូលមិនមែនសារពើពន្ធ

**១០៦.** ចំណូលមិនមែនសារពើពន្ធ គឺជាប្រភពមួយចំណែកនៃប្រាក់ចំណូលសរុបរបស់រាជរដ្ឋាភិបាល ដែលមានជាមធ្យមប្រមាណ ១៩% ក្នុងមួយឆ្នាំ និងជាង ២% នៃ ផសស ក្នុងអំឡុងឆ្នាំ ២០០២-២០១២។ ចំណូលមិនមែនសារពើពន្ធបានកើនឡើងពី ៨០២ ពាន់លានរៀល នៅឆ្នាំ ២០០៨ ទៅ ១.៤៤២ ពាន់លានរៀលនៅឆ្នាំ ២០១៣។ នាឆ្នាំ ២០១៣ នេះ ប្រភពនៃចំណូលមិនមែនសារពើពន្ធសំខាន់ៗ មានជាអាទិ៍ ផលពីអាករស្ថានទូតចំនួន ១៩,៨%, ផលពីឯកជនភាវូបនីយកម្ម និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋចំនួន ១៧,៨%, ផលពីវិស័យទេសចរណ៍ចំនួន ១៧,១%, ផលពីវិស័យអាកាសចរណ៍ស៊ីវិលចំនួន ៦,៦%, ផលពីប្រៃសណីយ៍ និងទូរគមនាគមន៍ចំនួន ៥,៣% និងផលពីកម្រៃត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋានចំនួន ៥,៥%។

១០៧. ចំណូលមិនមែនសារពើពន្ធត្រូវបានគ្រប់គ្រង និងប្រមូលនៅតាមក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបង់ចំណូលប្រព្រឹត្តទៅតាមរូបភាពពីរ គឺការបង់ចំណូលដោយត្រង់ និងដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ។ ការបង់ចំណូលដោយត្រង់ គឺជាការបង់ចំណូលដែលបានមកពីប្រាក់ចំណេញ (ភាគលាភ) របស់សហគ្រាសសាធារណៈ, ចំណូលផ្អែកតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀងនៃការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងសម្បទានដទៃទៀតរបស់រដ្ឋ។ ការបង់ចំណូលដោយផ្ទាល់ គឺជាការបង់ចំណូលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ដែលធ្វើឡើងតាមរយៈរដ្ឋទេយ្យករចំណូល។ ការគ្រប់គ្រង និងប្រមូលចំណូលនៅតាមក្រសួង-ស្ថាប័ន បានជួបប្រទះបញ្ហាប្រឈមធំៗមួយចំនួន ដែលតម្រូវឱ្យមានវិធានការដោះស្រាយជារួម។

១០៨. ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដោយក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅមិនទាន់មានការចាត់តាំងមន្ត្រីជាន់ខ្ពស់ច្បាស់លាស់សម្រាប់ការតាមដាន, ការកត់ត្រា, ការកៀរគរចំណូល និងការចាត់វិធានការតឹងទារបំណុល។ ការចូលរួម និងកិច្ចសហការពីក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋជាច្រើនក្នុងការកត់ត្រា, ការប្រមូលចំណូល និងការតឹងទារបំណុល នៅមិនទាន់មានភាពរលូន។ កិច្ចសហការក្នុងការផ្តល់របាយការណ៍, តួលេខ, កិច្ចសន្យា, កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណពីក្រសួង-ស្ថាប័នដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ។ ទន្ទឹមនេះ មានករណីមួយចំនួនលើការចុះ ឬការកែប្រែកិច្ចសន្យា, កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណត្រូវបានធ្វើឡើង ដោយគ្មានការពិនិត្យ និងយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការបង់ចំណូលយឺតយ៉ាវ, ការលាក់ចំណូល និងភាពខ្វះចន្លោះនៃការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់តាមក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន ក៏ជាបញ្ហាប្រឈមរួមនៅក្នុងវិស័យចំណូលមិនមែនសារពើពន្ធផងដែរ។

១០៩. ចំពោះបំណុលក៏នៅមានបញ្ហាប្រឈមផងដែរ ដូចជាបំណុលក្នុងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, វិស័យទេសចរណ៍ និងវិស័យអាកាសចរណ៍ស៊ីវិល។ កន្លងមក បំណុលទាំងនេះបានកើនឡើងជាបន្តបន្ទាប់ ហើយយន្តការដែលត្រូវបានបង្កើតឡើង ដើម្បីទារបំណុលក៏មិនមានប្រសិទ្ធភាពគ្រប់គ្រាន់ ដែលធ្វើឱ្យបំណុលទាំងនោះក្លាយទៅជាបំណុលរ៉ាំរ៉ៃ។ សកម្មភាពមួយចំនួនទៀតក៏បានបង្កើតជាបំណុលច្រើនដែរ ដូចជា ការលក់ និងជួលទ្រព្យសម្បត្តិរដ្ឋ និងសម្បទានរ៉ែ ដោយសារតែភាគីឯកជនមិនបានអនុវត្តតាមកិច្ចសន្យា និងមិនបានគោរពតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធការបង់ចំណូល ហើយរដ្ឋាភិបាលមិនបានចាត់វិធានការម៉ឺងម៉ាត់គ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហានេះ។

១១០. ក្រៅពីបញ្ហាបំណុល សមត្ថភាពក្នុងការប្រមូលចំណូលពីវិស័យសំខាន់ៗក៏នៅមានកម្រិតផងដែរ ដូចជា ធនធានធម្មជាតិ, កាស៊ីណូ, ការធានារ៉ាប់រង និងទូរគមនាគមន៍ ដែលទាមទារឱ្យមានជាចាំបាច់នូវចំណេះដឹងផ្នែកបច្ចេកទេស ដើម្បីអាចយល់ស៊ីជម្រៅអំពីការរៀបចំកិច្ចសន្យា, ការអនុវត្តប្រចាំថ្ងៃ និងផលវិបាកនាពេលអនាគត។ ទន្ទឹមនេះ ការងារប្រមូលចំណូល និងការតាមដានការប្រមូលចំណូលមួយចំនួន តម្រូវឱ្យធ្វើដំណើរទៅតាមបណ្តាខេត្តឆ្ងាយៗ ដែលទាមទារឱ្យមានធនធាន និងមធ្យោបាយសមស្រប។

១១១. ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី:***

- ក្រសួង-ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធទាំងអស់ត្រូវចាត់តាំងថ្នាក់ដឹកនាំ ដែលជាសមាជិករាជរដ្ឋាភិបាលមួយរូប ដើម្បីទទួលខុសត្រូវក្នុងការតាមដាន, ការកត់ត្រា, ការកៀរគរចំណូល និងការចាត់វិធានការតឹងទារបំណុល នៅក្រោមសមត្ថកិច្ចក្រសួង-ស្ថាប័នរបស់ខ្លួន,

- បន្តពង្រឹង និងជំរុញការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់,
- បន្តជំរុញ និងប្រើប្រាស់ប្រព័ន្ធធនាគារក្នុងការបង់ចំណូលមិនមែនសារពើពន្ធ,
- ជំរុញការបង់ចំណូលមិនមែនសារពើពន្ធពីក្រសួង-ស្ថាប័នចូលទៅក្នុងគណនីទោលរតនាគារជាតិឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា,
- បន្តជំរុញការដាក់ឱ្យអនុវត្ត និងការកែលម្អស្តង់ដារសេវាសម្រាប់ការបង់ចំណូលមិនមែនសារពើពន្ធឱ្យមានភាពងាយស្រួល និងមានតម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាព,
- រៀបចំ និងដាក់អនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងកំណត់សមត្ថកិច្ចឱ្យបានច្បាស់-លាស់រវាងក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការកត់ត្រា, ការតាមដាន និងការកៀរគរចំណូលមិនមែនសារពើពន្ធ,
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់វិធានការជំរុញឱ្យក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យពង្រឹងកិច្ចការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ ស្របតាមបទដ្ឋានគតិយុត្ត និងគោលការណ៍កំណត់ជាធរមាន,
- ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវប្រគល់កិច្ចសន្យា, កិច្ចព្រមព្រៀង, អាជ្ញាបណ្ណ, សៀវភៅបន្ទុក និងឯកសារពាក់ព័ន្ធគ្រប់ប្រភេទមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំទិន្នន័យសម្រាប់តាមដានការបង់ចំណូល, ការអនុវត្តកិច្ចសន្យា, កិច្ចព្រមព្រៀង, អាជ្ញាបណ្ណ និងសៀវភៅបន្ទុក និងការជំរុញការបង់ចំណូល រួមទាំងការដាក់ចេញនូវវិធានការចាំបាច់នានា,
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំទម្រង់គំរូសម្រាប់ការរៀបចំរបាយការណ៍ចំណូលឱ្យដល់ក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីរៀបចំ និងផ្ញើរបាយការណ៍ចំណូលប្រចាំខែទៀងទាត់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
- កែសម្រួលក្រុមការងារដែលបានបង្កើតហើយ និងបង្កើតក្រុមការងារអន្តរក្រសួងជាបន្ទាន់ ចំពោះវិស័យណាដែលមិនទាន់មាន ដើម្បីទារបំណុលតាមនីតិវិធី, គោលការណ៍ និងបទប្បញ្ញត្តិជាធរមានដូចជា វិស័យអាកាសចរណ៍ស៊ីវិល, វិស័យទេសចរណ៍, វិស័យទូរគមនាគមន៍ និងវិស័យផ្សេងៗទៀត,
- ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើ-ពន្ធរបស់ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រី ស្តីពីស្ថានភាពនៃការតាម-ដាន, កត់ត្រា និងប្រមូលចំណូល ឬការលាក់ទុកចំណូលរបស់ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយស្នើសុំមានវិធានការលើកទឹកចិត្តសម្រាប់ស្ថាប័នទាំងឡាយណាដែលប្រមូលចំណូលបានល្អ និងដាក់វិធានការរដ្ឋបាលតឹងរ៉ឹងចំពោះស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដែលប្រមូលចំណូលមិនបានល្អ ឬលាក់ចំណូល ដោយមិនរាប់បញ្ចូលនូវទោសទណ្ឌផ្សេងទៀតស្របតាមច្បាប់ជាធរមាន,

- ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ ដែលមានភារកិច្ចទារបំណុលត្រូវធ្វើរបាយការណ៍លម្អិតប្រចាំគ្រា មកកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីយន្តការ និងលទ្ធផលនៃការទារបំណុល,
- ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការចាត់វិធានការព្រមាន, ដកហូតអាជ្ញាបណ្ណ, លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ និងវិធានការចាំបាច់ផ្សេងៗទៀតតាមការអនុញ្ញាតរបស់ច្បាប់ ក្នុងករណីក្រុមហ៊ុនមិនមានចំណាត់ការណាមួយក្នុងការសងបំណុល,
- ផ្តល់សិទ្ធអំណាចគ្រប់គ្រាន់តាមផ្លូវច្បាប់, ធនធាន និងមធ្យោបាយសមស្របសម្រាប់មន្ត្រីចុះត្រួតពិនិត្យ និងប្រមូលចំណូលមិនមែនសារពើពន្ធ,
- សិក្សាពីការរៀបចំយន្តការលើកទឹកចិត្តដល់មន្ត្រីពាក់ព័ន្ធ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល។

***វិធានការរយៈពេលមធ្យម៖***

- រៀបចំការពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មជាយថាហេតុ លើកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរាជរដ្ឋាភិបាល,
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដោយភ្ជាប់បណ្តាញទំនាក់ទំនងរវាងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងរដ្ឋទេយ្យករចំណូលរបស់ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលបន្ទុកចំណូល ដើម្បីកត់ត្រាចំណូល, តាមដានការបង់ចំណូល និងចាត់វិធានការបង់ចំណូលឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព,
- រៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការបណ្តុះបណ្តាលជំនាញតាមវិស័យដល់មន្ត្រីដែលគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ,
- រៀបចំក្រុមការងារមួយដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋ ដោយផ្សារភ្ជាប់ជាមួយនឹងការសិក្សាអំពីភាពប្រកួតប្រជែងរបស់កម្ពុជាពាក់ព័ន្ធនឹងកម្រៃសេវានីមួយៗនៅក្នុងតម្លៃនៃការធ្វើធុរកិច្ច, អាជីវកម្ម និងពាណិជ្ជកម្មជារួម ដោយប្រៀបធៀបជាមួយប្រទេសជិតខាងក្នុងតំបន់ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រធ្វើការកែតម្រូវកម្រៃសេវា និងរង្វាន់លើកទឹកចិត្តផ្សារភ្ជាប់ជាមួយនឹងកំណែទម្រង់បៀវត្សក្នុងគោលដៅបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

### ៥.៣.២ វិស័យអាកាសចរណ៍ស៊ីវិល

**១១២.** ចំណូលពីអាកាសចរណ៍ស៊ីវិលរួមមានចំណូលសំខាន់ៗ ដូចជា ការបែងចែកប្រាក់ចំណូលពីកម្រៃស្នួយសារ និងកម្រៃសេវានាំផ្លូវចុះចត, ហោះឡើង និងហោះឆ្លងកាត់ ដែលមានក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជាទទួលបន្ទុក និងការបែងចែកប្រាក់ចំណូលពីក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជា ដែលទទួល

គ្រប់គ្រងសកម្មភាពរបស់អាកាសយានដ្ឋានអន្តរជាតិទាំងអស់។ វិស័យនេះមានសក្តានុពលខ្ពស់ ដោយសារតែកំណើន ចំនួនជើងហោះហើរជារៀងរាល់ឆ្នាំ។ នៅក្នុងឆ្នាំ ២០១៣ ចំណូលពីវិស័យនេះទទួលបានប្រហែល ៦,៦ % នៃ ចំណូល មិនមែនសារពើពន្ធសរុប។ កំណើនមធ្យមប្រចាំឆ្នាំនៃវិស័យនេះ គឺមានប្រមាណជា ៦,២% ក្នុងអំឡុងឆ្នាំ ២០០៨-២០១៣ ។

**១១៣.** ការប្រមូលចំណូលពីវិស័យនេះជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ចំណូល និង ការបែងចែកចំណូលពីក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជា មានបរិមាណតិចតួច និង (២)- កម្រៃសេវាជាក់ស្តែងបច្ចុប្បន្ននៅមានកម្រិតទាប។

**១១៤.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការរយៈពេលខ្លីចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូច ខាងក្រោម÷

- ពិនិត្យ និងសិក្សាអំពីការកែប្រែកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា និង ក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជាស្តីពីការបែងចែកចំណូល ដោយផ្អែកលើការវិនិយោគ ជាក់ស្តែងរបស់ក្រុមហ៊ុនលើការពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាព្រលានយន្តហោះ និងដោយយោងទៅតាមកំណើនសេដ្ឋកិច្ច និងចំណូលពីវិស័យនេះ,
- ពិនិត្យ និងសិក្សាឡើងវិញនូវការផ្តល់រង្វាន់លើកទឹកចិត្តដល់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

### ៥.៣.៣ វិស័យទេសចរណ៍

**១១៥.** វិស័យទេសចរណ៍ គឺជាកត្តាលីករដ៏មានសក្តានុពលមួយក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ជាមួយ នឹងគោលនយោបាយបើកចំហជើងមេឃ វិស័យទេសចរណ៍បានរីកចម្រើនយ៉ាងឆាប់រហ័ស ទាំងចំនួនភ្ញៀវទេសចរ, សណ្ឋាគារ និងទីកន្លែងកំសាន្ត។ ក្នុងឆ្នាំ ២០១៣ ចំនួនភ្ញៀវទេសចរធ្វើដំណើរមកកាន់ព្រះរាជាណាចក្រកម្ពុជាមាន ចំនួនប្រមាណ ៤,២ លាននាក់ កើនឡើង ១៧,៥% ធៀបនឹងឆ្នាំ ២០១២ ដែលមានចំនួន ៣,៦ លាននាក់។ ចំណូលពីវិស័យទេសចរណ៍ បានមកពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទដល់សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន, ខារ៉ាអូខេ, ទីកន្លែងកំសាន្ត និងការលក់សំបុត្រចូលទស្សនារមណីយដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រនានា។ល។ នៅក្នុងឆ្នាំ ២០១៣ ចំណូលពីផ្នែកនេះត្រូវបានប៉ាន់ស្មានថាចូលរួមចំណែកទៅក្នុងចំណូលមិនមែនសារពើពន្ធសរុប ប្រមាណ ១៧,៨% ស្មើនឹង ២១០ ពាន់លានរៀល ជាមួយនឹងអត្រាកំណើនជាមធ្យមប្រមាណ ១០,៥% ក្នុងចន្លោះឆ្នាំ ២០០៨-២០១៣។ ការប្រមូលចំណូលខាងលើនេះជួបបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- កំណើនចំណូលមិន សមមាត្រទៅនឹងកំណើននៃចំនួនភ្ញៀវទេសចរ, (២)- ភាពមិនច្បាស់លាស់នៃការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ ប្រភេទសណ្ឋាគារ និងភោជនីយដ្ឋាន និង (៣)- ការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នៅមានកម្រិត។

**១១៦.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- សិក្សាលទ្ធភាពដំឡើងកម្រៃអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ,
- បង្កើតការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,
- បង្កើតក្រុមការងារអន្តរក្រសួងថ្មី ដើម្បីចុះស្រាវជ្រាវ, ពិនិត្យ និងតាមដានចំណូលផ្សេងៗទៀតពី វិស័យទេសចរណ៍,

- សិក្សាអំពីលទ្ធភាពដំឡើងថ្លៃសំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានទេសចរណ៍នានា,
- កំណត់ឱ្យមានការធ្វើចំណាត់ថ្នាក់សណ្ឋាគារ មុននឹងបន្តអាជ្ញាបណ្ណទេសចរណ៍អាជីវកម្មសណ្ឋាគារ,
- លើកកម្ពស់ និងពង្រឹងប្រសិទ្ធភាពនៃក្រុមការងារវាយតម្លៃ និងធ្វើចំណាត់ថ្នាក់សណ្ឋាគារ ដែលដឹកនាំដោយក្រសួងទេសចរណ៍។

***វិធានការរយៈពេលមធ្យម :***

- ចាត់វិធានការជំរុញបង្កើនចំណូលពីកិច្ចសន្យាសម្បទាន ស្តីពីការប្រមូលចំណូលពីរមណីយដ្ឋានទេសចរណ៍ រួមទាំងពិនិត្យលទ្ធភាពកែប្រែកិច្ចសន្យាមួយចំនួនដែលមានការចាំបាច់,
- បង្កើតឱ្យមានប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ។

### ៥.៣.៤ ចំណូលពីអាករស្ថានទូត

**១១៧.** ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិទទួលបន្ទុកប្រមូលចំណូលពីអាករស្ថានទូត។ ការផ្តល់ទិដ្ឋាការមានពីរបែប : (១)- ការបិទសន្លឹកទិដ្ឋាការលើលិខិតឆ្លងដែន និង (២)- ទិដ្ឋាការអេឡិចត្រូនិច (e-Visa)។ អាស្រ័យដោយ e-Visa បានផ្តល់នូវផលប្រយោជន៍ជាច្រើនយ៉ាងដល់ភ្ញៀវទេសចរនៅក្នុងការស្នើសុំទិដ្ឋាការ ដូចជា ចំណេញពេលវេលាក្នុងការធ្វើដំណើរមកសុំទិដ្ឋាការនៅស្ថានទូត, ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលកិត្តិយស និងចំណេញថវិកាក្នុងការចាយលើសោហ៊ុយផ្សេងៗ ការប្រើប្រាស់សេវានេះមានការកើនឡើងជាបន្តបន្ទាប់។ ចំណូលពីវិស័យនេះមានទំហំធំគួរឱ្យកត់សម្គាល់ និងបន្តកើនឡើងជារៀងរាល់ឆ្នាំ ទៅតាមកំណើននៃភ្ញៀវទេសចរ។ ទន្ទឹមនឹងនេះ យោងអនុក្រឹត្យលេខ ២២៧ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤ តម្លៃទិដ្ឋាការក៏ត្រូវបានរាជរដ្ឋាភិបាលដំឡើងថ្លៃពី ២០ ដុល្លារអាមេរិក ទៅ ៣០ ដុល្លារអាមេរិក ចំពោះទិដ្ឋាការទេសចរណ៍ (ទិដ្ឋាការប្រភេទ T) និងដំឡើងថ្លៃពី ២៥ ដុល្លារអាមេរិក ទៅ ៣៥ ដុល្លារអាមេរិក ចំពោះទិដ្ឋាការធម្មតា (ទិដ្ឋាការប្រភេទ E) ដែលបានអនុវត្តចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ នេះតទៅ ឱ្យស្របទៅតាមវឌ្ឍនភាពនៃការអភិវឌ្ឍក្នុងប្រទេស និងតំបន់។ ចំណូលពីអាករស្ថានទូតក្នុងឆ្នាំ២០១៣ បានរួមចំណែក ១៩,៨% នៃចំណូលមិនមែនសារពើពន្ធសរុប។

**១១៨.** បើទោះជាចំណូលពីអាករស្ថានទូតមាននិន្នាការកើនឡើង ដោយសារមានការកើនឡើងនៃភ្ញៀវទេសចរ និងការដំឡើងថ្លៃទិដ្ឋាការ ក៏ចំណូលពីវិស័យនេះនៅមានបញ្ហាប្រឈមមួយចំនួនដូចជា : (១)- ពុំទាន់មានបទដ្ឋានបច្ចេកទេសសម្រាប់ការកត់ត្រាចំណូល និងនីតិវិធីនៃការគ្រប់គ្រងសន្និធិសន្លឹកទិដ្ឋាការ, (២)- ការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលអាករស្ថានទូតពីមន្ត្រី ដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការមកអង្គភាពគណនេយ្យ នៅពុំទាន់មានភាពច្បាស់លាស់ និងមានភាពយឺតយ៉ាវ ដែលធ្វើឱ្យការកត់ត្រាមានភាពស្មុគស្មាញ, (៣)- ការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់នៅពុំទាន់មានសង្គតិភាពទៅនឹងចំនួនសន្លឹកទិដ្ឋាការ ដែលភ្ញៀវទេសចរបានបង់អាករស្ថានទូត និង (៤)- ការបន្តលើកលែងទិដ្ឋាការនាពេលខាងមុខនឹងបង្កឱ្យមានផលប៉ះពាល់ដល់ចំណូលពីអាករស្ថានទូត។

**១១៩.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវបានកំណត់ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- បន្តជំរុញឱ្យគ្រប់ចំណុចគោលដៅ ដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចររួមមាន ច្រកអន្តរជាតិ និងស្ថានទូត, ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយស រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ, ប្រចាំត្រីមាស, ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់ និងច្បាស់លាស់,

- ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវរៀបចំរបាយការណ៍ទាំងបីប្រភេទខាងលើ ហើយត្រូវឆ្លុះបញ្ចាំងគ្នាទៅវិញទៅមក ព្រមទាំងមានមូលដ្ឋានអាចវាស់វែង និងវាយតម្លៃពីការគ្រប់គ្រងបាន,
- អង្គភាពអនុវត្តការផ្ដល់ទិដ្ឋាការត្រូវរក្សាគល់សន្លឹកទិដ្ឋាការ និងគល់បង្កាន់ដៃបង់ប្រាក់សម្រាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់,
- ជំរុញអនុវត្តនីតិវិធីនៃការកត់ត្រា និងតាមដានសន្និធិសន្លឹកទិដ្ឋាការ និងសន្និធិបង្កាន់ដៃបង់ប្រាក់ទៅតាមវិធីសាស្ត្រឃ្លាំងសន្និធិ (Stock Inventory)។

*វិធានការរយៈពេលមធ្យម:*

- រៀបចំសារាចរណែនាំស្ដីពីការគ្រប់គ្រងចំណូលពីអាករស្ថានទូត និងគ្រប់គ្រងសន្លឹកទិដ្ឋាការ ដើម្បីជាបន្ទាត់ក្នុងការផ្ទៀងផ្ទាត់ឆ្លុះបញ្ចាំងរវាងសន្លឹកទិដ្ឋាការ ដែលបានប្រើប្រាស់ និងចំណូលពីអាករស្ថានទូត,
- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្ដើមពីកម្រៃសេវាធ្វើដំណើរតាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្ដល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ។

### ៥.៣.៥ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

**១២០.** វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ គឺជាវិស័យដ៏សំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ វិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងទីផ្សារទូរស័ព្ទចល័ត និងអ៊ីនធើណែត។ ចំណូលពីវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍មាន ដូចជា ការចែករំលែកចំណូលរវាងប្រតិបត្តិករទូរគមនាគមន៍ ជាមួយរាជរដ្ឋាភិបាល, ថ្លៃអាជ្ញាបណ្ណទូរគមនាគមន៍ និងអ៊ីនធើណែត, ថ្លៃអាជ្ញាបណ្ណប្រៃសណីយ៍, ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ និងចំណូលផ្សេងៗទៀត។ ចំណូលពីវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍នៅឆ្នាំ ២០១៣ បានរួមចំណែក ៥,៤ % នៃចំណូលមិនមែនសារពើពន្ធសរុប។

**១២១.** ចំណូលពីវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវបានរំពឹងថានឹងបន្តកើនឡើងដោយសារកំណើននៃសកម្មភាពទូរគមនាគមន៍ដូចជាសេវាទូរស័ព្ទចល័ត, អ៊ីនធើណែត និងចំនួនអ្នកប្រើប្រាស់។ ទោះបីជាកន្លងមកចំណូលពីវិស័យនេះ បានរួមចំណែកយ៉ាងច្រើននៅក្នុងចំណូលថវិកាជាតិក៏ដោយ ក៏វិស័យនេះជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា : (១)- កង្វះគោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, (២)- កង្វះប្រសិទ្ធភាពនៃការគ្រប់គ្រង, ការចេញអាជ្ញាបណ្ណ និងការកំណត់ចំនួនអាជ្ញាបណ្ណ, (៣)- កង្វះយន្តការ និងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ និង (៤)- ការបែងចែកប្រាក់ចំណូលដុលជាមួយក្រុមហ៊ុនទូរស័ព្ទមិនឆ្លើយតបនឹងស្ថានភាពទីផ្សារ និងមិនទាន់ពេលវេលា។

**១២២.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

*វិធានការរយៈពេលខ្លី:*

- លើកកម្ពស់ និងពង្រឹងប្រសិទ្ធភាពការងារនៃក្រុមការងារអន្តរក្រសួងសម្រាប់ទារបំណុលវិស័យទូរគមនាគមន៍,

- ជំរុញការរៀបចំ និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលគ្រប់គ្រងព័ត៌មានទូរគមនាគមន៍ (DMC) ឱ្យបានឆាប់,
- ដកហូត ឬលុបចោលនូវអាជ្ញាបណ្ណ ឬកិច្ចសន្យាណាដែលមិនត្រូវបានអនុវត្ត,
- ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍។

*វិធានការរយៈពេលមធ្យមៈ*

- រៀបចំ និងធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃសណីយ៍,
- រៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយប្រៃសណីយ៍ និងទូរគមនាគមន៍, គោលនយោបាយប្រ៊ដ-បែនជាតិ (National Broadband Policy) និងគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន និងទូរគម-នាគមន៍។

### ៥.៣.៦ ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងចំណូលពីផល-អនុផលព្រៃឈើ

**១២៣.** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានជាស្ថាប័នទទួលបន្ទុកលើសម្បទានដីសេដ្ឋកិច្ច។ ក្នុងឆ្នាំ ២០១៣ សម្បទានដីសេដ្ឋកិច្ចសរុប ២៣០ ក្រុមហ៊ុន មានផ្ទៃដីសរុបចំនួន ១.៩៣៤.៨៩៦ ហិកតា ក្នុងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានផ្តល់ឱ្យ ១២២ ក្រុមហ៊ុន ដែលមានផ្ទៃដីសរុប ១.៣១៦.៣៩៦ ហិកតា និងក្រសួងបរិស្ថានបានផ្តល់ឱ្យ ១០៨ ក្រុមហ៊ុន ដែលមានផ្ទៃដីចំនួន ៦១៨.៥០០ ហិកតា។ ជាមួយនឹងការអនុវត្តបទបញ្ជាលេខ ០១បប របស់រាជរដ្ឋាភិបាល ផ្ទៃសម្បទានដីសេដ្ឋកិច្ចចំនួន ៣៦ ម៉ឺនហិកតារបស់ ១២៩ ក្រុមហ៊ុនត្រូវបានកាត់ចេញ និងផ្តល់ជូនប្រជាជន ក្រោមគោលនយោបាយចាស់សកម្មភាពថ្មី លើវិស័យដីធ្លី។ ទន្ទឹមនេះ សម្បទានដីសេដ្ឋកិច្ចចំនួន ២១៥.២៤០ ហិកតា ត្រូវបានដកហូតទាំងស្រុងពី ២៥ ក្រុមហ៊ុន និងដកហូតស្ទើរតែទាំងអស់ពី ៧ ក្រុមហ៊ុនមកដាក់ក្រោមការគ្រប់គ្រងរបស់រដ្ឋវិញ។ ជាលទ្ធផល គិតត្រឹមដើមខែ មករា ឆ្នាំ ២០១៥ ផ្ទៃសម្បទានដីសេដ្ឋកិច្ច ដែលបានចុះកិច្ចសន្យាមានចំនួន ២០៥ ក្រុមហ៊ុន មានផ្ទៃដីសរុបចំនួន ១.៣៥៩.៦៥៦ ហិកតា។ មកដល់បច្ចុប្បន្ននេះ ទំហំផ្ទៃសម្បទានដីសេដ្ឋកិច្ចចំនួនប្រមាណ ៣៦០.៨៥៦,០៤ ហិកតា ត្រូវបានអនុញ្ញាតឱ្យឈូសឆាយ និងចំនួន ៣១៦.៤៧២ ហិកតា ត្រូវបានដាំដុះរួច។ តាមគោលការណ៍របស់រាជរដ្ឋាភិបាល សម្បទានិកត្រូវបង់ថ្លៃឈ្នួលសម្បទានដីចំនួន ៥ ដុល្លារអាមេរិក ក្នុង ១ ហិកតា ក្នុងមួយឆ្នាំនៃផ្ទៃដី ដែលបានអនុញ្ញាតឱ្យឈូសឆាយ ដោយគិតពីឆ្នាំទី ៦ ទៅ ហើយថ្លៃសម្បទានដីត្រូវកើន ១% ក្នុងមួយឆ្នាំចាប់គិតពីឆ្នាំទី ៧។ ទន្ទឹមនេះ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ត្រូវបង់ប្រាក់កក់ ១០ ដុល្លារអាមេរិកក្នុងមួយហិកតានៃទំហំដី ដែលបានផ្តល់ជូនបន្ទាប់ពីចុះកិច្ចសន្យាក្នុងរយៈពេលមួយខែ។ ប្រាក់កក់ចំនួន ៧០% នឹងត្រូវប្រគល់ជូនក្រុមហ៊ុនវិញនៅពេលការដាំដុះចប់សព្វគ្រប់តាមផែនការមេ។ ប្រាក់កក់ចំនួន ៣០% ដែលនៅសល់ គឺសម្រាប់ទូទាត់ថ្លៃសម្បទានដីនៅចុងគ្រានៃកិច្ចសន្យា។ រាជរដ្ឋាភិបាលនឹងបន្តត្រួតពិនិត្យ និងវាយតម្លៃលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងឡាយណាដែលអសកម្ម ដើម្បីឈានទៅដកយកដីសម្រាប់រដ្ឋគ្រប់គ្រងវិញ ។

**១២៤.** ជាកិច្ចខិតខំក្នុងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចឱ្យបានល្អប្រសើរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានបានដាក់ចេញនូវប្រកាសរួម ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការពង្រឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងបានឯកភាពយកថ្លៃឈ្នួលដីទៅតាមទំហំ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានបានអនុញ្ញាតឱ្យឈូសឆាយ។ ជាមួយគ្នានេះដែរ ផល-អនុផលពីព្រៃឈើនៅលើ

សម្បទានដីសេដ្ឋកិច្ចទាំងអស់មិនមែនជារបស់ក្រុមហ៊ុនទេ តែជាកម្មសិទ្ធិរបស់រដ្ឋ ដែលត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ និងដាក់ដេញថ្លៃលក់ចូលជាថវិការដ្ឋ។ ក្រៅពីសម្បទានដីសេដ្ឋកិច្ច ផល-អនុផលព្រៃឈើនៅក្នុងទីតាំងអាងស្តុកវារីអគ្គិសនី, ទំនប់អាងស្តុកទឹកស្រោចស្រព និងចំណូលពិន័យបទល្មើសផល-អនុផលផ្សេងៗ ក៏ជាប្រភពចំណូលដ៏សំខាន់មួយដែរ។ ជាក់ស្តែង គិតចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៤ ចំណូលនេះមានចំនួនសរុប ៣១៧,២១ ពាន់លានរៀល ក្នុងនោះពីសម្បទានដីសេដ្ឋកិច្ចចំនួន ១៩០,២៧ ពាន់លានរៀល, ចំណូលពីអាងស្តុកទឹកវារីអគ្គិសនី ចំនួន ២៨,១ ពាន់លានរៀល និងចំណូលផ្សេងៗចំនួន ៩៨,៨៤ ពាន់លានរៀល។ ក្នុងនោះសម្រាប់ឆ្នាំ ២០១៤ ចំណូលពីថ្លៃសម្បទានដីសេដ្ឋកិច្ចក្រោមបន្ទុកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង់សរុបចំនួន ៤,៣៨ ពាន់លានរៀល។

**១២៥.** ទោះបីជាការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះបានចាប់ផ្តើមជាយូរមកហើយក្តី វិស័យនេះនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា : (១)- រដ្ឋទទួលបានចំណូលតិចតួចនៅឡើយពីថ្លៃសម្បទានដីសេដ្ឋកិច្ច និងផល-អនុផលពីព្រៃឈើពីសម្បទានិក និង (២)- កង្វះប្រសិទ្ធភាពក្នុងការចាត់វិធានការពីក្រសួងពាក់ព័ន្ធ ដើម្បីរកដំណោះស្រាយ ឬទារថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច និងផល-អនុផលពីព្រៃឈើ ដែលត្រូវបង់ និងថ្លៃជំពាក់ពីក្រុមហ៊ុនឯកជន។

**១២៦.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- រៀបចំ និងដាក់ឱ្យអនុវត្តប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន ស្តីពីការលក់ និងផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច, ប្រកាសរួមស្តីអំពីនីតិវិធីនៃការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច និងប្រកាសរួមស្តីពីការបង្កើតយន្តការ និងនីតិវិធីក្នុងការគ្រប់គ្រង និងការប្រមូលចំណូលពីផល-អនុផលព្រៃឈើលើសម្បទានដីសេដ្ឋកិច្ច, វារីអគ្គិសនី, ទំនប់អាងស្រោចស្រព និងពីប្រភពផ្សេងៗទៀត,
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ត្រូវជំរុញឱ្យសម្បទានិកបង់ និងបង់រំលឹកចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋតាមគោលការណ៍របស់រាជរដ្ឋាភិបាល នៅលើដីដែលបានអនុញ្ញាតឱ្យឈូសឆាយ ក្នុងតម្លៃ ៥ ដុល្លារអាមេរិក/ហិកតា/ឆ្នាំ ចាប់ពីឆ្នាំទី ៦ បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច,
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានត្រូវរៀបចំទិន្នន័យសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដើម្បីគ្រប់គ្រង និងតាមដានការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ក្នុងនោះរួមមានការតាមដានការបង់ចំណូលជូនរដ្ឋផងដែរ,
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងសម្បទានដីសេដ្ឋកិច្ច និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន។

***វិធានការរយៈពេលមធ្យម :***

- សិក្សាលើគោលនយោបាយតម្លៃសម្បទានដីសេដ្ឋកិច្ច ដោយពិចារណាទៅលើភាពទាក់ទាញសម្រាប់អ្នកវិនិយោគ និងផលប្រយោជន៍សមស្របជូនរាជរដ្ឋាភិបាល,

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានត្រូវធ្វើបញ្ជីសារពើភ័ណ្ឌសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដោយធានាឱ្យមានសង្គតិភាពទៅនឹងការចុះបញ្ជីដីរដ្ឋ។

### ៥.៣.៧ ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍

**១២៧.** កន្លងមករាជរដ្ឋាភិបាលបានចុះកិច្ចសន្យាជួលកោះ តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានមួយចំនួន ដែលមានលក្ខណៈជាកិច្ចសន្យាជួលរយៈពេលវែងឱ្យក្រុមហ៊ុនឯកជន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍជាតំបន់ទេសចរណ៍ ដោយភ្ជាប់ជាមួយនឹងកាតព្វកិច្ចបង់ប្រាក់កក់, ថ្លៃឈ្នួល និងលក្ខខណ្ឌវិនិយោគមួយចំនួនទៀត។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនាមជាភាគីនៃកិច្ចសន្យា តំណាងឱ្យរាជរដ្ឋាភិបាល ជាស្ថាប័នទទួលបន្ទុកក្នុងការចាត់ចែងលើនីតិវិធីសំណើ និងតាមដានផ្ទាល់លើការអនុវត្តគម្រោង។ រហូតមកដល់បច្ចុប្បន្ននេះ កិច្ចសន្យាប្រភេទនេះចំនួន ៣៩ ត្រូវបានធ្វើឡើងតាមរយៈការពិនិត្យពិភាក្សាក្នុងក្របខ័ណ្ឌអន្តរក្រសួង និងច្រកចេញចូលតែមួយនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ជាក់ស្តែង វិស័យនេះមានបញ្ហាប្រឈមដូចជា : (១)- ភាពយឺតយ៉ាវក្នុងការអនុវត្តតាមកម្មវិធីអភិវឌ្ឍន៍ និង (២)- ភាពយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួល។

**១២៨.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ វិធានការមួយចំនួនត្រូវដាក់ចេញ និងអនុវត្ត ដូចខាងក្រោម÷

- រៀបចំ និងដាក់ឱ្យអនុវត្តប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាន ដើម្បីពិនិត្យតាមដានឱ្យបានម៉ឺងម៉ាត់លើការអនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុន, កាតព្វកិច្ចបង់ចំណូលជូនរដ្ឋ និងដាក់ឱ្យអនុវត្តយន្តការតឹងទារបំណុល, ពិន័យ ឬស្នើលុបកិច្ចសន្យា និងរឹបអូសប្រាក់កក់ជាយថាហេតុ ទន្ទឹមនឹងបន្តជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍កោះ និងឆ្នេរទាំងនោះ ដើម្បីធ្វើពិពិធកម្មផលិតផលទេសចរណ៍,
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃ នៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន។

### ៥.៣.៨ ចំណូលពីសហគ្រាសសាធារណៈ

**១២៩.** សហគ្រាសសាធារណៈ គឺជាសហគ្រាស ដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។ សហគ្រាសសាធារណៈត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ សហគ្រាសសាធារណៈត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងនៃអាណាព្យាបាលហិរញ្ញវត្ថុ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ចំណូលពីសហគ្រាសសាធារណៈ គឺបានមកពីការបែងចែកភាគលាភរបស់សហគ្រាសសាធារណៈនោះ។ ចំណូលនេះបានមកពីសហគ្រាសសាធារណៈមួយចំនួន ដូចជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, ភ្នាក់ងារនាវាចរណ៍កម្ពុជា, សហគ្រាសបោះពុម្ព និងចែកផ្សាយ, កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងសហគ្រាសដទៃទៀត ។ល។

**១៣០.** ការបង់ចំណូលពីការបែងចែកប្រាក់ចំណេញសហគ្រាសសាធារណៈ ជួបបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- សហគ្រាសមួយចំនួនសុំបង់មួយចំណែកតូច ឬរក្សាទុកទាំងអស់នៃប្រាក់ចំណេញសម្រាប់ការវិនិយោគ

បន្ត និងពង្រីកអាជីវកម្មរបស់ខ្លួន, (២)- ការផ្ទេរភាគលាភ ជាចំណែកថវិការដ្ឋមានការយឺតយ៉ាវដោយសារកង្វះសាច់ប្រាក់ ឬមានអតិថិជនជំពាក់ និង (៣)- ការទទួលខុសត្រូវនៅមានកម្រិតពីសំណាក់សមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋមួយចំនួនក្នុងការជួយជំរុញការបង់ភាគលាភរបស់សហគ្រាសចូលថវិការដ្ឋ។

**១៣១.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី:***

- សហគ្រាសសាធារណៈត្រូវរៀបចំផែនការ និងគោលនយោបាយអភិវឌ្ឍន៍រយៈពេលវែងឱ្យបានច្បាស់លាស់,
- ពង្រឹងតួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យអមសហគ្រាសនីមួយៗក្នុងការផ្តល់ព័ត៌មាន និងរបាយការណ៍លម្អិតស្តីពីស្ថានភាពហិរញ្ញវត្ថុ, ការគ្រប់គ្រងសហគ្រាស និងបញ្ហាសំខាន់ផ្សេងៗមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដាក់ជាវិធានការទាន់ពេលវេលា,
- រៀបចំកិច្ចប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ រវាងសមាជិកក្រុមប្រឹក្សាភិបាលជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, មន្ត្រីត្រួតពិនិត្យរដ្ឋ និងថ្នាក់ដឹកនាំសហគ្រាស ជាមួយនឹងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
- សហគ្រាសសាធារណៈទាំងអស់មានកាតព្វកិច្ចបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋ តាមការកំណត់នៃបទប្បញ្ញត្តិជាធរមាន,
- សហគ្រាសសាធារណៈ ត្រូវធ្វើសវនកម្មពេញលេញលើផ្នែកហិរញ្ញវត្ថុពីក្រុមហ៊ុនសវនកម្មឯកជនដែលមានការទទួលស្គាល់តាមផ្លូវច្បាប់នៅក្នុងប្រទេសកម្ពុជា និងតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
- ពង្រឹងការត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំ និងធ្វើការផ្ទៀងផ្ទាត់ស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌរបស់សហគ្រាសាធារណៈ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ ការតាមដាន និងការត្រួតពិនិត្យនឹងត្រូវធ្វើដោយក្រុមចម្រុះដែលមានការចូលរួមពីអគ្គនាយកដ្ឋានពន្ធដារ, អគ្គាធិការដ្ឋាន, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស។

***វិធានការរយៈពេលមធ្យម:***

- សិក្សា និងរៀបចំកែលម្អបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសហគ្រាសសាធារណៈ,
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសិក្សា និងដឹកនាំរៀបចំនិយាមលើមុខចំណាយសំរាប់សហគ្រាសនីមួយៗ។ ក្នុងករណីដែលសហគ្រាសមិនគោរពតាមនិយាមដែលបានកំណត់ សហគ្រាស និងមន្ត្រីពាក់ព័ន្ធត្រូវប្រឈមនឹងវិធានការវិន័យ និងទោសទណ្ឌជាធរមាន។

### ៥.៣.៩ គ្រឹះស្ថានសាធារណៈរដ្ឋបាល

**១៣២.** គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាស្ថាប័ន ដែលមានបេសកកម្មផ្នែកសេវាកម្មជាលក្ខណៈរដ្ឋបាល, សង្គមវប្បធម៌, វិទ្យាសាស្ត្រ ឬបច្ចេកទេស។ នាពេលបច្ចុប្បន្ននេះ គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល មាន

ចំនួន ២៥ ហើយដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអប់រំ យុវជន និងកីឡា, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងការពារជាតិ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ គ្រឹះស្ថានទាំងនេះមានប្រភពចំណូលមួយចំនួនពីការឧបត្ថម្ភធនពីថវិការដ្ឋសម្រាប់ដំណើរការរដ្ឋបាល និងវិនិយោគ ព្រមទាំងចំណូលពីការផ្តល់សេវាសាធារណៈ និងចំណូលផ្សេងៗទៀតរបស់ខ្លួន។

**១៣៣.** ក្នុងដំណាក់កាលចាប់ផ្តើមដំបូង រាជរដ្ឋាភិបាលធ្លាប់បានផ្តល់ភាពអនុគ្រោះដោយមិនតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលបង់ចំណូលចូលរដ្ឋ និងទុកថវិកាដែលនៅសេសសល់មួយចំនួនសម្រាប់កសាង និងអភិវឌ្ឍគ្រឹះស្ថាននៅពេលដែលគ្រឹះស្ថាននោះទើបតែចាប់ដំណើរការ។ រហូតមកដល់បច្ចុប្បន្ននេះ គ្រឹះស្ថានសាធារណៈរដ្ឋបាលមួយចំនួនមានការរីកចម្រើន និងវិវឌ្ឍស្របតាមការរីកចម្រើននៃប្រទេសជាតិ ដោយអាចរកចំណូលទ្រទ្រង់នូវប្រតិបត្តិការរបស់ខ្លួនផង វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ផង ព្រមទាំងមានអតិរេកសាច់ប្រាក់។ ទោះបីជាមានវឌ្ឍនភាពដូចនេះ គ្រឹះស្ថានសាធារណៈរដ្ឋបាលមួយចំនួននៅតែទទួលការឧបត្ថម្ភធនពីរាជរដ្ឋាភិបាល និងមិនមានចេតនាក្លាយទៅជាសហគ្រាសសាធារណៈ ដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុនោះឡើយ។

**១៣៤.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី:***

- ពង្រឹងតួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យអមគ្រឹះស្ថាននីមួយៗ ក្នុងការផ្តល់ព័ត៌មាន និងរបាយការណ៍លម្អិតស្តីពីស្ថានភាពហិរញ្ញវត្ថុ, ការគ្រប់គ្រងគ្រឹះស្ថាន និងបញ្ហាសំខាន់ផ្សេងៗមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចាត់វិធានការទាន់ពេលវេលា,
- រៀបចំកិច្ចប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ រវាងសមាជិកក្រុមប្រឹក្សាភិបាលជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, មន្ត្រីត្រួតពិនិត្យរដ្ឋ និងថ្នាក់ដឹកនាំគ្រឹះស្ថាន ជាមួយនឹងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
- ពិនិត្យកាត់បន្ថយតាមស្ថានភាពជាក់ស្តែងនូវឧបត្ថម្ភធនពីថវិការដ្ឋ សម្រាប់ដំណើរការរដ្ឋបាល ដូចជា ថ្លៃទឹក, ភ្លើង, ទូរស័ព្ទ, សំរាម និងចំណាយផ្សេងៗ ព្រមទាំងកាត់បន្ថយចំណាយវិនិយោគសេដ្ឋកិច្ច និងសង្គមដែលមិនមានប្រសិទ្ធភាព,
- ត្រួតពិនិត្យកិច្ចប្រតិបត្តិការទាំងចំណូល និងចំណាយជាប្រចាំ,
- ពង្រឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គ្រប់ប្រភពចំណូល និងចំណាយ រួមទាំងផែនការអភិវឌ្ឍន៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

***វិធានការរយៈពេលមធ្យម:***

- សិក្សា និងរៀបចំឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគ្រឹះស្ថានសាធារណៈរដ្ឋបាល រួមទាំងពិនិត្យលទ្ធភាពឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានអតិរេកសាច់ប្រាក់បង់ចូលថវិការដ្ឋ និងកែលម្អលក្ខន្តិកៈគតិយុត្តគ្រឹះស្ថានសាធារណៈ

រដ្ឋបាល ដើម្បីរៀបចំគ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន,

- ពិនិត្យលទ្ធភាពដាក់គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងឡាយណា ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាសហគ្រាសសាធារណៈ,
- ពិនិត្យលទ្ធភាពដាក់អង្គភាពរដ្ឋទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

### ៥.៣.១០ ធនធានធម្មជាតិ

**១៣៥.** ធនធានធម្មជាតិ ដែលមានរ៉ែ, ប្រេងកាត, ឧស្ម័ន, ខ្សាច់ និងសាច់ដី អាចនឹងក្លាយជាប្រភពចំណូលធំមួយសម្រាប់ចំណូលមិនមែនសារពើពន្ធ។ ចំណូលពីធនធានធម្មជាតិ គឺបានមកពីកម្រៃនៃការផ្តល់អាជ្ញាបណ្ណធនធានរ៉ែ, កិច្ចសន្យា ឬកិច្ចព្រមព្រៀងប្រេង, កម្រៃសួយសារនៃធនធានធម្មជាតិ និងសកម្មភាពផ្សេងៗទៀត។ វិស័យនេះមានសក្តានុពលខ្ពស់ក្នុងការប្រមូលចំណូលបន្ថែម ដោយសារសកម្មភាពអាជីវកម្មលើធនធានធម្មជាតិស្ថិតនៅក្នុងការរុករកនៅឡើយ។

**១៣៦.** វិស័យធនធានធម្មជាតិ នៅមានបញ្ហាប្រឈមមួយចំនួនដូចជា : (១)- ចំណូលបានមកពីសួយសារ និងកម្រៃពីសកម្មភាពរុករកនៅទាប, (២)- កិច្ចសហការរវាងក្រសួង-ស្ថាប័ន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅមានកម្រិតក្នុងការផ្តល់របាយការណ៍ និងកិច្ចសន្យា ដែលបង្កជាការលំបាកដល់មន្ត្រីទទួលបន្ទុកការងារនេះក្នុងការត្រួតពិនិត្យ និងវាយតម្លៃការប្រមូលប្រាក់ចំណូល និង (៣)- កិច្ចព្រមព្រៀង ឬកិច្ចសន្យាត្រូវបានសម្រេចដោយគ្មានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ទុយពីមាត្រា ១៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

**១៣៧.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- ក្រសួងរ៉ែ និងថាមពលត្រូវរៀបចំទិន្នន័យ និងប្រព័ន្ធតាមដានកាតព្វកិច្ចហិរញ្ញវត្ថុទៅលើកិច្ចសន្យា និងអាជ្ញាបណ្ណ ដែលក្រសួងបានធ្វើ ឬចេញទៅឱ្យនីតិបុគ្គល ឬរូបវន្តបុគ្គលឯកជន ដោយបញ្ជាក់ផងដែរនូវកិច្ចសន្យា ឬអាជ្ញាបណ្ណដែលបានចេញ, កំពុងអនុវត្ត និងមិនមានដំណើរការ និងការអនុវត្តកិច្ចសន្យា និងអាជ្ញាបណ្ណពាក់ព័ន្ធ,
- រាល់កិច្ចសន្យា និងអាជ្ញាបណ្ណពាក់ព័ន្ធនឹងការចាត់ចែងរ៉ែ និងថាមពល ត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីមានសុពលភាពគតិយុត្តស្របតាមមាត្រា ១៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ,
- ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធត្រូវផ្សព្វផ្សាយណែនាំដល់រូបវន្តបុគ្គល និងនីតិបុគ្គលឯកជនអំពីច្បាប់, បទប្បញ្ញត្តិជាធរមាន និងកាតព្វកិច្ចក្នុងការបង់សួយសារ និងចំណូលដទៃទៀតជូនរដ្ឋ,
- ពង្រឹងកិច្ចសហការបន្ថែមទៀតឱ្យកាន់តែមានប្រសិទ្ធភាពរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងរ៉ែ និងថាមពល, ក្រសួងធនធានទឹក និងឧតុនិយម, ធនាគារជាតិនៃកម្ពុជា, ធនាគារពាណិជ្ជ, អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងមន្ទីរជំនាញពាក់ព័ន្ធជាមួយក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ក្នុងការកំណត់ការបង់ចំណូលសួយសារ និងការជំរុញឱ្យបង់ចំណូលសួយសារលើអាជីវកម្មធនធានរ៉ែ, សាច់ដី និងខ្សាច់តាមអភិក្រមទីផ្សារ,

- រៀបចំ និងដាក់ឱ្យអនុវត្តយន្តការផាកពិន័យអន្តរការណ៍ ចំពោះបទល្មើសក្នុងវិស័យធនធានរ៉ែ។

*វិធានការរយៈពេលមធ្យម :*

- សិក្សា និងរៀបចំធ្វើការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណ និងកម្រៃសួយសារសម្រាប់ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទ,
- សិក្សា និងរៀបចំកំណត់សន្ទស្សន៍ថ្លៃផលិតផលរ៉ែសម្រាប់គោលដៅវាយតម្លៃសួយសាររ៉ែ។

### ៥.៣.១១ ចំណូលពីឯកជនភាវូបនីយកម្ម (ការលក់ -ដោះដូរ) និងការជួលទ្រព្យសម្បត្តិរដ្ឋ

**១៣៨.** ឯកជនភាវូបនីយកម្ម និងការជួលទ្រព្យសម្បត្តិរដ្ឋ បានចូលរួមចំណែកយ៉ាងច្រើន នៅក្នុងចំណូលថវិកាជាតិ។ នៅឆ្នាំ ២០១៣ ចំណូលពីឯកជនភាវូបនីយកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋមានចំនួន ២០៦ ពាន់លានរៀលស្មើនឹង ១៧,៥% ដែលបានធ្លាក់ចុះពីកម្រិត ១៩,១% នៃចំណូលមិនមែនសារពើពន្ធសរុបនៅឆ្នាំ ២០០៨។ ចំណូលពីវិស័យនេះត្រូវបានរំពឹងថានឹងធ្លាក់ចុះ ដោយសារការធ្វើឯកជនភាវូបនីយកម្មមិនបន្តស្ថិតនៅជាអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភាទៀតទេ។ ចំណូលពីការជួលសម្បត្តិរដ្ឋត្រូវបានប្រមូលទៅតាមតម្លៃ ដែលកំណត់ក្នុងកិច្ចសន្យានៃការជួល និងបង់ប្រាក់។ ដោយឡែក ចំណូលពីការជួលរួមចំណែកតិចតួចនៅក្នុងថវិការដ្ឋ។

**១៣៩.** បញ្ហាប្រឈមសំខាន់ៗនៅក្នុងវិស័យនេះស្ថិតនៅត្រង់ថា : (១)- ការធ្វើឯកជនភាវូបនីយកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋខ្លះមិនសមស្របតាមនីតិវិធីជាធរមាន និង (២)- ការកំណត់តម្លៃជួលទ្រព្យសម្បត្តិរដ្ឋមួយចំនួនមិនឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។

**១៤០.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម ÷

*វិធានការរយៈពេលខ្លី :*

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យជាក់ស្តែងលើលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ, ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យពិភាក្សាថ្លៃឈ្នួលឡើងវិញជាមួយភាគីជួល ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃទីផ្សារ និងឈរលើគោលការណ៍ស្រុះស្រួលគ្នា និងធានាផលប្រយោជន៍ដល់ភាគីទាំងសងខាង,
- ជំរុញឱ្យធ្វើបណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋទាំងអស់ ពិសេសទ្រព្យសម្បត្តិរដ្ឋ ដែលបានជួលឱ្យភាគីឯកជន។

*វិធានការរយៈពេលមធ្យម :*

- សិក្សា និងពិនិត្យលទ្ធភាពកែប្រែកិច្ចសន្យាមួយចំនួន ដែលមិនបានផ្តល់ផលប្រយោជន៍សមរម្យដល់ភាគីរដ្ឋ,
- រៀបចំការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋទាំងអស់,
- ជំរុញការធ្វើបណ្ណកម្មសិទ្ធិរាល់ទ្រព្យសម្បត្តិរដ្ឋទាំងអស់របស់ស្ថាប័នថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ,

- ជំរុញការចុះបញ្ជីសារពើភ័ណ្ឌលើទ្រព្យសម្បត្តិរដ្ឋទាំងអស់ រួមបញ្ចូលទាំងទ្រព្យ ដែលរឹបអូសបានពីបទល្មើសផ្សេងៗ, ការបញ្ចប់គម្រោងនានារបស់ស្ថាប័នថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ, អំណោយរបស់ដៃគូអភិវឌ្ឍន៍, អង្គការក្រៅរាជរដ្ឋាភិបាល និងសប្បុរសជននានា,
- ជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ដែលស្ថិតនៅក្រៅតារាងតម្លៃពន្ធអចលនទ្រព្យ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ,
- ជំរុញការចុះបញ្ជីសារពើភ័ណ្ឌនូវដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់។

### ៥.៣.១២ ចំណូលពីកាស៊ីណូ

**១៤១.** ប្រភពចំណូលដ៏សំខាន់មួយទៀតគឺចំណូលពីកាស៊ីណូ និងសកម្មភាពអាជីវកម្មផ្សេងៗក្នុងបរិវេណកាស៊ីណូ។ ចំណូលនេះបានមកពីកម្រៃនៃការចេញអាជ្ញាបណ្ណសម្រាប់ដំណើរការកាស៊ីណូ និងការបង់ចំណូលកាតព្វកិច្ចពីសកម្មភាពអាជីវកម្មល្បែងស៊ីសង និងមិនមែនល្បែងស៊ីសងគ្រប់ប្រភេទ។ ក្នុងឆ្នាំ ២០១៤ នេះ មានក្រុមហ៊ុនកាស៊ីណូចំនួន ៥៧ ត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ ឬ/និងបន្តសុពលភាពអាជ្ញាបណ្ណសម្រាប់ដំណើរការអាជីវកម្ម ក្នុងនោះ កាស៊ីណូចំនួន ១៨ ស្ថិតនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ, កាស៊ីណូចំនួន ២៩ ស្ថិតនៅតាមតំបន់ព្រំដែនកម្ពុជា-វៀតណាម, កាស៊ីណូចំនួន ០៨ នៅខេត្តព្រះសីហនុ, ចំនួន ០១ នៅលើភ្នំបូកគោ និងចំនួន ០១ នៅរាជធានីភ្នំពេញ។

**១៤២.** ចំណូលពីវិស័យកាស៊ីណូបានចូលរួមចំណែកមួយផ្នែកនៅក្នុងចំណូលមិនមែនសារពើពន្ធ។ ប៉ុន្តែវិស័យនេះ បានជួបបញ្ហាប្រឈមមួយចំនួន ដែលនៅក្នុងនោះបញ្ហាប្រឈមជាចម្បង គឺនត្ថិភាពនៃច្បាប់សម្រាប់ការគ្រប់គ្រងវិស័យកាស៊ីណូ និងបញ្ហាប្រឈមមួយចំនួនទៀត ដូចជា : (១)- កិច្ចសហប្រតិបត្តិការលើការអនុវត្តបទប្បញ្ញត្តិ ដែលមានស្រាប់រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃនៅមានកម្រិត, (២)- មន្ត្រីត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនមានអំណាចគ្រប់គ្រាន់ក្នុងការចាត់វិធានការបង្ក្រាបចំពោះសកម្មភាពល្បែងស៊ីសងខុសច្បាប់ និង (៣)- កាស៊ីណូភាគច្រើនស្ថិតនៅតំបន់ដាច់ស្រយាល ដែលជាតំបន់គ្មានការអភិវឌ្ឍអាជីវកម្ម និងជាកាស៊ីណូដែលមានទ្រង់ទ្រាយតូចៗ ហើយជាញឹកញាប់ត្រូវបានផ្អាកសកម្មភាពអាជីវកម្មវិញ។

**១៤៣.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- ខិតខំកៀរគរប្រមូលចំណូលឱ្យអស់លទ្ធភាពពីអាជីវកម្មល្បែងភ្នាល់គ្រប់ប្រភេទ ដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល,
- រៀបចំយន្តការទប់ស្កាត់ និងហាមឃាត់ជាដាច់ខាតនូវសកម្មភាពល្បែងភ្នាល់គ្រប់ប្រភេទ ដែលគ្មានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
- ពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលតាមរបបម៉ៅការ ក្នុងពេលរង់ចាំច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត។

***វិធានការរយៈពេលមធ្យម :***

- ជំរុញការរៀបចំ និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ។

### ៥.៣.១៣ ចំណូលពីការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O)

**១៤៤.** ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញជាប្រភពចំណូលដែលបានពីការបញ្ជាក់ប្រភពដើមកំណើតផលិតផលសម្រាប់ការនាំចេញទៅក្រៅប្រទេស។ ចំណូលនេះមានពីរប្រភេទ គឺចំណូលពីកម្រៃរដ្ឋបាល (Administrative Fee) និងចំណូលពីកម្រៃគ្រប់គ្រងការនាំចេញ (Export Management Fee)។ ប្រភពចំណូលនេះអាចកើតមានឡើង ដោយសារការនាំចេញនូវផលិតផលពីកម្ពុជា។ ចំណូលពីវិស័យនេះរំពឹងថានឹងកើនឡើងអាស្រ័យដោយការកើនឡើងនូវទំនិញនាំចេញ និងលក្ខខណ្ឌអនុគ្រោះពន្ធពីបណ្តាប្រទេសក្រៅ។ ក្នុងឆ្នាំ ២០១៣ ក្រសួងពាណិជ្ជកម្មបានប្រមូលចំណូលពីវិស័យនេះបានចំនួន ១២៧ ពាន់លានរៀល ហើយរំពឹងថា នៅឆ្នាំ ២០១៤ ចំណូលពីវិស័យនេះនឹងបន្តកើនឡើងបន្ថែមទៀត ទោះជាសហរដ្ឋអាមេរិកមិនតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដែលធ្វើឱ្យចំណូលពីកម្រៃរដ្ឋបាលមានការធ្លាក់ចុះខ្លះៗក៏ដោយ។ ជាមួយនឹងវឌ្ឍនភាពខាងលើវិស័យនេះនៅមានបញ្ហាប្រឈមមួយចំនួនរួមមាន : (១)- ភាពរអាក់រអួលផ្នែកវាយនភ័ណ្ឌ ដែលបង្កឡើងដោយក្រុមបាតុកម្ម និងកូដកម្មផ្សេងៗ ដែលនាំឱ្យការផលិតមានការធ្លាក់ចុះ និង (២)- ការបញ្ឈប់ការអនុគ្រោះពន្ធនាំចូលពីបណ្តាប្រទេសក្រៅ ដែលបណ្តាលឱ្យមានការធ្លាក់ចំណូលពីកម្រៃរដ្ឋបាល។

**១៤៥.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការ ដូចខាងក្រោម ÷

- ខិតខំជំរុញការអនុវត្តប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្មឱ្យមានប្រសិទ្ធភាព ដោយត្រូវផ្តល់សេវាសាធារណៈឱ្យបានល្អ និងមានតម្លាភាព ដើម្បីបង្កលក្ខណៈងាយស្រួល និងមានទំនុកចិត្តដល់អ្នកទទួលសេវា,
- ជំរុញការកត់ត្រាបញ្ជីគណនេយ្យស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃការប្រមូលចំណូល ព្រមទាំងអាចវាស់វែង និងវាយតម្លៃពីសមិទ្ធកម្ម,
- លើកកម្ពស់ការផ្តល់សេវាដល់ម្ចាស់រោងចក្រ-សហគ្រាស ដើម្បីជួយឱ្យដំណើរការផលិតកម្មបានល្អប្រសើរ និងទទួលបានបរិមាណផលិតផលខ្ពស់។

### ៥.៣.១៤ ចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

**១៤៦.** ចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមានដូចជា ភាស៊ីផ្សារ, ចំណតរថយន្ត, ភាស៊ីផ្សេងៗ និងសម្បទានដទៃទៀតរបស់រដ្ឋ។ ចំណូលផ្នែកនេះត្រូវបានគេរំពឹងថានៅមានសក្តានុពលកើនឡើងបន្តទៀត។ ការប្រមូលចំណូលនៅក្នុងវិស័យនេះជួបបញ្ហាប្រឈមមួយចំនួនគឺ : (១)- កង្វះការទទួលខុសត្រូវពេញលេញរបស់អង្គភាពជំនាញ និងអាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុក និង (២)- ការផ្តល់កិច្ចសន្យាវិនិយោគ និងកិច្ចសន្យាសម្បទានមួយចំនួនមិនបានគោរពតាមបទប្បញ្ញត្តិស្តីពីនីតិវិធីហិរញ្ញវត្ថុ។

**១៤៧.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- ពង្រឹងការគោរពតាមបទប្បញ្ញត្តិស្តីពីនីតិវិធីហិរញ្ញវត្ថុនៅក្នុងការផ្តល់កិច្ចសន្យាវិនិយោគ និងកិច្ច-សន្យានានារួមមានទាំងវិធានការដាក់ទោសទណ្ឌ ចំពោះអង្គភាពដែលមិនគោរពតាមនីតិវិធីជាធរមានផងដែរ,

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចាត់មន្ត្រីជំនាញចុះពិនិត្យការអនុវត្តសៀវភៅបន្ទុក និងកិច្ចសន្យាសម្បទានទ្រព្យសម្បត្តិសាធារណៈគ្រប់ប្រភេទយ៉ាងតិច ២ ដង ក្នុង ១ ឆ្នាំ ដើម្បីចាត់វិធានការឱ្យបានទាន់ពេលវេលា,
- អាជ្ញាធររាជធានី-ខេត្តត្រូវដឹកនាំ និងសហការជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ត្រួតពិនិត្យជាប្រចាំ លើការអនុវត្តសៀវភៅបន្ទុកសម្បទាននានាដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន,
- រៀបចំ និងដាក់ឱ្យអនុវត្តយន្តការព្រមានជាដំណាក់កាល និងដកអាជ្ញាបណ្ណអាជីវកម្ម ឬលុបចោលកិច្ចសន្យាភាស៊ី ក្នុងករណីមិនគោរពតាមនីតិវិធីហិរញ្ញវត្ថុ,
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពង្រឹងការរៀបចំផែនការចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋប្រចាំឆ្នាំនីមួយៗ ដោយសហការជាមួយអាជ្ញាធរខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។

## ៦. ការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន

**១៤៨.** ការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានការគិតគូរលើការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន ដោយផ្តោតលើ : (១)- ការកែលម្អប្រព័ន្ធសារពើពន្ធ និងមិនមែនសារពើពន្ធ, (២)- ការពង្រឹងយន្តការស្ថាប័ន ដោយផ្តោតលើការចែករំលែក និងផ្តល់ព័ត៌មានរវាងស្ថាប័ន ព្រមទាំងយន្តការសម្របសម្រួលគោលនយោបាយ និងយន្តការដោះស្រាយវិវាទសារពើពន្ធ និង (៣)- ការកែលម្អគោលនយោបាយ និងក្របខ័ណ្ឌអនុវត្តលើចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមួយចំនួន។

### ៦.១. ការកែលម្អប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

**១៤៩.** ដោយឈរលើគោលការណ៍ចៀសវាងការបង្កើតប្រភេទពន្ធថ្មី, មិនដំឡើងអត្រាពន្ធ និងអាករ, និងធានាឱ្យបាននូវភាពងាយស្រួល, សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព, តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងការប្រមូលចំណូល និងឆ្លើយតបទៅនឹងកម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលបច្ចុប្បន្ន យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ នេះនឹងផ្តោតជារួម និងជាសំខាន់ទៅលើការប្រមូលឱ្យអស់លទ្ធភាពនូវសក្តានុពលចំណូល ដែលមាននាពេលបច្ចុប្បន្ន នៅក្នុងក្របខ័ណ្ឌគោលនយោបាយសារពើពន្ធដែលមានស្រាប់។

**១៥០.** នាពេលអនាគតខាងមុខ ជាពិសេសបន្ទាប់ពីឆ្នាំ ២០១៨ នៅពេលដែលការប្រមូលចំណូលពីសក្តានុពលចំណូល ដែលមាននាពេលបច្ចុប្បន្ន ឈានដល់កម្រិតអតិបរមា និងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនាពេល ១០ ឆ្នាំ ខាងមុខបន្តទៀត រាជរដ្ឋាភិបាលចាំបាច់ត្រូវពិនិត្យ និងកែលម្អឡើងវិញនូវប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ សំដៅធ្វើឱ្យប្រព័ន្ធនេះក្លាយទៅជាគ្នាស់សេដ្ឋកិច្ចមួយយ៉ាងពិតប្រាកដ ដែលនឹងដើរតួយ៉ាងសំខាន់ក្នុងការបង្កើតការងារជូនប្រជាពលរដ្ឋ, ការទាក់ទាញការវិនិយោគ, ការផ្តល់នូវសមធម៌ និងយុត្តិធម៌, ការធានាប្រសិទ្ធភាព, តម្លាភាព និងគណនេយ្យភាពក្នុងការប្រមូលចំណូល, ការបង្កើនចំណូលបានទៅតាមសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាល និងការបម្រើបានប្រកបដោយប្រសិទ្ធភាពលើគោលនយោបាយផ្សេងៗ ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល។

**១៥១.** ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនាពេល ១០ ឆ្នាំ ខាងមុខបន្តទៀត វិធានការចាំបាច់ដែលត្រូវដាក់ចេញ គឺសិក្សា និងរៀបចំឯកសារគោល (Blueprint) ស្តីពីការកែលម្អប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។

### ៦.២ ការពង្រឹងយន្តការស្ថាប័ន

**១៥២.** ការសម្របសម្រួលគោលនយោបាយ និងការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិរវាងស្ថាប័នប្រមូលចំណូល ដូចជា អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ គឺជាកត្តាស្នូលនៃការលើកកម្ពស់លទ្ធផលការងារ ក៏ដូចជាការបង្កើននូវប្រសិទ្ធភាពរបស់រដ្ឋបាលចំណូលដែលពាក់ព័ន្ធទាំងអស់។ ទន្ទឹមនេះ ការផ្តល់ទិន្នន័យ និងព័ត៌មានស្តីពីការចុះបញ្ជី, ការចុះកិច្ចសន្យា, ការទទួលបានសម្បទាន និងការដេញថ្លៃ

ពី ឬជាមួយរាជរដ្ឋាភិបាលពីស្ថាប័នចំណាយ ដូចជា អគ្គនាយកដ្ឋានលទ្ធកម្ម, អគ្គនាយកដ្ឋានរតនាគារជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងពាណិជ្ជកម្ម, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួង-ស្ថាប័នទាំងអស់ជូនដល់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងជួយសម្រួល និងពន្លឿនការងារប្រចាំថ្ងៃរបស់អគ្គនាយកដ្ឋានទាំងពីរ ក៏ដូចជាការធ្វើសវនកម្មទៅលើសកម្មភាពជំនួញរបស់អ្នកជាប់ពន្ធ។

**១៥៣.** ក្រៅពីកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រសិទ្ធភាពនៃរដ្ឋបាលចំណូលក៏ពឹងផ្អែកទៅលើកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន។ នាពេលកន្លងមក រាជរដ្ឋាភិបាលបានរៀបចំ និងអនុវត្តយន្តការមួយចំនួន ដូចជា វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន, ក្រុមការងារពន្ធដារដែលស្ថិតនៅក្រោមក្រុមការងារផ្នែកនីតិកម្ម, ពន្ធដារ និងអភិបាលកិច្ច, គណៈកម្មការពិគ្រោះយោបល់ពាណិជ្ជកម្មរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ល។ ដើម្បីជួយដោះស្រាយនូវកង្វល់ និងការលំបាកនានារបស់វិស័យឯកជន ក៏ដូចជាពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន។

**១៥៤.** ជារួម ស្ថានភាពនៃការសម្របសម្រួលគោលនយោបាយ ព្រមទាំងការចែករំលែក និងផ្តល់ទិន្នន័យ និងព័ត៌មានរវាងស្ថាប័នចំណូល និងចំណាយនាពេលបច្ចុប្បន្នកំពុងជួបបញ្ហាប្រឈមមួយចំនួន និងជាបញ្ហាទូទៅមួយដែលមិនបានទទួលនូវការដោះស្រាយប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ជាក់ស្តែង បើទោះជាមានអនុស្សារណៈយោគយល់គ្នាលើការចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាដែលបានបញ្ញត្តថារាល់សំណើសុំព័ត៌មាន អគ្គនាយកដ្ឋានទាំងពីរត្រូវធ្វើការចែករំលែកគ្នាទៅវិញទៅមកក៏ដោយ ក៏ដំណើរការឆ្លើយតបទៅនឹងការស្នើសុំព័ត៌មានមានរយៈពេលយូរ និងព័ត៌មានដែលផ្តល់ឱ្យនៅពុំមានលក្ខណៈឆ្លើយតបទៅនឹងសំណើ។ ការផ្តល់ទិន្នន័យ និងព័ត៌មានពីស្ថាប័នផ្សេងទៀត ដូចជា ពីអគ្គនាយកដ្ឋានលទ្ធកម្ម, អគ្គនាយកដ្ឋានរតនាគារជាតិ និងស្ថាប័នផ្សេងៗជូនទៅស្ថាប័នដទៃទៀតក៏នៅមានកម្រិត។ លើសពីនេះទៀត ការសម្របសម្រួលគោលនយោបាយសារពើពន្ធនៅមិនទាន់បានរៀបចំ និងដាក់ឱ្យអនុវត្តនៅឡើយ។ ទន្ទឹមនេះ ទោះបីជាមានយន្តការជាច្រើន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរបស់ស្ថាប័នរដ្ឋ និងវិស័យឯកជន មកដល់ពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលនៅមិនទាន់បានរៀបចំយន្តការដោះស្រាយវិវាទសារពើពន្ធនៅឡើយ។

**១៥៥.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

- ដាក់ឱ្យដំណើរការឡើងវិញនូវការប្រជុំជាប្រចាំរបស់ក្រុមការងារចម្រុះ ពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ដោយចាត់តាំងថ្នាក់ដឹកនាំជាន់ខ្ពស់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយរូប ដើម្បីដឹកនាំការប្រជុំនេះ និងធានាពង្រឹងការអនុវត្តការងាររបស់ក្រុមការងារនេះ និងធ្វើការត្រួតពិនិត្យ ព្រមទាំងវាយតម្លៃកិច្ចសហការរបស់អគ្គនាយកដ្ឋានទាំងពីរ,
- កិច្ចសន្យាសម្បទាន, កិច្ចសន្យាលទ្ធកម្ម, កិច្ចសន្យាផ្សេងៗ, កិច្ចព្រមព្រៀង, ទិន្នន័យនៃការចុះបញ្ជីអចលនទ្រព្យ, ទិន្នន័យនៃការចុះបញ្ជីយានយន្ត ឬលិខិតអនុញ្ញាត ព្រមទាំងឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងកាតព្វកិច្ចពន្ធ និងអាករ និងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋទាំងអស់ រវាងអ្នកជាប់ពន្ធជាមួយរាជរដ្ឋាភិបាល ត្រូវតែផ្តល់ជូនអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា,

- បង្កើតក្រុមការងារដើម្បីសិក្សាអំពីលក្ខខណ្ឌ, វិសាលភាព និងតម្រូវការព័ត៌មានរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងការចែករំលែកព័ត៌មានផ្ទាល់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន,
- បង្កើត និងដាក់ឱ្យដំណើរការគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដើម្បីធ្វើការកែសម្រួលរចនាសម្ព័ន្ធពន្ធនាំចេញ-នាំចូល និងមូលដ្ឋានគិតពន្ធ ដោយមានការគិតគូរច្បាស់លាស់ពីទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម ដោយឈរលើគោលការណ៍សមធម៌, យុត្តិធម៌សង្គម, ប្រសិទ្ធភាពសេដ្ឋកិច្ច, តម្លាភាព និងគណនេយ្យភាព,
- រៀបចំអនុក្រឹត្យស្តីពីគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ ដើម្បីដោះស្រាយវិវាទសារពើពន្ធ។

## ៦.៣. ការកែលម្អគោលនយោបាយ និងក្របខ័ណ្ឌអនុវត្តលើចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមួយចំនួន

**១៥៦.** ការកែសម្រួលគោលនយោបាយសារពើពន្ធ និងក្របខ័ណ្ឌអនុវត្តនៅក្នុងយុទ្ធសាស្ត្រនេះនឹងផ្តោតលើការកែសម្រួលគោលនយោបាយ និងក្របខ័ណ្ឌនៃការអនុវត្តចាំបាច់មួយចំនួន ដូចជា របបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, ទំហំផលរបរត្រូវជាប់ក្នុងរបបស្វ័យប្រកាស និងអត្រាអាករពិសេសលើមុខទំនិញសំខាន់ៗ ជាដើម។ ដូចបានគូសបញ្ជាក់ពីខាងដើម ការធ្វើឱ្យប្រសើរឡើងគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធជាទូទៅមានគោលដៅធ្វើការប៉ះប៉ូវដល់ការបាត់បង់នូវចំណូលមួយចំនួន និងធ្វើសាមញ្ញកម្មចំពោះប្រព័ន្ធពន្ធ, ធានាសមធម៌ និងយុត្តិធម៌ និងរក្សាស្ថិរភាព, តម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាពនៃការប្រមូលចំណូល ព្រមទាំងធានានូវភាពរលូន និងសង្គតិភាពក្នុងការអនុវត្តកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ពិសេសពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មសេដ្ឋកិច្ច។ ជាក់ស្តែង គោលនយោបាយ និងក្របខ័ណ្ឌអនុវត្តនៃចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធដែលជាកម្មវត្ថុនៃការកែលម្អរួមមានជាអាទិ៍ : (១)- អាករពិសេសលើទំនិញ និងសេវាមួយចំនួន, (២)- ការអនុវត្តអាករលើតម្លៃបន្ថែម, (៣)- របបម៉ៅការ, (៤)- ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តពន្ធដល់គម្រោងវិនិយោគ, (៥)- កិច្ចព្រមព្រៀងពន្ធអន្តរជាតិ ពិសេសការចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA), (៦)- ពន្ធលើអចលទ្រព្យ, (៧)- ពន្ធលើចំណូលរូបវន្តបុគ្គល, (៨)- ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ, (៩)- ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពន្ធដារមួយចំនួន ដើម្បីធានាភាពរលូនក្នុងការអនុវត្ត, (១០)- ការអនុវត្តវិធានការ ដើម្បីប៉ះប៉ូវដល់ការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀត និង (១១)- ការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

### ៦.៣.១ អាករពិសេសលើទំនិញ និងសេវាមួយចំនួន

**១៥៧.** គោលដៅយុទ្ធសាស្ត្រនៃការកែសម្រួលអាករពិសេស គឺ : (១)- បង្កើនចំណូលពន្ធសម្រាប់គោលបំណងជារួមផង និងប៉ះប៉ូវដល់ការបាត់បង់ចំណូលពីការលុបបំបាត់ ឬកាត់បន្ថយពន្ធលើពាណិជ្ជកម្មអន្តរជាតិដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផង, (២)- ឆ្លុះបញ្ចាំងចំណាយប្រើប្រាស់ ឬចំណាយផលិតពីប្រភពខាងក្រៅ ដែលមិនបានរួមបញ្ចូលក្នុងតម្លៃទំនិញ, (៣)- ជំរុញការកាត់បន្ថយនៃការប្រើប្រាស់ទំនិញ និងសេវាមួយចំនួនដែលប៉ះពាល់ដល់សុខភាព, សង្គម, បរិស្ថាន និងមានភាពប្រណិត និង (៤)- បង្កើនប្រសិទ្ធភាពនៃប្រព័ន្ធពន្ធប្រកបដោយគណនេយ្យភាព និងតម្លាភាព។

១៥៨. ទោះបីជាចំណូលពីអាករពិសេសលើទំនិញ និងសេវាមួយចំនួនពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់ក៏ដោយ ក៏ការគ្រប់គ្រង និងប្រមូលអាករពិសេសនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- រោងចក្រផលិតទំនិញនៅក្នុងស្រុកមួយចំនួន ដូចជា ស្រា, ស្រាបៀរ, បារី, ភេសជ្ជៈគ្រប់ប្រភេទ។ល។ នៅមិនទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធត្រឹមត្រូវតាមច្បាប់នៅឡើយ, (២)- អគ្គនាយកដ្ឋានពន្ធដារមិនទាន់បានដាក់មន្ត្រីពន្ធដារប្រចាំការនៅគ្រប់រោងចក្រផលិតផលិតផលជាប់អាករពិសេសក្នុងស្រុកមួយចំនួន, (៣)- គោលនយោបាយលើកលែងអាករពិសេសចំពោះគម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, (៤)- អត្រាអាករពិសេសទាបបើប្រៀបធៀបការប្រមូលអាករពិសេសជាមួយបណ្តាប្រទេស ដែលជាសមាជិកអាស៊ាន, (៥)- ការផលិតក្នុងស្រុកជំនួសឱ្យការនាំចូលចំពោះទំនិញ ដែលជាប់អាករពិសេសមួយចំនួន និង (៦)- កង្វះប្រសិទ្ធភាពសមស្របក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទំនិញនាំចូលដែលជាប់អាករពិសេស។

១៥៩. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការពង្រឹងយន្តការអនុវត្ត និងការកែសម្រួលគោលនយោបាយ ត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- បន្តពង្រឹងការដាក់មន្ត្រីពន្ធដារប្រចាំការនៅតាមរោងចក្រផលិតផលិតផលក្នុងស្រុក ដែលត្រូវជាប់អាករពិសេស ដូចជា ស្រា, ស្រាបៀរ, បារី, ភេសជ្ជៈគ្រប់ប្រភេទ។ល។,
- រៀបចំប្រកាសស្តីពីការកំណត់ឱ្យបិទតែមប្រើលើទំនិញជាប់អាករពិសេសមួយចំនួនទៀត,
- ពិនិត្យលទ្ធភាពនៃការដំឡើងអាករពិសេសលើទំនិញអេឡិចត្រូនិច និងផលិតផលប្លាស្ទិកបន្ថែមទៀត។

***វិធានការរយៈពេលមធ្យម :***

- ពិនិត្យឡើងវិញលើបញ្ជីទំនិញនាំចូលដែលត្រូវជាប់អាករពិសេស,
- ដំឡើងអត្រា និងកែប្រែមូលដ្ឋានគិតអាករពិសេសលើមុខទំនិញប៉ះពាល់សុខភាពមួយចំនួន ដូចជា បារី, ស្រា, ស្រាបៀរ និងភេសជ្ជៈមានជាតិអាល់កុល,
- ធ្វើការសិក្សាលើការកែរបៀបយកពន្ធពីការយកពន្ធតាមអត្រា ទៅជាការយកពន្ធតាមឯកតាជាមួយនឹងការបង់អាករពិសេសចាប់ពីកម្រិតអប្បបរមាមួយ,
- រៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអាករពិសេស ឬរដ្ឋាករ។

### ៦.៣.២ អាករលើតម្លៃបន្ថែម

១៦០. ចំណូលអាករលើតម្លៃបន្ថែមប្រមូលបានសរុបប្រមាណជា ៤% នៃ ផសស ក្នុងឆ្នាំ ២០១៣ ដែលក្នុងនោះ អគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ១,៧% នៃ ផសស។ ចំណូលអាករនេះមានកម្រិតទាបនៅឡើយ បើធៀបជាមួយប្រទេសមួយចំនួនក្នុងតំបន់។ ការប្រមូលអាករលើតម្លៃបន្ថែមមានកម្រិតទាបនេះ ដោយសារនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ទំហំផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធក្នុងរបបស្វ័យប្រកាសនៅមានកម្រិតខ្ពស់ ពោលគឺផលរបរប្រចាំឆ្នាំលើសពី ៥០០ លានរៀល (១២៥.០០០ ដុល្លារអាមេរិក) ចំពោះការផ្គត់ផ្គង់ទំនិញ ឬផលរបរលើសពី ២៥០ លានរៀល (៦២.៥០០ ដុល្លារអាមេរិក) ចំពោះការផ្គត់ផ្គង់សេវា ឬផលរបរលើសពី ១២៥ លានរៀល (៣១.២៥០ ដុល្លារអាមេរិក) ចំពោះការផ្គត់ផ្គង់ទំនិញ និងសេវាជាមួយរដ្ឋ បើប្រៀបធៀបនឹងប្រទេសដទៃទៀត ដូចជា ប្រទេសថៃ ៣០.០០០ ដុល្លារអាមេរិក, ហ្វីលីពីន ១៤.០០០ ដុល្លារអាមេរិក, វៀតណាម ០ (គ្មានកម្រិត

ផលរបរ), ណូវែលហ្សេឡង់ ២៧.៣៤០ ដុល្លារអាមេរិក, អូស្ត្រាលី ៣៦.៦៨៤ ដុល្លារអាមេរិក, ចិន ២.៩៧៤-៧.៤៣៦ ដុល្លារអាមេរិក, កូរ៉េ 0 (គ្មានកម្រិតផលរបរ) និង (២)- ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យ ដែលមិនមានចែងក្នុងច្បាប់សារពើពន្ធ។

**១៦១.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- រៀបចំកែប្រែអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត។

***វិធានការរយៈពេលមធ្យម :***

- បញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យ ដែលមិនមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ,
- បង្កើតយន្តការបង្វិលសងចំពោះការទិញទំនិញនាំចេញដោយជនបរទេសនៅអាកាសយានដ្ឋានអន្តរជាតិ។

### ៦.៣.៣ របបម៉ៅការ

**១៦២.** អ្នកជាប់ពន្ធតាមរបបម៉ៅការ គឺជាអ្នកជាប់ពន្ធតូចៗ ដែលមិនស្ថិតនៅក្នុងរបបពន្ធស្វ័យប្រកាស ដែលគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម។ អ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវបង់អាករលើផលរបរ ២% និងបង់ពន្ធលើប្រាក់ចំណេញតាមអត្រាកំណើនតាមថ្នាក់ពី 0% ដល់ ២0% ជារៀងរាល់ខែ។ ការប្រមូលពន្ធក្នុងរបបម៉ៅការមានបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ការបង់ប្រាក់ពន្ធមិនមានតម្លាភាព ពីព្រោះត្រូវបង់តាមការពិភាក្សា និងយល់ព្រមរវាងអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារ ហើយអាចធ្វើការកែប្រែការកំណត់ពន្ធនេះក្នុងរយៈពេល ៣ខែ, ៦ខែ, ឬ ១ឆ្នាំ ដែលកត្តានេះអាចនឹងបង្កឱ្យមានវិសមភាពក្នុងចំណោមអ្នកជាប់ពន្ធ, (២)- កម្រិតផលរបរប្រចាំឆ្នាំជាប់ពន្ធតាមរបបស្វ័យប្រកាសខ្ពស់ធ្វើឱ្យចំនួនអ្នកជាប់ពន្ធក្នុងរបបម៉ៅការច្រើន និងមន្ត្រីពន្ធដារនៅតាមសាខាខេត្ត-ខណ្ឌ បម្រើការងារប្រមូលពន្ធតាមរបបម៉ៅការមានចំនួនច្រើន ប៉ុន្តែប្រមូលប្រាក់ពន្ធបានតិច និង (៣)- អ្នកជាប់ពន្ធមួយចំនួនក្នុងរបបម៉ៅការ ដែលមានកម្រិតផលរបរត្រូវជាប់ពន្ធក្នុងរបបស្វ័យប្រកាសមិនចង់ចុះបញ្ជីក្នុងរបបស្វ័យប្រកាសទេ ដោយសារការកើនបន្ទុកចំណាយក្នុងការកាន់កាប់បញ្ជីគណនេយ្យ, ការត្រូវបង់អាករលើតម្លៃបន្ថែម ១០% រួមទាំងពន្ធដទៃទៀតច្រើនជាងរបបម៉ៅការ និងការត្រូវធ្វើសវនកម្មនាពេលក្រោយ។

**១៦៣.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- រៀបចំបទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ រួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញក្នុងមួយឆមាសម្តង ឬមួយឆ្នាំម្តង ដើម្បីបន្ថយបន្ទុករបស់អ្នកជាប់ពន្ធ និងផ្ទេរមន្ត្រីទៅបម្រើការងារនៅកន្លែង ដែលមានចំណូលខ្ពស់,
- ធ្វើយុទ្ធនាការផ្ទេរអ្នកជាប់ពន្ធក្នុងរបបម៉ៅការ ដែលមានកម្រិតផលរបរត្រូវជាប់ពន្ធក្នុងរបបស្វ័យប្រកាសឱ្យចូលក្នុងរបបស្វ័យប្រកាស,

- រៀបចំ និងដាក់ឱ្យអនុវត្តនូវរបបស្វ័យប្រកាសបំពេញ និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ។

### ៦.៣.៤ ពិនិត្យឡើងវិញរបបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគ

**១៦៤.** គោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានដាក់ចេញតាមរយៈច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៤ និងបានធ្វើវិសោធនកម្មក្នុងឆ្នាំ ២០០៣។ គោលនយោបាយនេះមានគោលបំណងទាក់ទាញការវិនិយោគពីបរទេស ក្នុងខណៈដែលការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅមានកម្រិតទាប, ឧស្សាហកម្មនៅមានភាពទន់ខ្សោយ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅមានលក្ខណៈមិនគ្រប់គ្រាន់។ យោងតាមការសិក្សាស្រាវជ្រាវបឋម រាជរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធនាំចូលដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាមធ្យមក្នុងមួយឆ្នាំប្រមាណជាង ៣% នៃ ផសស ពីឆ្នាំ ២០០៤-២០១២ និងការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញជាមធ្យមប្រមាណ ០,៤% នៃ ផសស ពីឆ្នាំ ២០០៩-២០១១។ ការលើកទឹកចិត្តពន្ធនេះបានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចតាមរយៈការបង្កើតការងារជូនប្រជាពលរដ្ឋ ជាពិសេសក្នុងវិស័យឧស្សាហកម្មអតិពលកម្ម ដែលសរុបមានពលករប្រមាណ ៦០០ ពាន់នាក់ និងការបង្កើតការងារប្រយោលមួយចំនួនទៀត។

**១៦៥.** នាពេលបច្ចុប្បន្ន សភាពការវិវត្តន៍ថ្មីៗរបស់កម្ពុជា រួមមាន ៖ កំណើនសេដ្ឋកិច្ចមានកម្រិតខ្ពស់, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផលិតភាពពលករមានការរីកចំរើនជាលំដាប់ ជាមួយនិងការរៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មក្នុងគោលដៅចាប់យកវិស័យឧស្សាហកម្ម ដែលមានតម្លៃបន្ថែម និងជំនាញខ្ពស់ បានតម្រូវឱ្យមានការគិតគូរ និងរៀបចំឡើងវិញនូវគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

**១៦៦.** ឆ្លើយតបទៅនឹងតម្រូវការខាងលើ វិធានការចាំបាច់ដែលត្រូវដាក់ចេញ គឺការពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគ ដោយបញ្ចូលការលើកទឹកចិត្តពន្ធក្នុងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

### ៦.៣.៥ កិច្ចព្រមព្រៀងពន្ធអន្តរជាតិ

**១៦៧.** កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា គឺជាកិច្ចព្រមព្រៀងទ្វេភាគីមានភាពស្មុគស្មាញដែលធ្វើឡើងក្នុងគោលដៅមួយចំនួន រួមមាន ៖ (១)- លុបចោលនូវរបាំងពន្ធសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគឆ្លងប្រទេស, (២)- លុបចោល ឬបន្ថយការយកពន្ធត្រួតគ្នាទៅលើនិវាសនជន ដែលមាននិវាសនដ្ឋាននៅក្នុងប្រទេសចុះកិច្ចសន្យាទាំងពីរ, (៣)- ទប់ស្កាត់ និងប្រឆាំងអំពើចៀសវាងពន្ធ និងគេចវេសពន្ធ, (៤)- បង្កើតយន្តការដោះស្រាយជម្លោះ ដែលកើតឡើងដោយការបង់ពន្ធត្រួតគ្នា, (៥)- ធ្វើឱ្យមានភាពប្រាកដប្រជាក្នុងការបង់ពន្ធ, (៦)- ធ្វើឱ្យមានការកាត់បន្ថយមូលដ្ឋាន និងអត្រាពន្ធមួយចំនួន, (៧)- ធ្វើឱ្យមានការថយចុះចំណាយដើម្បីបំពេញកាតព្វកិច្ចបង់ពន្ធ, (៨)- លើកទឹកចិត្តឱ្យមានការហូរចូលការវិនិយោគបរទេស, (៩)- ផ្លាស់ប្តូរព័ត៌មានរវាងប្រទេសចុះកិច្ចព្រមព្រៀង និង (១០)- បែងចែក និងកំណត់សិទ្ធិ និងអធិបតេយ្យយកពន្ធរវាងប្រទេស ដែលចុះកិច្ចព្រមព្រៀង។ល។

**១៦៨.** បច្ចុប្បន្ននេះ ប្រទេសកម្ពុជាពុំទាន់បានចុះកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយប្រទេសណាមួយឡើយ ដោយសារ ៖ (១)- ការចរចាជាមួយប្រទេសដៃគូតម្រូវឱ្យមានការសិក្សាច្បាស់លាស់ជាមុនដើម្បីចៀសវាងការបាត់បង់ចំណូលពន្ធ និងតម្រូវឱ្យមានក្របខ័ណ្ឌគោលនយោបាយ និងគំរូកិច្ចព្រមព្រៀងពន្ធមួយ

ច្បាស់លាស់, (២)- សមត្ថភាពមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារនៅមានកម្រិតសម្រាប់ការរៀបចំកិច្ចព្រមព្រៀង ដើម្បីកំណត់សិទ្ធិយកពន្ធរបស់ភាគីចុះកិច្ចព្រមព្រៀង ដែលជាកិច្ចការស្មុគស្មាញ ដោយតម្រូវឱ្យអ្នកចូលរួមចរចាត្រូវមានចំណេះដឹងខ្ពស់លើគំរូកិច្ចព្រមព្រៀងរបស់អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ និងគំរូរបស់អង្គការសហប្រជាជាតិ និង (៣)- អគ្គនាយកដ្ឋានពន្ធដារមានការកែទម្រង់សារពើពន្ធជាច្រើនក្នុងពេលតែមួយ ជាហេតុធ្វើឱ្យការរៀបចំកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាមានភាពយឺតយ៉ាវ។

**១៦៩.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួន ត្រូវដាក់ចេញ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- ជំរុញក្រុមការងារអន្តរក្រសួង ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកនាំមុខ និងក្រុមការងារកម្រិតបច្ចេកទេស ដើម្បីរៀបចំធ្វើការចរចាជាមួយប្រទេសជាដៃគូ,
- ជ្រើសរើសប្រទេសសម្រាប់ធ្វើការចរចាដំបូង និងបន្តបន្ទាប់ទៀត ពិសេសប្រទេសអាស៊ាន និងប្រទេស ដែលមានការវិនិយោគច្រើននៅកម្ពុជា,
- រៀបចំបទប្បញ្ញត្តិដែលពាក់ព័ន្ធ ដើម្បីធ្វើវិសោធនកម្មបទប្បញ្ញត្តិនានាដែលខ្វះចន្លោះ,
- បង្កើនចំនួនមន្ត្រី និងបន្តធ្វើការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ដំណើរការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា។

***វិធានការរយៈពេលមធ្យម :***

- បន្តធ្វើការចរចា និងចុះកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយបណ្តាប្រទេសក្នុងអាស៊ាន និងប្រទេសដទៃទៀត,
- បន្តការងារពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការងារនេះ។

### ៦.៣.៦ ពន្ធលើអចលនទ្រព្យ

**១៧០.** ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ បានកំណត់ថាការប្រមូលពន្ធលើអចលនទ្រព្យមានវិសាលភាពអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ចំពោះតែអចលនទ្រព្យ ដែលមានតម្លៃលើសពី ១០០ លានរៀល តាមអត្រាពន្ធ ០,១% និងមូលដ្ឋានគិតពន្ធត្រឹមតែ ៨០% នៃតម្លៃអចលនទ្រព្យសរុប។ ប្រភេទពន្ធនេះបានចាប់អនុវត្តក្នុងឆ្នាំ ២០១១ សម្រាប់ថវិការាជធានី-ខេត្ត ជាមួយនឹងការលើកលែងពន្ធមួយចំនួន។ ក្នុងឆ្នាំ ២០១១ ពន្ធអចលនទ្រព្យប្រមូលបានចំនួន ៤៨,៧៨ ពាន់លានរៀល ឬប្រមាណ ១២,២ លានដុល្លារអាមេរិក និងកើនឡើងដល់ចំនួន ៦០,៤៧ លានរៀល ឬប្រមាណ ១៥ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៣។

**១៧១.** ការប្រមូលពន្ធអចលនទ្រព្យនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ពន្ធអចលនទ្រព្យអនុវត្តតែទៅលើអចលនទ្រព្យនៅក្នុងភូមិសាស្ត្រខណ្ឌនៃរាជធានីភ្នំពេញ និងក្រុងនៃខេត្ត ដោយមិនទាន់អនុវត្តបានទូទាំងប្រទេសនៅឡើយ, (២)- អចលនទ្រព្យមួយចំនួននៅមិនទាន់បានប្រកាសបង់ពន្ធនៅឡើយ, (៣)- ប្រភេទពន្ធអចលនទ្រព្យនេះមិនទាន់ត្រូវបានធ្វើសវនកម្ម និងមិនទាន់មានការដាក់ទោសទណ្ឌចំពោះម្ចាស់អចលនទ្រព្យ ដែលមិនទាន់បានប្រកាស និងបង់ពន្ធនៅឡើយ និង (៤)- មិនទាន់មានការសហការពេញលេញជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ និងអាជ្ញាធរដែនដី។

**១៧២.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

*វិធានការរយៈពេលខ្លី:*

- ចុះធ្វើសវនកម្ម និងអនុវត្តតាមច្បាប់ចំពោះម្ចាស់អចលនទ្រព្យ ដែលបានប្រកាសបង់ពន្ធមិនត្រឹមត្រូវ និងមិនទាន់ដាក់លិខិតប្រកាសបង់ពន្ធលើអចលនទ្រព្យរបស់ខ្លួននៅឡើយ,
- ពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ពិសេសអាជ្ញាធរមូលដ្ឋាន ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ,
- កែលម្អសេវា និងផ្តល់ការសម្រួលដល់អ្នកជាប់ពន្ធ ពិសេសរៀបចំយន្តការបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមប្រព័ន្ធធនាគារ និងប្រព័ន្ធអេឡិចត្រូនិក។

*វិធានការរយៈពេលមធ្យម:*

- ពង្រីកវិសាលភាពប្រមូលពន្ធលើអចលនទ្រព្យដល់ទីប្រជុំជនស្រុក, ទីប្រជុំជនសំខាន់ៗ និងតំបន់អភិវឌ្ឍន៍តាមព្រំដែន និងបន្តបន្ទាប់ទូទាំងប្រទេស,
- កែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រមូលពន្ធលើអចលនទ្រព្យ។

### ៦.៣.៧ ពន្ធលើចំណូលរូបវន្តបុគ្គល

**១៧៣.** ពន្ធលើចំណូលរូបវន្តបុគ្គល ដែលមានលក្ខណៈពេញលេញ គឺជាពន្ធផ្ទាល់ ដែលបង់តាមរបបស្វ័យប្រកាសប្រចាំឆ្នាំ ហើយតម្រូវឱ្យរូបវន្តបុគ្គលម្នាក់ៗត្រូវធ្វើការគណនាប្រាក់ពន្ធ (ចំណូលជាប់ពន្ធគុណនឹងអត្រាពន្ធ) និងដាក់លិខិតប្រកាសមករដ្ឋបាលសារពើពន្ធដោយខ្លួនឯង។ ចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គលកើតឡើងពីប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗ ដែលបានទទួលពីការងារអាជីវកម្ម, ការវិនិយោគ ឬការប្រាក់នៃការសន្សំ និងចំណូលពីប្រភពផ្សេងៗ ដោយធ្វើការកាត់កងនូវចំណាយចាំបាច់នានា និងត្រូវគណនាដោយដកចេញនូវការលើកលែងពន្ធ និងការបន្ធូរបន្ថយពន្ធដែលកំណត់ដោយច្បាប់។ ប្រព័ន្ធពន្ធដារកម្ពុជានាពេលបច្ចុប្បន្នមានតែពន្ធលើប្រាក់បៀវត្ស ដែលកាត់ទុក និងដាក់លិខិតប្រកាសបង់ពន្ធជារៀងរាល់ខែដោយនិយោជកជំនួសឱ្យនិយោជិត តាមអត្រាកំណើនតាមថ្នាក់ពី 0% ដល់ ២០%។ ជាមួយគ្នានោះដែរ ក្នុងករណីបុគ្គលម្នាក់ៗមានចំណូលមកពីប្រភពផ្សេងៗ ត្រូវបានអនុវត្តពន្ធកាត់ទុកដោយអ្នកបើកផ្តល់ឱ្យចំពោះការទូទាត់ ដូចជា ឈ្នួលផ្ទះ និងដី, ការផ្តល់សេវា, ការប្រាក់, ភាគលាភ។ល។

**១៧៤.** មកទល់បច្ចុប្បន្ននេះ កម្ពុជាមិនទាន់មានបទប្បញ្ញត្តិ និងយន្តការគាំទ្រ ដើម្បីអនុវត្តពន្ធលើចំណូលរូបវន្តបុគ្គលពេញលេញ ដែលធ្វើឱ្យកម្ពុជាបាត់បង់នូវសក្តានុពលចំណូលពីពន្ធលើរូបវន្តបុគ្គលនេះ។

**១៧៥.** ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ វិធានការចាំបាច់ ដែលត្រូវដាក់ចេញ គឺការសិក្សាអំពីការរៀបចំបទប្បញ្ញត្តិ និងយន្តការគាំទ្រទាំងឡាយ សម្រាប់ត្រៀមឱ្យអនុវត្តពន្ធលើចំណូលរូបវន្តបុគ្គល ដែលមានលក្ខណៈពេញលេញ។

### ៦.៣.៨ ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ

**១៧៦.** ការយកពន្ធលើវិស័យប្រេងកាត និងធនធានរ៉ែ ដែលជាវិស័យថ្មី និងស្មុគស្មាញតម្រូវឱ្យមន្ត្រីពន្ធដារមានជំនាញខ្ពស់ និងត្រូវមានបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធដារគ្រប់គ្រាន់។ ច្បាប់ស្តីពីសារពើពន្ធបច្ចុប្បន្នមិនទាន់មានចែងអំពីបទប្បញ្ញត្តិពន្ធទាក់ទិននឹងធនធានធម្មជាតិ (ប្រេងកាត និងធនធានរ៉ែដទៃទៀត) គ្រប់គ្រាន់ ដូចជា ការធ្វើវិលស់ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត, ចំណាយរុះរើបោសសម្អាត, ចំណាយការប្រាក់, កំហិតលើការកាត់កង, ការផ្ទេរអត្ថប្រយោជន៍ និងសម្ព័ន្ធអាជីវកម្ម។ កង្វះខាតនេះតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំឱ្យមាន

បទប្បញ្ញត្តិសម្រាប់គ្រប់គ្រងវិស័យនេះ ដើម្បីគ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែស្របតាមបទដ្ឋានអន្តរជាតិ ដែលមានភាពងាយស្រួលអនុវត្ត និងផ្តល់នូវភាពជឿទុកចិត្តដល់អ្នកជាប់ពន្ធ។

**១៧៧.** ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ វិធានការរយៈពេលខ្លីចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចខាងក្រោម÷

- ជំរុញការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ,
- រៀបចំលិខិតបទដ្ឋានគតិយុត្តអនុវត្តពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ។

### ៦.៣.៩ ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពន្ធដារ

**១៧៨.** កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់ពេញលេញសំខាន់ៗពីរលើកលើប្រព័ន្ធពន្ធដារក្នុងឆ្នាំ ១៩៩៤ និងឆ្នាំ ១៩៩៧ ព្រមទាំងការកែទម្រង់បន្ទាប់បន្សំមួយចំនួនទៀត លើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ។ បច្ចុប្បន្ន ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការរីកចម្រើន ដែលតម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដារត្រូវធ្វើបច្ចុប្បន្នកម្មច្បាប់ស្តីពីសារពើពន្ធឱ្យបានសមស្របក្នុងគោលបំណងបំពេញបន្ថែមចំណុចខ្វះចន្លោះ និងភាពមិនច្បាស់លាស់នៃមាត្រាមួយចំនួនក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

**១៧៩.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការរយៈពេលមធ្យម គឺធ្វើការសិក្សា និងពិនិត្យឡើងវិញអំពីប្រព័ន្ធពន្ធដារ និងបទប្បញ្ញត្តិស្តីពីពន្ធដារនូវចំណុចខ្វះចន្លោះ និងភាពមិនច្បាស់លាស់ ហើយរៀបចំធ្វើវិសោធនកម្មបទប្បញ្ញត្តិពាក់ព័ន្ធតាមការចាំបាច់។

### ៦.៣.១០ ការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

**១៨០.** កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានលើការដោះដូរទំនិញត្រូវបានរៀបចំឡើង ក្នុងគោលបំណងបង្កើតមូលដ្ឋានផលិតរួមមួយ និងទីផ្សាររួមមួយសម្រាប់លំហូរពាណិជ្ជកម្មដោយសេរីក្នុងតំបន់អាស៊ាន និងសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ ដើម្បីឈានទៅសម្រេចគោលដៅរួមនៃការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននាដំណាច់ឆ្នាំ ២០១៥។ ប្រទេសកម្ពុជាបានអនុវត្តពេញលេញនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានលើការដោះដូរទំនិញនេះចាប់តាំងពីឆ្នាំ ២០១១ បន្ទាប់ពីការចាប់ផ្តើមអនុវត្តដំបូងនាចុងឆ្នាំ ២០១០ តាមគម្រោងកាត់បន្ថយអត្រាពន្ធនាំចូលចំពោះក្រុមប្រភេទទំនិញចំនួន ៦ ដែលមានលក្ខខណ្ឌ និងពេលវេលាកំណត់រៀងៗខ្លួន។

**១៨១.** សម្រាប់រយៈពេលវែង ការចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាននេះនឹងធ្វើឱ្យប្រទេសកម្ពុជាកើនឡើងនូវសមត្ថភាពប្រកួតប្រជែងខ្ពស់លើការធ្វើពាណិជ្ជកម្មតាមរយៈការកាត់បន្ថយថ្លៃដើម និងការជំរុញសន្ទុះកំណើនពាណិជ្ជកម្មឱ្យកាន់តែខ្លាំងក្លាជាងមុន។ នៅក្នុងរយៈពេលខ្លី កិច្ចព្រមព្រៀងពាណិជ្ជកម្មនេះនឹងជះឥទ្ធិពលជាអវិជ្ជមានចំពោះកម្ពុជា ដោយសារការថយចុះនៃចំណូលពន្ធពី : (១)- ការនាំចូលផលិតផលតេលសិលា និងផលិតផលរ៉ែផ្សេងៗ, (២)- ការនាំចូលយានយន្ត និង (៣)- ការនាំចូលគ្រឿងឧបភោគបរិភោគ រួមបញ្ចូលបារី និងភេសជ្ជៈមានជាតិស្រវឹងផ្សេងៗ។

**១៨២.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវវាយតម្លៃរៀងរាល់ត្រីមាសលើការបាត់បង់ចំណូលពន្ធអាករគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត និងស្នើឡើងនូវវិធានការសមស្រប។

### ៦.៣.១១ ការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

**១៨៣.** ក្នុងគោលដៅរួមចំណែកសម្រេចឱ្យបានកំណើនចំណូល ០,៥ % នៃ ផសស និងផែនការអភិវឌ្ឍន៍ដែលបានគូសបញ្ជាក់ក្នុង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** ចំណូលមិនមែនសារពើពន្ធ ដែលរួមមាន កម្រៃពីសេវាសាធារណៈ, ចំណូលពីធនធាន និងសម្បទាន និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ បានក្លាយជាប្រភពចំណូលមួយយ៉ាងសំខាន់របស់រាជរដ្ឋាភិបាល ដោយសារវិសាលភាពនៃប្រភពចំណូលនេះមានការកើនឡើងជាលំដាប់។

**១៨៤.** កង្វះច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ បានបណ្តាលឱ្យការប្រមូលចំណូលមិនមែនសារពើពន្ធនៅមានភាពខ្លះចន្លោះ, មិនគ្រប់ជ្រុងជ្រោយ, មិនទាន់អស់លទ្ធភាព និងមិនទាន់ប្រទាក់ក្រឡាគ្នាពេញលេញរវាងក្រសួង-ស្ថាប័ន និងអង្គភាពប្រមូលចំណូលទាំងអស់។ ក្នុងន័យនេះ ច្បាប់ស្តីពីចំណូលមិនមែនសារពើពន្ធនឹងផ្តោតសំខាន់លើការបង្កើតឱ្យបាននូវយន្តការ, នីតិវិធី, បែបបទ និងទោសទណ្ឌច្បាស់លាស់ ដើម្បីពង្រឹងការគ្រប់គ្រង និងប្រមូលពន្ធប្រភេទនេះឱ្យមានសង្គតិភាព, តម្លាភាព, ប្រសិទ្ធភាព និងគណនេយ្យភាព។ បន្ថែមពីនេះទៀត ច្បាប់នេះនឹងផ្តល់លទ្ធភាពឱ្យក្រសួង-ស្ថាប័ន និងអង្គភាពប្រមូលចំណូលទាំងអស់ មានមូលដ្ឋានគតិយុត្តរឹងមាំ ក្នុងការអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួន ក្នុងការកៀរគរប្រមូលចំណូល និងតឹងទារបំណុល។

**១៨៥.** ទន្ទឹមនឹងនេះដែរ កង្វះច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏បានបង្កជាបញ្ហាចោទទៅដល់ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ជាពិសេសការធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិរដ្ឋ, ការកំណត់ថ្លៃ និងកម្រៃ, ការរៀបចំបញ្ជីសារពើភ័ណ្ឌ, ការផ្ទេរសិទ្ធិកាន់កាប់, ការអភិរក្ស, ការអភិវឌ្ឍ និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ។ ហេតុនេះ ការបង្កើតឡើងនូវច្បាប់នេះ គឺជាកត្តាគន្លឹះមួយ ម្យ៉ាងដើម្បីឈានទៅដល់ការគ្រប់គ្រង និងចាត់ចែងទ្រព្យ-សម្បត្តិរដ្ឋឱ្យមានប្រសិទ្ធភាពខ្ពស់ និងម្យ៉ាងទៀតជួយពង្រឹងយន្តការការប្រមូលចំណូលពីប្រភពនេះឱ្យអស់ពីលទ្ធភាព, គ្រប់ជ្រុងជ្រោយ, ប្រកបដោយប្រសិទ្ធភាព និងស្របតាមការអភិវឌ្ឍរបស់សង្គម ជាពិសេសចំណូលពីសម្បទានទ្រព្យ-សម្បត្តិសាធារណៈរបស់រដ្ឋ។

**១៨៦.** ដើម្បីដោះស្រាយនូវបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនសម្រាប់រយៈពេលមធ្យមត្រូវដាក់ចេញ ដូចខាងក្រោម÷

- រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ,
- រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ,
- ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវធ្វើការស្រាវជ្រាវ និងលើកសំណើរៀបចំ និងធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានគ្រប់ប្រភេទរបស់រដ្ឋ រួមមានជាអាទិ៍ ច្បាប់ស្តីពីរ៉ែ, ច្បាប់ស្តីពីប្រេងកាត និងច្បាប់ស្តីពីសម្បទាន ជាដើម ដោយធានាឱ្យមានសង្គតិភាព និងការបំពេញឱ្យគ្នាជាមួយនឹងច្បាប់ស្តីពីសារពើពន្ធ, ច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

## ៧. ការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ

**១៨៧.** ការអនុវត្តយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានការតាមដាន និងវាយតម្លៃជាប្រចាំ និងជាបន្ទុកការងារដ៏ចម្បងមួយ ដែលទាមទារធនធានច្រើន និងកិច្ចខិតខំប្រឹងប្រែងខ្ពស់ក្នុងរយៈពេលវែង។ ភាពជោគជ័យនឹងមិនអាចទទួលបានទេ ប្រសិនបើមិនមានការគាំទ្រពីថ្នាក់ដឹកនាំនយោបាយ, ថ្នាក់គ្រប់គ្រង និងមន្ត្រីអនុវត្ត។ ទន្ទឹមនេះ ប្រសិទ្ធភាព និងចីរភាពនៃការដឹកនាំការអនុវត្តយុទ្ធសាស្ត្រនេះ គឺជាកត្តាកំណត់ភាពជោគជ័យ។ ដើម្បីឆ្លើយតបទៅនឹងកត្តាដែលបានរៀបរាប់ខាងលើ គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រគៀរគរចំណូលចំនួនពីរនឹងត្រូវបានបង្កើតឡើង : (១)- គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ និង (២)- គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ។

**១៨៨.** គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធមានសមាសភាព, តួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ រួមមាន :
  - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន,
  - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយរូប ជាអនុប្រធាន,
  - សមាជិកគណៈកម្មាធិការមានតំណាងពីអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ,
  - អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈទទួលបន្ទុកជាលេខាធិការដ្ឋាន។
- តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ រួមមាន :
  - កំណត់កាលវិភាគនៃការអនុវត្ត ព្រមទាំងត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាព, និងសូចនាករទាំងអស់ ដែលទាក់ទងនឹងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា,
  - សម្របសម្រួល និងផ្តល់ការណែនាំលើការអនុវត្តយុទ្ធសាស្ត្រដល់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា,
  - ប្រជុំរៀងរាល់ត្រីមាស ដើម្បីត្រួតពិនិត្យ, វាយតម្លៃ និងចាត់វិធានការជាក់ស្តែងក្នុងការជំរុញការប្រមូលចំណូលសារពើពន្ធ និងបំណុលនាពេលអនាគត,

**១៨៩.** គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធមានសមាសភាព, តួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សមាសភាពគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ រួមមាន :
  - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន,
  - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយរូប ជាអនុប្រធាន,
  - ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន (រដ្ឋលេខាធិការ ឬថ្នាក់ប្រហាក់ប្រហែល) ដែលបានទទួលការចាត់តាំងឱ្យទទួលបន្ទុកគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ តំណាងពីអគ្គ-

នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, អគ្គាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,

- អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈទទួលបន្ទុកជាលេខាធិការដ្ឋាន។

• តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ រួមមាន :
  - កំណត់កាលវិភាគនៃការអនុវត្ត ព្រមទាំងត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាព, និងសូចនាករទាំងអស់ ដែលទាក់ទងនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ,
  - សម្របសម្រួល និងផ្តល់ការណែនាំក្នុងការអនុវត្តយុទ្ធសាស្ត្រដល់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ,
  - វាយតម្លៃ និងជំរុញការបង់ចំណូលមិនមែនសារពើពន្ធពីគ្រប់ក្រសួង-ស្ថាប័ន និងចាត់វិធានការជាក់ស្តែង ដើម្បីពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ និងបំណុលនាពេលអនាគត។

**១៩០.** ជាមួយនឹងរចនាសម្ព័ន្ធច្បាស់លាស់, ការតាមដាន និងវាយតម្លៃការអនុវត្ត និងវឌ្ឍនភាពរបស់យុទ្ធ-សាស្ត្រកៀរគរចំណូលនឹងចែកចេញជាពីរប្រភេទធំៗ គឺ : (១)- ការវាយតម្លៃទៅលើការអនុវត្តវិធានការទាំងឡាយ ដែលបានដាក់ចេញ ជាមួយនឹងពេលវេលាបញ្ចប់ ដែលបានកំណត់ដោយផ្អែកលើសូចនាករច្បាស់លាស់ និង(២)- ការពិនិត្យទៅលើសូចនាករវឌ្ឍនភាពនៃការប្រមូលចំណូលជាក់ស្តែង ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ រួមមាន : កំណើនចំណូលជាមធ្យមប្រចាំឆ្នាំ និងបរិមាណចំណូលជាភាគរយនៃ ផសស ។

## រូបភាព ៥: រចនាសម្ព័ន្ធគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រកៀរគរចំណូល



**តារាង ១: សូចនាករគន្លឹះសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃជាមូលដ្ឋានលើការប្រមូលចំណូល[2]**

| ចំណូលចរន្ត (ពាន់លានរៀល) | ច្ប[3].២០១៤ | ព្យ[4].២០១៥ | ព្យ.២០១៦ | ព្យ.២០១៧ | ព្យ.២០១៨ |
|---|---|---|---|---|---|
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 4,634 | 5,271 | 5,926 | 6,657 | 7,461 |
| អគ្គនាយកដ្ឋានពន្ធដារ | 3,974 | 4,658 | 5,419 | 6,275 | 7,215 |
| ចំណូលមិនមែនសារពើពន្ធ | 1,677 | 1,750 | 1,960 | 2,210 | 2,486 |
| **ចំណូលចរន្តសរុប** | **10,284** | **11,679** | **13,306** | **15,142** | **17,162** |
| **កំណើនប្រចាំឆ្នាំ** | | | | | |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 13.4% | 13.8% | 12.4% | 12.3% | 12.1% |
| អគ្គនាយកដ្ឋានពន្ធដារ | 12.2% | 17.2% | 16.3% | 15.8% | 15.0% |
| ចំណូលមិនមែនសារពើពន្ធ(*) | 16.3% | 4.3% | 12.0% | 12.7% | 12.5% |
| **ចំណូលចរន្តសរុប** | **13.4%** | **13.6%** | **13.9%** | **13.8%** | **13.3%** |
| **ភាគរយនៃផសស** | | | | | |
| អគ្គនាយកដ្ឋានគយ | 6.85% | 7.08% | 7.24% | 7.39% | 7.54% |
| អគ្គនាយកដ្ឋានពន្ធដារ | 5.87% | 6.26% | 6.62% | 6.97% | 7.29% |
| ចំណូលមិនមែនសារពើពន្ធ | 2.48% | 2.35% | 2.40% | 2.45% | 2.51% |
| **ចំណូលចរន្តសរុប** | **15.18%** | **15.69%** | **16.26%** | **16.81%** | **17.35%** |
| **កំណើនចំណូលចរន្តជាភាគរយនៃផសស** | **0.44** | **0.51** | **0.57** | **0.55** | **0.54** |

(*) ចំណូលសារពើពន្ធផ្សេងៗ និងចំណូលមិនមែនសារពើពន្ធ

[2] សូចនាករចំណូលនីមួយៗត្រូវបានគណនាផ្អែកលើអត្រាកំណើនព្យាករណ៍មធ្យមរយៈពេល០៥ឆ្នាំដោយប្រើប្រាស់ម៉ូដែលវិទ្យាសាស្ត្រតាមបែបបរិមាណនិងបន្ស៊ីជាមួយនឹងការវិនិច្ឆ័យប្រកបដោយលក្ខណៈអភិរក្សនិយមផងដែរ។សូចនាករនីមួយៗតំណាងឱ្យគោលដៅចំណូលអប្បបរមាដែលអគ្គនាយកដ្ឋាននិងនាយកដ្ឋាននីមួយៗត្រូវសម្រេចឱ្យបាន ដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តការងារប្រមូលចំណូលរបស់ខ្លួន។

[3] ច្ប. មានន័យថា តាមច្បាប់ថវិកាជាតិ

[4] ព្យ. មានន័យថា តាមការព្យាករណ៍

## ៨. សេចក្តីសន្និដ្ឋាន

**១៩១.** រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដែលជាផ្នែកមួយនៃកិច្ចការកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងស្របតាមគោលនយោបាយ ដែលបានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍនាពេលអនាគត, ជំរុញកំណើនសេដ្ឋកិច្ច, កាត់បន្ថយភាពក្រីក្រ, លើកកម្ពស់ជីវភាពប្រជាជន, គ្រប់គ្រងធនធានប្រកបដោយចីរភាព, ពង្រឹងបរិយាកាសវិនិយោគ, លើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន និងជំរុញការធ្វើសមាហរណកម្មប្រកបដោយជោគជ័យទៅក្នុងតំបន់ និងពិភពលោក។

**១៩២.** ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនេះ គឺជាកិច្ចការងារលំបាក, ស្មុគស្មាញ, មានលក្ខណៈជាប្រព័ន្ធ និងអាចជួបនូវបញ្ហាប្រឈមជាច្រើន ដែលទាមទារឱ្យក្រសួង, ស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់នៅក្នុងសង្គមមានការសម្របសម្រួលឱ្យបានល្អប្រសើរ, ប្តេជ្ញាចិត្តចូលរួមយ៉ាងសស្រាក់សស្រាំ, ប្រឹងប្រែងឱ្យអស់ពីចិត្តពីថ្លើម ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅ ដែលបានកំណត់។ ទន្ទឹមនេះ ការអនុវត្តយុទ្ធសាស្ត្រប្រកបដោយជោគជ័យ និងដោយរលូន ក៏ទាមទារផងដែរឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថនៅក្នុងការបំពេញកាតព្វកិច្ចបម្រើជាតិ ដោយត្រូវប្រកាន់ខ្ជាប់នូវអភិក្រមការងារថ្មី ៤ យ៉ាង ដែលត្រូវបានដាក់ចេញមកដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** គឺ "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល និងព្យាបាល**" លើការប្រមូលចំណូល និងបង់ពន្ធ ដោយឈរលើមូលដ្ឋានស្មើភាព, តម្លាភាព, គណនេយ្យភាព និងការតម្កល់ឧត្តមប្រយោជន៍ជាតិ និងប្រជាជនជាធំ។

**១៩៣.** សមិទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រែក្លាយកម្ពុជាពីប្រទេស ដែលមានចំណូលទាបទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ ស្របតាមទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៥.១.១ | ការពង្រឹងមុខងារប្រតិបត្តិការស្នូល | | | |
| ៥.១.១.១ | ការចុះបញ្ជីអ្នកជាប់ពន្ធ | | | |
| ១ | បង្កើតប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីក្រុមហ៊ុនតាមរយៈប្រព័ន្ធប្រមូលផ្តុំទិន្នន័យនៅថ្នាក់កណ្តាល, | ២០១៥ | | - ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីក្រុមហ៊ុន តាមរយៈប្រព័ន្ធប្រមូលផ្តុំទិន្នន័យនៅថ្នាក់កណ្តាល នឹងត្រូវបានបង្កើតឡើង |
| ២ | ធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ពិសេសបន្តការងារលុបចេញពីបញ្ជីចំពោះសហគ្រាស ដែលបាត់ខ្លួន ឬសហគ្រាសមិនដាក់លិខិតប្រកាសបន្ទាប់ពីបានធ្វើការត្រួតពិនិត្យរួច, | ២០១៥ | ធ្វើជាប្រចាំ | - ចំនួនសហគ្រាស ដែលត្រូវបានលុបចោលជារៀងរាល់ឆ្នាំ |
| ៣ | ចុះត្រួតពិនិត្យដល់ទីតាំងរបស់ក្រុមហ៊ុនដែលស្នើសុំចុះបញ្ជីពន្ធដារ និងធ្វើយុទ្ធនាការទូទាំងប្រទេស ដើម្បីប្រមូលព័ត៌មានចុះបញ្ជីដោយចុះអង្កេតស្រាវជ្រាវតាមដងផ្លូវ, ទិន្នន័យពីតតិយជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីបញ្ចូលអ្នកជាប់ពន្ធទៅក្នុងបញ្ជី ឬដើម្បីពិនិត្យផលរបរដែលត្រូវផ្ទេរពីរបបម៉ៅការទៅរបបស្វ័យប្រកាស, | រៀងរាល់៣ខែ | រៀងរាល់៣ខែ | - ចំនួនក្រុមហ៊ុន ដែលត្រូវបានអគ្គនាយកដ្ឋានពន្ធដារចុះត្រួតពិនិត្យដល់ទីកន្លែងជារៀងរាល់ត្រីមាស<br>- ចំនួនកម្មវិធីអង្កេតស្រាវជ្រាវតាមដងផ្លូវជារៀងរាល់ត្រីមាស |
| ៤ | ធ្វើបច្ចុប្បន្នកម្មវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម (អតប) ដែលបានចេញ និងត្រៀមផ្តល់ជូនថ្មីដែលមានសុវត្ថិភាពជាងមុន, | ២០១៥ | | - ចំនួនវិញ្ញាបនបត្រ អតប ថ្មីដែលត្រូវបានផ្តល់ជូន |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៥ | ចូលរួមអនុវត្តយន្តការ "ដំបូលតែមួយ" ជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងពាណិជ្ជកម្ម ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធសម្រាប់កិច្ចការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម។ | ២០១៥ | | - ការចុះបញ្ជីក្រោមដំបូលតែមួយសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) នឹងត្រូវបានអនុវត្ត |
| ៥.១.១.២ | ការផ្តល់សេវាអ្នកជាប់ពន្ធ | | | |
| ១ | រៀបចំ និងដាក់ឱ្យអនុវត្តផែនការផ្តល់សេវាអ្នកជាប់ពន្ធធំបំផុតចំនួន ១៥០, | ២០១៥ | | - ផែនការផ្តល់សេវាជូនអ្នកជាប់ពន្ធធំបំផុតចំនួន ១៥០ នឹងត្រូវបានអនុម័ត |
| ២ | រៀបចំបញ្ជីសំណួរចម្លើយ ដែលត្រូវបានសួរញឹកញាប់ និងចងក្រងដាក់ចូលក្នុងសៀវភៅណែនាំ និងដាក់ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ, | ២០១៥ | | - បញ្ជីសំណួរចម្លើយដែលត្រូវបានសួរញឹកញាប់នឹងត្រូវបានរៀបចំ និងផ្សព្វផ្សាយ |
| ៣ | រៀបចំបង្កើតការិយាល័យផ្តល់ព័ត៌មានតាមទូរស័ព្ទ និងការិយាល័យទំនាក់ទំនងសាធារណៈនៅនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ និងបង្កើតបញ្ជរពិគ្រោះយោបល់ពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ, | ២០១៦ | | - ការិយាល័យផ្តល់ព័ត៌មានតាមទូរស័ព្ទ, ការិយាល័យទំនាក់ទំនងសាធារណៈ និងបញ្ជរពិគ្រោះយោបល់ពន្ធនឹងត្រូវបានបង្កើតឡើង |
| ៤ | បង្កើនចំនួនមន្ត្រីទទួលបន្ទុកសេវាអ្នកជាប់ពន្ធ និងផ្តល់ធនធាន និងមធ្យោបាយបន្ថែម សម្រាប់ការងារផ្តល់សេវាអ្នកជាប់ពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ ដើម្បីបំពេញបន្ថែមនូវតម្រូវការជាក់ស្តែង និងផ្តល់សេវាអ្នកជាប់ពន្ធឱ្យមានប្រសិទ្ធភាព, | ២០១៦ | | - ស្ថិតិនៃមន្ត្រីផ្តល់សេវាអ្នកជាប់ពន្ធ, ថវិកាសម្រាប់គាំទ្រសេវាអ្នកជាប់ពន្ធ |
| ៥ | បន្តអនុវត្ត និងពង្រឹងការបិទផ្សាយជាសាធារណៈជាពិសេសនៅកន្លែងផ្តល់ | ២០១៥ | | - តារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈនឹង |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
| --- | --- | --- | --- | --- |
| | សេវានូវតារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈ, | | | ត្រូវបានបិទផ្សាយ |
| ៦ | បន្តរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតាមរយៈប្រអប់សំបុត្រ, ទូរស័ព្ទ ឬអ៊ីម៉ែល, | ២០១៥ | | - ចំនួនកន្លែង ឬប្រអប់សំបុត្រ ទទួលបណ្តឹងតវ៉ា |
| ៧ | រៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសេវាអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីប្រភេទពន្ធនីមួយៗ, | ២០១៦ | | - សៀវភៅណែនាំស្តីពីសេវាអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីប្រភេទពន្ធនីមួយៗនឹងត្រូវបានរៀបចំ និងផ្សព្វផ្សាយ |
| ៨ | រៀបចំ និងផ្សព្វផ្សាយដល់សាធារណជនតាមរយៈការរៀបចំសិក្ខាសាលា សារព័ត៌មាន, វិទ្យុ, ទូរទស្សន៍, គេហទំព័រ, ផ្ទាំងផ្សព្វផ្សាយ និងខិត្តបណ្ណផ្សព្វផ្សាយ ដើម្បីបញ្ជ្រាបវប្បធម៌បង់ពន្ធ, | ២០១៦ | | - ចំនួនកម្មវិធីផ្សព្វផ្សាយតាមមធ្យោបាយទាំងនេះនឹងត្រូវបានរៀបចំ និងផ្សព្វផ្សាយ |
| ៩ | ពង្រឹងសមត្ថភាព និងកិច្ចសហការជាមួយផ្នែកឯកជន, គណនេយ្យករ, សវនករជំនាញ, អ្នកច្បាប់និងភ្នាក់ងារសេវាកម្មពន្ធដារដើម្បីពង្រឹងការគោរពច្បាប់ និងស្វែងយល់ពីតម្រូវការរបស់អ្នកជាប់ពន្ធ, | ២០១៥ | | - ចំនួនព្រឹត្តិការណ៍សហប្រតិបត្តិការ និងការកសាងសមត្ថភាព និងការជួបប្រជុំនឹងត្រូវបានរៀបចំឡើងរៀងរាល់ ៣ ខែ |
| ១០ | រៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រពង្រឹងសេវាអ្នកជាប់ពន្ធ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងនោះរួមមាន យន្តការសម្របសម្រួលរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន, កម្មវិធីផ្តល់សេវាអ្នកជាប់ពន្ធ, ការបណ្តុះបណ្តាលក្រុមមន្ត្រីបង្គោល ដែលមានជំនាញសេវាអ្នកជាប់ពន្ធ និងការផ្សព្វផ្សាយ។ល។ | | ៣ ឆ្នាំ | - យុទ្ធសាស្ត្រសេវាអ្នកជាប់ពន្ធ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនឹងត្រូវបានរៀបចំ, អនុម័ត និងដាក់ឱ្យអនុវត្ត |
| ៥.១.១.៣ | ការចាត់ចែងលិខិតប្រកាស | | | |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ១ | រៀបចំស្តង់ដាររបាយការណ៍ដាក់លិខិតប្រកាសប្រចាំខែចំពោះគ្រប់ប្រភេទពន្ធសម្រាប់អង្គភាពនីមួយៗ, | ២០១៥ | | - ស្តង់ដាររបាយការណ៍ដាក់លិខិតប្រកាសប្រចាំខែនឹងត្រូវបានរៀបចំ |
| ២ | កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាស ឱ្យបានខ្ពស់ជាអតិបរមាបន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា, | ជារៀងរាល់ឆ្នាំ | ជារៀងរាល់ឆ្នាំ | - អត្រាគោលដៅនៃការដាក់លិខិតប្រកាស ត្រូវបានកំណត់÷<br>• ៧៥% សម្រាប់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ<br>• ៧០% សម្រាប់សាខាពន្ធដារខណ្ឌ និង<br>• ៨០% សម្រាប់សាខាពន្ធដារខេត្ត |
| ៣ | អនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ ខែជាប់គ្នា, | រៀងរាល់៦ខែ | រៀងរាល់៦ខែ | - ចំនួនវិញ្ញាបនប័ត្រ អ.ត.ប.ដែលបានលុបចោល |
| ៤ | រៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ។ | ២០១៦ | | - យន្តការដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត÷<br>• ជំហានដំបូងនៅ ន/ជ គ្រប់គ្រងអ្នកជាប់ពន្ធធំ<br>• ជំហានបន្ទាប់នៅសាខាពន្ធដារខេត្ត-ខណ្ឌ |
| ៥.១.១.៤ | **ការធ្វើសវនកម្ម** | | | |
| ១ | កែលម្អវិធីសាស្ត្រកំណត់ហានិភ័យ ដែលមានស្រាប់រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិភាពក្នុងការធ្វើសវនកម្ម និងរៀបចំសារាចរណែនាំ | ២០១៦ | ជាប្រចាំ | - សារាចរណែនាំស្តីពីការកំណត់ហានិភ័យរួមនឹងត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | ដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដាររួម ដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធ ដែលត្រូវធ្វើសវនកម្ម, | | | - វិធីសាស្ត្រកំណត់ហានិភ័យនឹងត្រូវបានកែលម្អ<br>- កំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់ក្រុមហ៊ុនធំៗនីមួយៗនឹងត្រូវបានរៀបចំឡើង |
| ២ | ជ្រើសរើសបន្ថែមសវនករទាំងក្នុងមុខងារសវនកម្មពេញលេញ និងសវនកម្មមានកម្រិត ដើម្បីបំពេញតម្រូវការជាក់ស្តែងនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ សម្រាប់ឆ្លើយតបនឹងកំណើនចំនួនសហគ្រាស និងប្រសិទ្ធភាពនៃការធ្វើសវនកម្ម, | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ | - ចំនួនសវនករនឹងត្រូវបានជ្រើសរើសបន្ថែម |
| ៣ | រៀបចំ និងអនុវត្តយន្តការលើកទឹកចិត្តដល់សវនករដោយផ្អែកលើលទ្ធផលសវនកម្មពិតប្រាកដ, | ២០១៥ | | - យន្តការលើកទឹកចិត្តសម្រាប់សវនករ នឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ៤ | រៀបចំសៀវភៅណែនាំស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងសវនកម្ម ដើម្បីឱ្យអ្នកជាប់ពន្ធយល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្នុងពេលធ្វើសវនកម្ម, | ២០១៥ | | - សៀវភៅណែនាំនឹងត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ |
| ៥ | រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យមុនពេលចុះសវនកម្មកន្លងមក សម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ (ដូចជាការគោរពច្បាប់, កំហុសអចេតនា, ការអនុវត្តច្បាប់ខុស, ការប្រកាសប្រាក់ពន្ធខ្វះ, ការគេចវេសពន្ធធ្ងន់ធ្ងរ។ល។) | ២០១៦ | ជាប្រចាំ | - កំណត់ត្រាលទ្ធផលសវនកម្ម និងមតិត្រលប់វិញនឹងត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេល មធ្យម | សូចនាករ |
|---|---|---|---|---|
| ៦ | ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្ម ដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និង បន្ថយបន្ទុកសវនកម្ម, | ២០១៦ | ជាប្រចាំ | - នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំនឹងចាប់ផ្តើម អនុវត្តឱ្យបានយ៉ាងតិចចាប់ពី ៣០% នៃសហគ្រាស ដែលដាក់លិខិតប្រកាសមានប្រាក់ពន្ធ |
| ៧ | បន្តធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រកំណត់ហានិភ័យរបស់ក្រុមហ៊ុន និង បង្កើតប្រព័ន្ធកុំព្យូទ័រវិភាគហានិភ័យដោយស្វ័យប្រវត្តិ, | | ៣ឆ្នាំ | - ប្រព័ន្ធកុំព្យូទ័រវិភាគហានិភ័យ ដោយស្វ័យប្រវត្តិនឹង ត្រូវបានដាក់ឱ្យប្រើប្រាស់ |
| ៨ | ពង្រឹងការទទួលព័ត៌មានអ្នកជាប់ពន្ធឱ្យមានលក្ខណៈស្វ័យប្រវត្តិពីអង្គភាព ផ្ទៃក្នុង និងស្ថាប័នពាក់ព័ន្ធ, | | ៣-៤ឆ្នាំ | - ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធនឹង0ត្រូវទទួលបាន ពីគ្រប់ស្ថាប័នដោយស្វ័យប្រវត្តិ |
| ៩ | រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្ម លើវិស័យសំខាន់ៗមួយចំនួន រួមមាន ធនាគារ, សំណង់, ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករ ងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម, | | ២០១៦ | - សារាចរណែនាំទាំងនេះនឹងត្រូវបានចងក្រង និង ដាក់ឱ្យអនុវត្ត |
| ១០ | រៀបចំសារាចរណែនាំស្តីពីការផ្ទេរថ្លៃ (Transfer Pricing)។ | | ២០១៧ | - សារាចរណែនាំនឹងត្រូវបានចងក្រង និងដាក់ឱ្យ អនុវត្ត |
| **៥.១.១.៥** | **ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា** | | | |
| ១ | កំណត់គោលដៅប្រមូលបំណុលពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធ ដារខេត្ត-ខណ្ឌ និងអនុវត្តវិធានការតឹងទារចំពោះអ្នកជំពាក់បំណុលពន្ធ ធំៗ ដែលមិនតវ៉ា និងមានបំណុលពន្ធថ្មីៗ, | ២០១៥ | រៀងរាល់ឆ្នាំ | - អ្នកជំពាក់បំណុលពន្ធធំៗ នឹងត្រូវបានជ្រើសរើស និងអនុវត្តវិធានការតឹងទារ<br>- បំណុលពន្ធត្រូវបានប្រមូលឱ្យបានចាប់ពី ២០% ឡើងទៅនៃបំណុលពន្ធសុទ្ធនៅសល់សរុប (បំណុល ពន្ធសុទ្ធនៅសល់សរុបបន្ទាប់ពីលុបបំណុលដែល |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | | | | មិនអាចប្រមូលបាន) |
| ២ | អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្ដីពីពន្ធដារដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្ដឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ, | ២០១៦ | រៀងរាល់ឆ្នាំ | - ការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្ដឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការនឹងត្រូវបានអនុវត្ត |
| ៣ | រៀបចំសៀវភៅណែនាំស្ដីពីការគ្រប់គ្រងប្រមូលបំណុលពន្ធ, | ២០១៥ | | - សៀវភៅណែនាំស្ដីពីការគ្រប់គ្រងប្រមូលបំណុលពន្ធនឹងត្រូវបានរៀបចំនិងអនុវត្ត |
| ៤ | កែប្រែប្រកាសស្ដីពីវិធាន និងនីតិវិធីនៃការដោះស្រាយបណ្ដឹងតវ៉ា។ | ២០១៥ | | - ប្រកាសនឹងត្រូវបានរៀបចំ និងអនុវត្ត |
| ៥.១.២ | ការពង្រឹងមុខងារគាំទ្រ | | | |
| ៥.១.២.១ | ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ | | | |
| ១ | កំណត់ និងផ្សព្វផ្សាយនូវចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារដល់គ្រប់មន្ត្រីពន្ធដារ និងសាធារណជន, | ២០១៥ | | - ចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ នឹងត្រូវបានរៀបចំ និងផ្សព្វផ្សាយ |
| ២ | ពិនិត្យឡើងវិញនូវផែនការប្រតិបត្តិរបស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ និងកំណត់គោលដៅអាទិភាព និងពេលវេលាសម្រេចបាន, | ២០១៥ | | - ផែនការប្រតិបត្តិរបស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌនឹងត្រូវបានរៀបចំ |
| ៣ | កែសម្រួលរចនាសម្ព័ន្ធការងាររបស់អង្គភាពពន្ធដារនីមួយៗ និងបង្កើតការិយាល័យមួយចំនួនបន្ថែមទៀតនៅតាមនាយកដ្ឋានថ្នាក់កណ្ដាល និងតាមសាខាពន្ធដារខេត្ត ដើម្បីដំណើរការការងារ និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព, | ២០១៥ | | - ប្រកាសកែសម្រួលនឹងត្រូវបានបង្កើត |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៤ | បន្តពង្រឹងនិងកែសម្រួលតួនាទី និងភារកិច្ចរបស់ការិយាល័យសវនកម្មផ្ទៃក្នុងនៃនាយកដ្ឋានត្រួតពិនិត្យ, | ២០១៥ | | - ភារកិច្ច និងតួនាទីនឹងត្រូវបានកែសម្រួល |
| ៥ | បង្កើតគណៈកម្មការ/ ក្រុមការងារគ្រប់គ្រងការកែទម្រង់អចិន្ត្រៃយ៍ ដោយជ្រើសរើសមន្ត្រី ដែលមានបទពិសោធន៍ រួមទាំងមានការផ្តល់ការលើកទឹកចិត្តឱ្យបានសមរម្យ, | ២០១៤ | | - គណៈកម្មការ/ ក្រុមការងារគ្រប់គ្រងកំណែទម្រង់អចិន្ត្រៃយ៍នឹងត្រូវបានបង្កើតឡើង |
| ៦ | បង្កើតការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ ក្នុងនាយកដ្ឋានត្រួត-ពិនិត្យ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ, | ២០១៦ | | - ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារនឹងត្រូវបានបង្កើតឡើង |
| ៧ | រៀបចំនីតិសម្បទាជូនមន្ត្រីពន្ធដារជានគរបាលយុត្តិធម៌, | ២០១៥ | | - ច្បាប់ពន្ធដារនឹងត្រូវបានធ្វើវិសោធនកម្ម |
| ៨ | បន្តរៀបចំកែលម្អរចនាសម្ព័ន្ធ និងបង្កើតនាយកដ្ឋាន និងការិយាល័យថ្មីមួយចំនួនតាមការចាំបាច់របស់អគ្គនាយកដ្ឋានពន្ធដារ, | | តុលា/ ២០១៨ | - រចនាសម្ព័ន្ធ និងនាយកដ្ឋានថ្មីមួយចំនួន នឹងត្រូវបានបង្កើត |
| ៩ | រៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន។ | | តុលា/ ២០១៨ | - ផែនការអភិវឌ្ឍន៍ស្ថាប័ននឹងត្រូវបានរៀបចំឡើង |
| ៥.១.២.២ | ការគ្រប់គ្រងធនធានមនុស្ស | | | |
| ១ | បញ្ចប់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស, | ២០១៦ | | - យុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សនឹងត្រូវបានរៀបចំឡើង |
| ២ | ធ្វើសនិទានកម្មរបបរង្វាន់លើកទឹកចិត្ត ដែលត្រូវផ្អែកលើលទ្ធផលការងារជាមូលដ្ឋាន, បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពន្ធដារគ្រប់កម្រិត និង | ២០១៥ | | - របបរង្វាន់លើកទឹកចិត្តដែលផ្អែកលើលទ្ធផលការងាររបស់មន្ត្រីនឹងត្រូវបានរៀបចំឡើង |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | កែលម្អកម្មវិធីសិក្សារបស់សាលាជាតិពន្ធដារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង, | | | - កម្មវិធីបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពន្ធដារគ្រប់កម្រិត<br>- កម្មវិធីសិក្សារបស់សាលាជាតិពន្ធដារនឹងត្រូវបានកែលម្អ |
| ៣ | ធ្វើការជ្រើសរើសមន្ត្រីពន្ធដារឱ្យបានឆាប់រហ័សស្របតាមតម្រូវការជាក់ស្តែងរបស់អង្គភាពពន្ធដារនីមួយៗ, | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ | - ការជ្រើសរើសមន្ត្រីពន្ធដារនឹងត្រូវបានកែលម្អ |
| ៤ | បញ្ចប់ការរៀបចំលក្ខខណ្ឌការងារ និងការទទួលខុសត្រូវលើមុខងារនីមួយៗ និងទម្រង់វាយតម្លៃលទ្ធផលការងាររបស់មន្ត្រីរាជការពន្ធដារតាមឋានានុក្រម, | ២០១៤ | | - លក្ខខណ្ឌការងារ និងការទទួលខុសត្រូវលើមុខងារនីមួយៗ និងទម្រង់វាយតម្លៃការងារត្រូវបានបង្កើតឡើង |
| ៥ | បញ្ចប់សេចក្តីព្រាងស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ និងរៀបចំសេចក្តីណែនាំស្តីពីវិន័យ និងការដាក់ទណ្ឌកម្មដែលបញ្ជាក់អំពីនីតិវិធីអនុវត្តច្បាស់លាស់, | ២០១៥ | | - ក្រមសីលធម៌នឹងត្រូវបានអនុម័ត<br>- សេចក្តីណែនាំវិន័យនិងការដាក់ទណ្ឌកម្មនឹងត្រូវបានអនុម័ត |
| ៦ | រៀបចំបទដ្ឋានគោលការណ៍ឱ្យបានច្បាស់លាស់សម្រាប់ការផ្លាស់ប្តូរមន្ត្រី, | ២០១៥ | | - គោលការណ៍តែងតាំង ឬចាត់បញ្ជូនមន្ត្រីទៅបំពេញភារកិច្ចតាមសាខាខេត្ត-ក្រុងនឹងត្រូវបានបង្កើតឡើង |
| ៧ | រៀបចំគម្រោងចំណាយថវិការបស់អង្គភាពពន្ធដារ ដើម្បីទទួលបានថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់គាំទ្រការអនុវត្តការងារប្រមូលចំណូលពន្ធ និងការកែទម្រង់ពន្ធដារឱ្យមានប្រសិទ្ធភាព។ | ២០១៥ | រៀងរាល់ឆ្នាំ | - គម្រោងថវិកាចំណាយនឹងត្រូវបានបង្កើត<br>- ថវិកាសម្រាប់អគ្គនាយកដ្ឋានពន្ធដារ នឹងត្រូវបានផ្តល់ជូនគ្រប់គ្រាន់ទាន់ពេលវេលា |
| **៥.១.២.៣** | **បច្ចេកវិទ្យាព័ត៌មាន** | | | |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ១ | ជ្រើសរើសបន្ថែមនូវមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មាន គ្រប់អង្គភាពពន្ធដារទាំងអស់ ដើម្បីគាំពារដល់ផែនការទំនើបភាវូបនីយកម្ម និងស្វ័យប្រវត្តិកម្មពន្ធដារ, | ២០១៦ | | - ចំនួនមន្ត្រីជំនាញនឹងត្រូវបានជ្រើសរើសបន្ថែម |
| ២ | បញ្ចប់ការរៀបចំបណ្តាញតភ្ជាប់តំបន់ទូលាយ (WAN) តាមលក្ខណៈបច្ចេកទេសពីសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់មកកាន់ អគ្គនាយកដ្ឋានពន្ធដារ, | ២០១៥ | | - បណ្តាញតភ្ជាប់តំបន់ទូលាយ (WAN) នឹងត្រូវបានតភ្ជាប់ |
| ៣ | រៀបចំ និងអនុវត្តការដាក់លិខិតប្រកាសពន្ធតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, | | ២០១៧ | - ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននឹងត្រូវបានដាក់អនុវត្ត÷<br>• ជំហានដំបូងនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ<br>• ជំហានបន្ទាប់នៅសាខាពន្ធដារខេត្ត-ខណ្ឌ |
| ៤ | រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានពន្ធដារតាមដំណាក់កាលនៃការអនុវត្ត,តម្រូវការរបស់អ្នកប្រើប្រាស់ និងតម្រូវការធនធានសម្ភារៈបរិក្ខារ និងរៀបចំផែនការធ្វើលទ្ធកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយផ្អែកទៅតាមផែនការយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការងារសេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម និងការគ្រប់គ្រងបំណុលពន្ធ, | | ៣-៤ឆ្នាំ | - ផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន នៃប្រព័ន្ធទំនើបភាវូបនីយកម្ម និងស្វ័យប្រវត្តិកម្មពន្ធដារនឹងត្រូវបានរៀបចំ<br>- ផែនការលទ្ធកម្មតាមតំណាក់នីមួយៗនឹងត្រូវបានរៀបចំឡើង |

## ឧបសម្ព័ន្ធ ២: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| ៥.២.១ | **ការពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញ** | | | |
| ៥.២.១.១ | ការប្រកាសគយ | | | |
| ក. | ការគ្រប់គ្រងឯកសារនាំចេញ-នាំចូល | | | |
| ១ | កំណត់ទិន្នន័យអប្បបរមា ដែលត្រូវមានលើវិក្កយបត្រពាណិជ្ជកម្មក្នុងទម្រង់ជាក់លាក់តាមបទប្បញ្ញត្តិជាធរមាន, | ២០១៥ | | - សេចក្តីណែនាំ និងដាក់ឱ្យអនុវត្តរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើទិន្នន័យអប្បបរមាដែលត្រូវមានលើវិក្កយបត្រ<br>- ចំនួនករណីបទល្មើសនៃការប្រើប្រាស់ ឯកសារក្លែងក្លាយ |
| ២ | ពង្រឹងប្រព័ន្ធប្រកាសគយ ដោយស្វ័យប្រវត្តិតាមរយៈការតភ្ជាប់ទៅវិញទៅមកជាមួយនឹងប្រព័ន្ធរបស់សហគមន៍កំពង់ផែ, | ២០១៥ | | - ប្រព័ន្ធប្រកាសគយដោយស្វ័យប្រវត្តិត្រូវបានតភ្ជាប់ និងដាក់ឱ្យដំណើរការពេញលេញ |
| ៣ | ពង្រឹងប្រសិទ្ធភាពនៃការផ្ទៀងផ្ទាត់សង្គតិភាព និងអនុលោមភាពនៃឯកសារនាំចេញ-នាំចូល, | ជាប្រចាំ | ជាប្រចាំ | - កម្រិតអនុលោមភាពនៃឯកសារនាំចេញ-នាំចូល<br>- ចំនួនឯកសារដែលមានភាពមិនប្រក្រតី |
| ៤ | រៀបចំកិច្ចប្រជុំរវាង អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងភ្នាក់ងារកម្ពុជានាវាចរ “កាំសាប” ដើម្បីរៀបចំសេចក្តីព្រាងអនុស្សារណៈនៃការយោគយល់គ្នា លើនីតិវិធីគ្រប់គ្រងនិង ទទួលឯកសារដឹកជញ្ជូន ដែលត្រឹមត្រូវនិងទាន់ពេលវេលា, | ២០១៥ | | - អនុស្សារណៈយោគយល់ជាមួយសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ “កាំសាប” ត្រូវបានរៀបចំ និងចុះហត្ថលេខា |
| ៥ | ពង្រឹងយន្តការគ្រប់គ្រងក្រុមហ៊ុនជើងសាគយ និងធ្វើការព្រមាន និងដាក់ទោសទណ្ឌជាទៀងទាត់តាមច្បាប់ជាធរមាន ចំពោះបុគ្គលផ្តល់សេវាកម្មជើងសាគយដោយពុំមាននីតិសម្បទាជាជើងសាគយ, | ២០១៥ | | - ការកសាងបញ្ជីស្ថិតិតាមដានបុគ្គល ឬ ក្រុមហ៊ុនដែលជាម្ចាស់ទំនិញនាំចេញ-នាំចូលពិតប្រាកដ<br>- ចំនួនករណីព្រមាន |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| ៦ | រៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីបញ្ចេញទំនិញពីគយមុនពេលទំនិញមកដល់, | | ២០១៥ | - ការដាក់ឱ្យអនុវត្តនីតិវិធីបញ្ចេញទំនិញពីគយ មុនការមកដល់ឱ្យបានពេញលេញ |
| ៧ | បង្កើត និងអនុវត្តម៉ូឌុលត្រួតពិនិត្យទំនិញឆ្លងកាត់ក្នុងប្រព័ន្ធអាស៊ីគូដា, | | ២០១៥ | - ការដាក់ឱ្យអនុវត្តម៉ូឌុលត្រួតពិនិត្យទំនិញ ឆ្លងកាត់ក្នុងប្រព័ន្ធអាស៊ីគូដា |
| ៨ | ដាក់ឱ្យអនុវត្តអនុស្សារណៈយោគយល់គ្នារវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងភ្នាក់ងារកម្ពុជានាវាចរ “កាំសាប” លើការគ្រប់គ្រងការទទួលឯកសារដឹកជញ្ជូនត្រឹមត្រូវ និងទាន់ពេលវេលា។ | | ២០១៥ | - អនុស្សារណៈត្រូវបានរៀបចំ និងអនុវត្ត |
| ខ. | ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ | | | |
| ១ | ពង្រីក និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយឱ្យស្របតាមតម្លៃទិញលក់ពិតរាល់ដំណាច់ត្រីមាសតាមបទប្បញ្ញត្តិជាធរមាន ដោយធ្វើ ៣ ជំពូក ក្នុង ១ត្រីមាស, | ជារៀងរាល់ត្រីមាស | ជារៀងរាល់ត្រីមាស | - ចំនួនមុខទំនិញដែលបានធ្វើបច្ចុប្បន្នភាព ក្នុងប្រព័ន្ធទិន្នន័យទ្រទ្រង់តម្លៃគិតពន្ធគយ |
| ២ | ពិនិត្យលទ្ធភាពធ្វើមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំពោះមុខទំនិញវេទយិតលើចំណូលពន្ធគយមួយចំនួន ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូលចំណូលពន្ធគយ, | រៀងរាល់ដំណាច់ឆ្នាំនីមួយៗ | រៀងរាល់ដំណាច់ឆ្នាំនីមួយៗ | - ចំនួនមុខទំនិញវេទយិតដែលបានធ្វើមជ្ឈការទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| ៣ | ធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយលើទំនិញដែលមិនមានវេទយិតភាពលើចំណូលពន្ធអាករគយឱ្យទៅការិយាល័យគយទូទាំងខេត្ត-ក្រុងក្រោយពេលប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយត្រូវបានធ្វើបច្ចុប្បន្នកម្ម។ | រៀងរាល់ដំណាច់ឆ្នាំនីមួយៗ | រៀងរាល់ដំណាច់ឆ្នាំនីមួយៗ | - ចំនួនមុខទំនិញមិនមានវេទយិតត្រូវបានធ្វើវិមជ្ឈការទៅអង្គភាពគយ និងរដ្ឋាករខេត្ត-ក្រុង |
| ៥.២.១.២ | ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ | | | |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| ក. | ការគ្រប់គ្រងហានិភ័យ | | | |
| ១ | ធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវលក្ខណៈវិនិច្ឆ័យ សម្រាប់កំណត់ហានិភ័យនិងបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយ ដោយរក្សាឱ្យបាននូវការសម្ងាត់វិជ្ជាជីវៈ, | រៀងរាល់ត្រីមាស | រៀងរាល់ត្រីមាស | - កម្រិតបច្ចុប្បន្នភាពនៃលក្ខណៈវិនិច្ឆ័យ សម្រាប់កំណត់ហានិភ័យ និងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យ |
| ២ | ដំឡើងប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយបន្ថែមទៀត នៅតាមការិយាល័យគយនានា, | ២០១៥ | | - ចំនួនប្រព័ន្ធទិន្នន័យ ដែលបានតម្លើងបន្ថែមនៅតាមការិយាល័យគយនានា |
| ៣ | អង្កេត និងវាយតម្លៃសូចនាករហានិភ័យរបស់ធុរជនបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជននិងធ្វើបច្ចុប្បន្នកម្មឱ្យបានទៀងទាត់, | យ៉ាងតិចម្តងក្នុង ១ឆ្នាំ | យ៉ាងតិចម្តងក្នុង ១ឆ្នាំ | - របាយការណ៍វាយតម្លៃសូចនាករហានិភ័យគយ និងកម្រិតបច្ចុប្បន្នភាពនៃប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន |
| ៤ | កែសម្រួលកម្រិតហានិភ័យនៃមុខទំនិញក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់តាមរយៈការធ្វើវិសោធនកម្មអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់។ | ២០១៥ | | - សារាចរណ៍ណែនាំស្តីពីការកែសម្រួលកម្រិតហានិភ័យទំនិញត្រូវបានអនុវត្ត |
| ខ. | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ | | | |
| ១ | ប្រមូលទិន្នន័យចាំបាច់ពីគ្រប់ប្រភពទាំងអស់ដើម្បីធ្វើការគ្រប់គ្រងព័ត៌មានសម្ងាត់គយឱ្យមានប្រសិទ្ធភាព, | ២០១៥ | | - ទិន្នន័យចាំបាច់សម្រាប់ការគ្រប់គ្រងព័ត៌មានសម្ងាត់គយត្រូវបានប្រមូល |
| ២ | បង្កើនចំនួនមន្ត្រីគ្រប់គ្រងព័ត៌មានសម្ងាត់គយនៅគ្រប់សាខា ឬការិយាល័យគយ និងអនុវត្តមុខងារគ្រប់គ្រងព័ត៌មានសម្ងាត់គយឱ្យបានពេញ | ២០១៥ | | - ចំនួនមន្ត្រីព័ត៌មានសម្ងាត់គយ<br>- ភាពពេញលេញនៃការអនុវត្តមុខងារគ្រប់គ្រង |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| | លេញ, | | | ព័ត៌មានសម្ងាត់គយ |
| ៣ | កសាង និងអនុវត្តផែនការសកម្មភាពជាលក្ខណៈប្រព័ន្ធសម្រាប់ការ-គ្រប់គ្រងព័ត៌មានសម្ងាត់គយ ដោយមានការតភ្ជាប់ជាមួយនឹងស្ថាប័នពាក់ព័ន្ធ។ | | ២០១៦ | - ផែនការសកម្មភាពជាលក្ខណៈប្រព័ន្ធ សម្រាប់ការ-គ្រប់គ្រងព័ត៌មានសម្ងាត់គយត្រូវបានអនុវត្ត និងតភ្ជាប់ជាមួយនឹងស្ថាប័នពាក់ព័ន្ធ |
| ៥.២.១.៣ | **សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ** | | | |
| ១ | ពង្រីកអង្គភាពសវនកម្មក្រោយការបញ្ចេញទំនិញពីគយពី ៦ ទៅ ៩ ក្រុម, | ២០១៥ | | - អង្គភាពសវនកម្មក្រោយការបញ្ចេញទំនិញពីគយត្រូវបានពង្រីកដល់ ៩ ក្រុម |
| ២ | បញ្ជ្រាបជាប្រចាំដល់ធុរជននូវយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ជាពិសេសពាក់ព័ន្ធនឹងកាតព្វកិច្ចគ្រប់គ្រង និងថែរក្សាបញ្ជីស្នាមគណនេយ្យ និងឯកសារពាក់ព័ន្ធនឹងការនាំចេញ-នាំចូល, | រៀងរាល់ត្រីមាស | រៀងរាល់ត្រីមាស | - សិក្ខាសាលាស្តីពីយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយត្រូវបានអនុវត្ត |
| ៣ | ចែករំលែកជាប្រចាំនូវលទ្ធផលសវនកម្មក្រោយការបញ្ចេញទំនិញពីគយជាមួយនឹងប្រព័ន្ធគ្រប់គ្រងហានិភ័យ, | ២០១៥ | | - លទ្ធផលនៃសវនកម្មក្រោយការបញ្ចេញទំនិញពីគយត្រូវបានចែករំលែកជាប្រចាំជាមួយប្រព័ន្ធគ្រប់គ្រងហានិភ័យ |
| ៤ | បង្កើតបណ្តាញផ្លាស់ប្តូរព័ត៌មានហានិភ័យស្វ័យប្រវត្តិរវាងការិយាល័យគយពាក់ព័ន្ធដែលបានពីលទ្ធផលនៃការងារសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ, | | ២០១៥ | - បណ្តាញផ្លាស់ប្តូរព័ត៌មានហានិភ័យស្វ័យប្រវត្តិត្រូវបានតភ្ជាប់ជាមួយការិយាល័យគយ ដែលបានលទ្ធ-ផលពីសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ |
| ៥ | រក្សាឯករាជ្យភាពនៃតួនាទីរបស់មន្ត្រីសវនកម្មក្រោយបញ្ចេញទំនិញពីគយដោយមិនត្រូវមានតួនាទីដទៃទៀត នៅកន្លែងធ្វើបែបបទបញ្ចេញទំនិញពី | | ២០១៥ | - ចំនួនករណីមន្ត្រីសវនកម្មក្រោយបញ្ចេញទំនិញពីគយដែលមានតួនាទីលើសពីមួយ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| | គយ។ | | | |
| **៥.២.២** | **ការពង្រឹងយន្តការឆ្លងកាត់** | | | |
| **៥.២.២.១** | **អំពើរត់គេចពន្ធ** | | | |
| ១ | បន្តអនុវត្តផែនការសកម្មភាពរយៈពេល ៦០ ថ្ងៃ ទន្ទឹមនឹងផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីកាត់បន្ថយគ្រប់ទម្រង់នៃអំពើរត់គេចពន្ធ, | ជាប្រចាំ | ជាប្រចាំ | - របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្ម-ភាពរយៈពេល ៦០ ថ្ងៃ ត្រូវបានរៀបចំ និងតាមដានជាប្រចាំ |
| ២ | បញ្ចប់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពដើម្បីបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធរយៈពេលមធ្យម ដោយមានកំណត់សូចនាករ និងរយៈពេលអនុវត្តច្បាស់លាស់, | ២០១៥ | | - ការដាក់ឱ្យអនុវត្តផែនការសកម្មភាពការងារបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ រយៈពេលមធ្យម<br>- ចំនួនករណីអំពើរត់គេចពន្ធត្រូវបានបង្ការ និងបង្ក្រាប<br>- របាយការណ៍វឌ្ឍនភាពជាប្រចាំនៃការអនុវត្តផែនការសកម្មភាពបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ |
| ៣ | ពង្រឹងសមត្ថភាពមន្ត្រីក្នុងការរៀបចំដាក់បណ្ដឹងទៅតុលាការ, | ជាប្រចាំ | ជាប្រចាំ | - ចំនួនបទល្មើសបង្ក្រាប ដែលត្រូវបានដាក់ពាក្យបណ្ដឹង |
| ៤ | ពង្រឹងអនុលោមភាពនៃការប្រើប្រាស់ទំនិញក្រោមរបបអនុគ្រោះពន្ធគយ, | ជាប្រចាំ | ជាប្រចាំ | - របាយការណ៍ប្រើប្រាស់ទំនិញក្រោមរបបអនុគ្រោះពន្ធអាករ ដែលមិនត្រូវតាមគោលដៅ |
| ៥ | ដាក់ឱ្យអនុវត្តនូវតែមប្រើសម្គាល់យានយន្តនាំចូលដែលរួចពន្ធ និងបង្កើតប្រព័ន្ធ គ្រប់គ្រងទិន្នន័យគ្រប់គ្រងយានយន្ត ដែលមានម្ចាស់ដោយសហ-ការជាមួយ អាជ្ញាធរមូលដ្ឋាន និងធ្វើការផ្ទៀងផ្ទាត់ស្លាកលេខយានយន្ត | ២០១៥ | | - ការដាក់ឱ្យអនុវត្តតែមប្រើសម្គាល់យានយន្តនាំចូលដែលរួចពន្ធ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យយានយន្តត្រូវបានអនុវត្ត |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| | ខុសច្បាប់ ដើម្បីកាត់បន្ថយអំពើរត់គេចពន្ធ, | | | |
| ៦ | រៀបចំឱ្យមានសន្និធិគយបណ្តោះអាសន្ននៅតាមមាត់ច្រកព្រំដែន និងតាមតំបន់ប្រជុំជនបន្ថែមសំដៅកាត់បន្ថយការជញ្ជូនទំនិញតាមរូបភាពបំបែកទំនិញ និងបង្កភាពងាយស្រួលដល់ធុរជនក្នុងការបំពេញបែបបទគយ, | ២០១៥ | | - ចំនួនសន្និធិគយបណ្តោះអាសន្នតាមមាត់ច្រកព្រំដែន និងតាមតំបន់ទីប្រជុំជនចាំបាច់ ត្រូវបានរៀបចំ |
| ៧ | កែសម្រួលសមាសភាពគណៈកម្មាធិការអន្តរក្រសួងទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ដែលត្រូវបានកំណត់ដោយបទបញ្ជាលេខ ០២បប របស់រាជរដ្ឋាភិបាលចុះថ្ងៃ ១៩ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធ។ | ២០១៥ | | - សមាសភាពថ្មីនៃគណៈកម្មាធិការតាមឋានៈ និងតួនាទីត្រូវបានរៀបចំ |
| ៥.២.២.២ | **តម្លៃគិតពន្ធគយ** | | | |
| ១. | សិក្សា និងវាយតម្លៃពីលទ្ធភាពនៃការអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចប្រកាសតម្លៃគិតពន្ធគយលើទំនិញនាំចេញ-នាំចូលក្រោមរបបអនុគ្រោះពន្ធតាមតម្លៃចម្លងការ។ | ២០១៥ | | - ការប្រកាសតម្លៃគិតពន្ធគយទំនិញក្រោមរបបអនុគ្រោះពន្ធអាករតាមតម្លៃចម្លងការ |
| ៥.២.៣ | **ការពង្រឹងយន្តការគាំទ្រ** | | | |
| ៥.២.៣.១ | **ប្រព័ន្ធអាស៊ីគូដា** | | | |
| ១ | តភ្ជាប់ប្រព័ន្ធអាស៊ីគូដាជូនតំណាងស្ថាប័នពាក់ព័ន្ធនៅតាមមាត់ច្រក និងនាយកដ្ឋានរដ្ឋាករ, | ២០១៥ | | - ប្រព័ន្ធអាស៊ីគូដា ដែលមានមុខងារពេញលេញត្រូវបានតភ្ជាប់ទៅតាមស្ថាប័នពាក់ព័ន្ធនៅមាត់ច្រក និងនាយកដ្ឋានរដ្ឋាករ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| ២ | តភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិអាស៊ីគូដាជាមួយនឹងប្រព័ន្ធគ្រប់គ្រងហានិភ័យគយ, ប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រព័ន្ធបញ្ជរតែមួយអាស៊ាន, | | ២០១៦ | - ប្រព័ន្ធស្វ័យប្រវត្តិអាស៊ីគូដាត្រូវបានតភ្ជាប់ពេញលេញនឹងប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រព័ន្ធបញ្ជរតែមួយអាស៊ាន |
| ៣ | ពង្រីកមុខងាររបស់ប្រព័ន្ធអាស៊ីគូដាដែលនៅសេសសល់។ | | ២០១៧ | - ម៉ូឌុលសេសសល់នៃប្រព័ន្ធអាស៊ីគូដាត្រូវបានពង្រីក និងប្រើប្រាស់ពេញលេញ |
| ៥.២.៣.២ | ប្រព័ន្ធបញ្ជរតែមួយជាតិ | | | |
| ១ | ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិឱ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន, | ២០១៦ | | - ការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិមានលក្ខណៈពេញលេញតាមបទប្បញ្ញត្តិ |
| ២ | ភ្ជាប់ប្រព័ន្ធបញ្ជរតែមួយជាតិជាមួយប្រព័ន្ធបញ្ជរតែមួយអាស៊ានសម្រាប់គម្រោងសាកល្បង ដែលនឹងត្រូវអនុវត្ត, | | ២០១៦ | - ការតភ្ជាប់រួចរាល់នៃប្រព័ន្ធបញ្ជរតែមួយជាតិទៅនឹងប្រព័ន្ធបញ្ជរតែមួយអាស៊ាន |
| ៣ | ពង្រឹងប្រសិទ្ធភាពការងាររវាងស្ថាប័នរដ្ឋនិងធុរជន ស្ថាប័នរដ្ឋនិងស្ថាប័នរដ្ឋ និង ធុរជននិងធុរជន ដើម្បីគាំទ្រការអនុវត្តប្រព័ន្ធនេះរយៈពេលយូរ។ | | ២០១៧ | - របាយការណ៍វឌ្ឍនភាពស្តីពីសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋនិងធុរជន ស្ថាប័នរដ្ឋនិងស្ថាប័នរដ្ឋ និង ធុរជននិងធុរជន ដែលពាក់ព័ន្ធ |
| ៥.២.៣.៣ | យន្តការសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន | | | |
| ១ | រៀបចំកិច្ចប្រជុំយន្តការភាពជាដៃគូពិភាក្សាដោះស្រាយបញ្ហា ឬកង្វល់នានារបស់ធុរជន, | រៀងរាល់ឆមាស | រៀងរាល់ឆមាស | - ចំនួនយោបល់ត្រឡប់ និងអនុសាសន៍ ដែលបានទទួលពីវិស័យឯកជន |
| ២ | ដាក់ឱ្យអនុវត្តយន្តការលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់។ | ២០១៤ | | - តាមដានអនុលោមភាពកិច្ចប្រតិបត្តិការរបស់ប្រតិបត្តិករសេដ្ឋកិច្ចទទួលសិទ្ធិ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
|---|---|---|---|---|
| ៥.២.៣.៤ | ផែនការអភិវឌ្ឍន៍ស្ថាប័ន | | | |
| ១ | រៀបចំផែនការអភិវឌ្ឍន៍ស្ថាប័ន ដែលមានដាក់ចេញទស្សនៈវិស័យរយៈពេលវែង។ | ២០១៥ | | - ផែនការអភិវឌ្ឍន៍ស្ថាប័នផ្អែកលើទស្សនវិស័យរយៈពេលវែងត្រូវបានរៀបចំ និងបញ្ចប់ |
| ៥.២.៣.៥ | ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ | | | |
| ១ | ពង្រឹងកិច្ចដំណើរការនៃគណៈកម្មាធិការកែទម្រង់គយឡើងវិញ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តការងារកែទម្រង់នេះ។ | ២០១៥ | | - របាយការណ៍វាយតម្លៃវឌ្ឍនភាពការងារ និងបញ្ហាប្រឈមនៃការងារកែទម្រង់ |
| ៥.២.៣.៦ | ការគ្រប់គ្រងធនធានមនុស្ស | | | |
| ១ | កាត់បន្ថយនូវការប្រគល់ភារកិច្ចច្រើនកន្លែងដល់មន្ត្រីគយម្នាក់ៗក្នុងពេលតែមួយ, | ២០១៥ | | - ចំនួនមន្ត្រីគយ ដែលមានភារកិច្ចច្រើនកន្លែងលើសពីមួយត្រូវបានកាត់បន្ថយ |
| ២ | ពង្រឹងការគោរពប្រតិបត្តិក្រមសីលធម៌របស់មន្ត្រីគយ, | ជាប្រចាំ | ជាប្រចាំ | - របាយការណ៍តាមដានការគោរពប្រតិបត្តិក្រម-សីលធម៌របស់មន្ត្រីគយ<br>- ចំនួនពាក្យបណ្ដឹងដែលទទួលបាន |
| ៣ | ពង្រឹងសមត្ថភាពមន្ត្រីគយតាមរយៈការបណ្ដុះបណ្ដាលជំនាញចាំបាច់ទាំងឡាយ, | ជាប្រចាំ | ជាប្រចាំ | - ចំនួនវគ្គបណ្ដុះបណ្ដាលជំនាញ<br>- ចំនួនមន្ត្រីទទួលបានការបណ្ដុះបណ្ដាល |
| ៤ | ពង្រីកវិសាលភាពប្រអប់តវ៉ាគយ និងបង្កើតឱ្យមានមន្ត្រីទំនាក់ទំនងសាធារណៈនៅតាមសាខាការិយាល័យគយ និងរដ្ឋាករនាមាត់ច្រកសំខាន់ៗទាំងអស់, | ២០១៥ | | - ចំនួនប្រអប់តវ៉ាគយត្រូវបានដំឡើង<br>- ចំនួនមន្ត្រីទំនាក់ទំនងសាធារណៈនៅតាមសាខាការិយាល័យគយ និងរដ្ឋាករ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករត្រួតពិនិត្យ |
| --- | --- | --- | --- | --- |
| | | | | - ចំនួនបណ្តឹងតវ៉ា ឬការបង្ហាញនូវកង្វល់/ យោបល់របស់ធុរជនត្រូវបានទទួល |
| ៥ | បង្កើតឱ្យមានមន្ត្រីទំនាក់ទំនងសាធារណៈនៅតាមសាខាការិយាល័យគយ និងរដ្ឋាករសំខាន់ៗមួយចំនួន។ | ២០១៥ | | - ចំនួនមន្ត្រីទំនាក់ទំនងសាធារណៈ |
| ៥.២.៣.៧ | សវនកម្មផ្ទៃក្នុង | | | |
| ១ | ជំរុញកិច្ចដំណើរការពេញលេញរបស់ការិយាល័យសវនកម្មផ្ទៃក្នុងតាមតួនាទី និងភារកិច្ច ដែលត្រូវបានកំណត់ដោយបទប្បញ្ញត្តិជាធរមានដោយ ផ្តល់មធ្យោបាយធ្វើការងារ និងធនធានមនុស្សសមស្រប, | ២០១៥ | | - ភាពពេញលេញនៃការបំពេញមុខងាររបស់ការិយា-ល័យសវនកម្មផ្ទៃក្នុង |
| ២ | បង្កើតប្រព័ន្ធរបាយការណ៍លទ្ធផលសវនកម្មផ្ទៃក្នុងទៀងទាត់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, | ២០១៥ | | - របាយការណ៍លទ្ធផលសវនកម្មផ្ទៃក្នុងត្រូវបានរៀបចំជាប្រចាំ |
| ៣ | ជំរុញកិច្ចសហការរវាងការិយាល័យសវនកម្មផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាមួយអង្គភាពសវនកម្មផ្សេងទៀត។ | ជាប្រចាំ | ជាប្រចាំ | - របាយការណ៍ស្តីពីកិច្ចសហការរវាងការិយាល័យសវនកម្មផ្ទៃក្នុងនៃ អ.គ.រ និងអង្គភាពសវនកម្មផ្សេងទៀត |

## ឧបសម្ព័ន្ធ ៣: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៥.៣.១ | បរិការណ៍ និងបញ្ហាប្រឈមនៃចំណូលមិនមែនសារពើពន្ធ | | | |
| ១ | ក្រសួង-ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធទាំងអស់ត្រូវចាត់តាំងថ្នាក់ដឹកនាំ ដែលជាសមាជិករាជរដ្ឋាភិបាលមួយរូប ដើម្បីទទួលខុសត្រូវក្នុងការតាមដាន, ការកត់ត្រា, ការកៀរគរចំណូល និងការចាត់វិធានការតឹងទារបំណុលនៅក្រោមសមត្ថកិច្ចក្រសួង-ស្ថាប័នរបស់ខ្លួន, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គភាព ដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | ២០១៥ | | - សមាជិករាជរដ្ឋាភិបាលមួយរូបត្រូវបានតែងតាំង |
| ២ | បន្តពង្រឹង និងជំរុញការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់, **(ទទួលបន្ទុកដោយគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពប្រមូលចំណូលពាក់ព័ន្ធទាំងអស់)** | រៀងរាល់ឆមាស | | - យន្តការពង្រឹង និងជំរុញការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ត្រូវបានដាក់ចេញ |
| ៣ | បន្តជំរុញ និងប្រើប្រាស់ប្រព័ន្ធធនាគារក្នុងការបង់ចំណូលមិនមែនសារពើពន្ធ, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គភាពដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | ២០១៥ | | - វិធានការជំរុញនូវការប្រើប្រាស់ធនាគារ និងរបាយការណ៍វឌ្ឍនភាពស្តីពីការប្រើប្រាស់ |
| ៤ | ជំរុញការបង់ចំណូលមិនមែនសារពើពន្ធពីក្រសួង-ស្ថាប័នចូលទៅក្នុងគណនីទោលរតនាគារឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គភាព ដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | ២០១៥ | | - យន្តការជំរុញការបង់ចំណូលទៅក្នុងគណនីទោលរតនាគារ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៥ | បន្តជំរុញការដាក់ឱ្យអនុវត្ត និងការកែលម្អស្តង់ដារសេវាសម្រាប់ការបង់ចំណូលមិនមែនសារពើពន្ធឱ្យមានភាពងាយស្រួល និងមានតម្លាភាព, គណនេយ្យភាព និងទាន់ពេលវេលា, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គភាព ដែលប្រមូលចំណូលទាំងអស់)** | ២០១៥ | | - ការដាក់វិធានការជំរុញ និងកែលម្អ និងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត និងការកែលម្អ |
| ៦ | រៀបចំ និងដាក់អនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងកំណត់សមត្ថកិច្ចឱ្យបានច្បាស់លាស់រវាងក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការកត់ត្រា, ការតាមដាន និងការកៀរគរចំណូលមិនមែនសារពើពន្ធ, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គភាព ដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | ២០១៥ | | - លិខិតគតិយុត្តស្តីពីការកំណត់សមត្ថកិច្ច និងភារកិច្ចក្នុងការកត់ត្រា, ការតាមដាន និងការកៀរគរចំណូលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ៧ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចាត់វិធានការជំរុញក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពង្រឹងកិច្ចការប្រមូលចំណូលនិងបំណុលមិនមែនសារពើពន្ធស្របតាមបទដ្ឋានគតិយុត្ត និងគោលការណ៍កំណត់ជាធរមាន, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ការដាក់ចេញជាវិធានការ និងការវាយតម្លៃពីលទ្ធផលជាបន្តបន្ទាប់ |
| ៨ | ក្រសួងស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវប្រគល់កិច្ចសន្យា, កិច្ចព្រមព្រៀង, អាជ្ញាបណ្ណ, សៀវភៅបន្ទុក និងឯកសារពាក់ព័ន្ធគ្រប់ប្រភេទមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំទិន្នន័យសម្រាប់តាមដានការបង់ | ២០១៥ | | - របាយការណ៍រួម ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យា, កិច្ចព្រមព្រៀង, អាជ្ញាបណ្ណ, សៀវភៅបន្ទុក និងឯកសារពាក់ព័ន្ធ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
| --- | --- | --- | --- | --- |
| | ចំណូល, ការអនុវត្តកិច្ចសន្យា, កិច្ចព្រមព្រៀង, អាជ្ញាបណ្ណ និងសៀវភៅបន្ទុក និងការជំរុញការបង់ចំណូល រួមទាំងការដាក់ចេញនូវវិធានការចាំបាច់នានា, **(ទទួលបន្ទុកដោយគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាព ដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | | | |
| ៩ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំទម្រង់គំរូសម្រាប់ការរៀបចំរបាយការណ៍ចំណូលឱ្យដល់ក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់-ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីរៀបចំ និងផ្ញើរបាយការណ៍ចំណូលប្រចាំខែទៀងទាត់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ទម្រង់គំរូសម្រាប់ការរៀបចំរបាយការណ៍ចំណូលត្រូវបានដាក់ឱ្យប្រើប្រាស់ |
| ១០ | កែសម្រួលក្រុមការងារ ដែលបានបង្កើតហើយ និងបង្កើតក្រុមការងារអន្តរ-ក្រសួងជាបន្ទាន់ចំពោះវិស័យណា ដែលមិនទាន់មាន ដើម្បីទារបំណុលតាមនីតិវិធី, គោលការណ៍ និងបទប្បញ្ញត្តិជាធរមានដូចជា វិស័យអាកាស-ចរណ៍ស៊ីវិល, វិស័យទេសចរណ៍, វិស័យទូរគមនាគមន៍ និងវិស័យផ្សេងៗទៀត, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាមីមានបំណុល)** | ២០១៥ | | - ការកែសម្រួល និងបង្កើតបានក្រុមការងារ និងលទ្ធ-ផលនៃការទារបំណុល |
| ១១ | ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋ-បាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, **(ទទួលបន្ទុកដោយអាជ្ញាធរសវនកម្មជាតិ)** | រៀងរាល់ឆ្នាំ | | - ចំនួនរបាយការណ៍សវនកម្ម |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
| --- | --- | --- | --- | --- |
| ១២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ស្តីពីស្ថានភាពនៃការតាមដាន, កត់ត្រា និងប្រមូលចំណូល ឬការលាក់ទុកចំណូលរបស់ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយស្នើសុំមានវិធានការលើកទឹកចិត្តសម្រាប់ស្ថាប័នទាំងឡាយណា ដែលប្រមូលចំណូលបានល្អ និងមានវិធានការរដ្ឋបាលតឹងរ៉ឹងចំពោះស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដែលប្រមូលចំណូលមិនបានល្អ ឬលាក់ចំណូល ដោយមិនរាប់បញ្ចូលនូវទោសទណ្ឌផ្សេងទៀតស្របតាមច្បាប់ជាធរមាន, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | រៀងរាល់ឆ្នាំ | | - របាយការណ៍គោរពជូននាយករដ្ឋមន្ត្រី |
| ១៣ | ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ ដែលមានភារកិច្ចទារបំណុលត្រូវធ្វើរបាយការណ៍លម្អិតប្រចាំត្រីមាសកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីយន្តការ និងលទ្ធផលនៃការទារបំណុល, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដែលទទួលបន្ទុកទារបំណុល)** | រៀងរាល់ឆមាស | | - របាយការណ៍លម្អិតស្តីពីយន្តការ និងលទ្ធផលនៃការទារបំណុល |
| ១៤ | ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការចាត់វិធានការព្រមាន, ដកហូតអាជ្ញាបណ្ណ, លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ និងវិធានការចាំបាច់ផ្សេងៗទៀតតាមការអនុញ្ញាតរបស់ច្បាប់ ក្នុងករណីក្រុមហ៊ុនមិនមានចំណាត់ការណាមួយក្នុងការសងបំណុល, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គ-** | រៀងរាល់ឆមាស | | - វិធានការព្រមាន, ដកហូតអាជ្ញាបណ្ណ, លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | **ភាពពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | | |
| ១៥ | ផ្តល់សិទ្ធអំណាចគ្រប់គ្រងតាមច្បាប់, ធនធាន និងមធ្យោបាយសមស្រប សម្រាប់មន្ត្រីចុះត្រួតពិនិត្យ និងប្រមូលចំណូលមិនមែនសារពើពន្ធ, **(ទទួលបន្ទុកដោយក្រសួងសាមី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ការផ្តល់សិទ្ធិអំណាចគ្រប់គ្រាន់, ធនធាន និងមធ្យ-បាយត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ១៦ | សិក្សាពីការរៀបចំយន្តការលើកទឹកចិត្តដល់មន្ត្រីពាក់ព័ន្ធ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល, **(ទទួលបន្ទុកដោយក្រសួងសាមី)** | ២០១៥ | | - យន្តការលើកទឹកចិត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុ-វត្ត |
| ១៧ | រៀបចំការពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មជាយថាហេតុលើកិច្ចព្រម-ព្រៀង ឬកិច្ចសន្យាណាមួយ ដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរាជរដ្ឋាភិបាល, **(ទទួលបន្ទុកដោយក្រសួងសាមីនីមួយៗ ដែលជាម្ចាស់អចលនទ្រព្យ)** | | ២០១៦ | - ចំនួនកិច្ចព្រមព្រៀង ឬកិច្ចសន្យាដែលត្រូវពិនិត្យ និងកែប្រែឡើងវិញ |
| ១៨ | រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដោយភ្ជាប់បណ្តាញទំនាក់ទំនងរវាងអគ្គ-នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងរដ្ឋទេយ្យករចំណូលរបស់ក្រសួង-ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលបន្ទុកចំណូល ដើម្បីកត់ត្រាចំណូល,តាមដានការបង់ចំណូល និងចាត់វិធានការបង់ចំណូលឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព, **(ទទួលបន្ទុកដោយគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | | ២០១៧ | - ប្រព័ន្ធគ្រប់គ្រងទិន្នន័យត្រូវបានដាក់ឱ្យប្រើប្រាស់ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ១៩ | រៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការបណ្តុះបណ្តាលជំនាញតាមវិស័យដល់មន្ត្រី ដែលគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ, **(ទទួលបន្ទុកដោយក្រសួងសាមី)** | | ២០១៦ | - ផែនការបណ្តុះបណ្តាលជំនាញត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ២០ | រៀបចំក្រុមការងារមួយដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋ ដោយផ្សារភ្ជាប់ជាមួយនឹងការសិក្សាអំពីភាពប្រកួតប្រជែងរបស់កម្ពុជាពាក់ព័ន្ធនឹងកម្រៃសេវានីមួយៗនៅក្នុងតម្លៃនៃការធ្វើធុរកិច្ច, អាជីវកម្ម និងពាណិជ្ជកម្មជារួម ដោយប្រៀបធៀបជាមួយប្រទេសជិតខាងក្នុងតំបន់ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រធ្វើការកែតម្រូវកម្រៃសេវា និងរង្វាន់លើកទឹកចិត្តផ្សារភ្ជាប់ជាមួយនឹងការកែទម្រង់បៀវត្សក្នុងគោលដៅបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | | ២០១៦ | - ក្រុមការងារ និងលទ្ធផលនៃការវាយតម្លៃពីប្រសិទ្ធភាពនៃការប្រមូលចំណូល |
| ៥.៣.២ | វិស័យអាកាសចរណ៍ស៊ីវិល | | | |
| ១ | ពិនិត្យ និងសិក្សាអំពីការកែប្រែកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជាស្តីពីការបែងចែកចំណូលដោយផ្អែកលើការវិនិយោគជាក់ស្តែងរបស់ក្រុមហ៊ុនលើការពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវា | ២០១៥ | | - លទ្ធផលនៃការពិនិត្យ និងសិក្សា |

| ល.រ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | ព្រលានយន្តហោះ និងដោយយោងទៅតាមកំណើនសេដ្ឋកិច្ច និងចំណូលនៃវិស័យនេះ, **(ទទួលបន្ទុកដោយទីស្តីការគណៈរដ្ឋមន្ត្រី)** | | | |
| ២ | ពិនិត្យ និងសិក្សាឡើងវិញនូវការផ្តល់រង្វាន់លើកទឹកចិត្តដល់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល)** | ២០១៥ | | - លទ្ធផលស្តីពីការពិនិត្យ និងសិក្សា |
| ៥.៣.៣ | **វិស័យទេសចរណ៍** | | | |
| ១ | សិក្សាលទ្ធភាពដំឡើងកម្រៃអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ, **(ទទួលបន្ទុកដោយក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - លទ្ធផលស្តីពីលទ្ធភាពដំឡើង និងការដំឡើងជាយថាហេតុណាមួយ |
| ២ | បង្កើតការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, **(ទទួលបន្ទុកដោយក្រសួងទេសចរណ៍)** | ២០១៥ | | - ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន |
| ៣ | បង្កើតក្រុមការងារអន្តរក្រសួងថ្មី ដើម្បីចុះស្រាវជ្រាវ, ពិនិត្យ និងតាមដានចំណូលផ្សេងៗទៀតពីវិស័យទេសចរណ៍, **(ទទួលបន្ទុកដោយក្រសួងទេសចរណ៍)** | ២០១៥ | | - ក្រុមការងារ និងលទ្ធផលបឋមស្តីពីការចុះស្រាវជ្រាវ, ពិនិត្យ និងតាមដាន |
| ៤ | សិក្សាអំពីលទ្ធភាពដំឡើងថ្លៃសំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានទេសចរណ៍នានា, **(ទទួលបន្ទុកដោយក្រសួងទេសចរណ៍)** | ២០១៥ | | - លទ្ធភាពដំឡើងថ្លៃសំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានទេសចរណ៍នានា |
| ៥ | កំណត់ឱ្យមានការធ្វើចំណាត់ថ្នាក់សណ្ឋាគារមុននឹងបន្តអាជ្ញាបណ្ណទេសចរណ៍អាជីវកម្មសណ្ឋាគារ, **(ទទួលបន្ទុកដោយក្រសួងទេសចរណ៍)** | ២០១៥ | | - លិខិតគតិយុត្តស្តីពីការធ្វើចំណាត់ថ្នាក់សណ្ឋាគារមុននឹងបន្តអាជ្ញាបណ្ណទេសចរណ៍អាជីវកម្មសណ្ឋាគារ |
| ៦ | លើកកម្ពស់ និងពង្រឹងប្រសិទ្ធភាពនៃក្រុមការងារវាយតម្លៃ និងធ្វើចំណាត់ថ្នាក់សណ្ឋាគារ ដែលដឹកនាំដោយក្រសួងទេសចរណ៍, **(ទទួលបន្ទុកដោយ** | ២០១៥ | | - យន្តការលើកកម្ពស់ និងពង្រឹងប្រសិទ្ធភាព |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | **ក្រសួងទេសចរណ៍ និងក្រសួងស្ថាប័នពាក់ព័ន្ធ)** | | | |
| ៧ | ចាត់វិធានការជំរុញបង្កើនចំណូលកិច្ចសន្យាសម្បទានស្តីពីការប្រមូលចំណូលនៃរមណីយដ្ឋានទេសចរណ៍ រួមទាំងពិនិត្យលទ្ធភាពកែប្រែកិច្ច-សន្យាមួយចំនួនដែលមានការចាំបាច់, **(ទទួលបន្ទុកដោយក្រសួងទេសចរណ៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ)** | | ២០១៦ | - វិធានការជំរុញបង្កើនចំណូល និងការកើនឡើងចំណូល |
| ៨ | បង្កើតឱ្យមានប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ។ **(ទទួលបន្ទុកដោយក្រសួងទេសចរណ៍)** | | ២០១៦ | - ការសម្រេចបាននូវប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍ |
| ៥.៣.៤ | ចំណូលពីអាករស្ថានទូត | | | |
| ១ | បន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចររួមមាន ច្រកអន្តរជាតិ និងស្ថានទូត, ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយស, រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ, ប្រចាំត្រីមាស, ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់ និងច្បាស់លាស់, **(ទទួលបន្ទុកដោយក្រសួងមហាផ្ទៃ និងក្រសួងការ-បរទេស និងសហប្រតិបត្តិការអន្តរជាតិ)** | ជាប្រចាំខែ/ត្រីមាស/ឆមាស/ និងប្រចាំឆ្នាំ | | - វិធានការជំរុញ និងលទ្ធផល |
| ២ | ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវរៀបចំរបាយការណ៍ទាំងបីប្រភេទខាងលើ ហើយត្រូវឆ្លុះបញ្ចាំងគ្នាទៅវិញទៅមក ព្រមទាំងមានមូលដ្ឋានអាចវាស់វែង និងវាយតម្លៃពីការគ្រប់គ្រងបាន , **(ទទួលបន្ទុកដោយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និង** | រៀងរាល់ត្រីមាស | | - របាយការណ៍ទាំងបីប្រភេទស្តីពីចំណូលអាករស្ថាន-ទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | **សហប្រតិបត្តិការអន្តរជាតិ)** | | | |
| ៣ | អង្គភាពអនុវត្តការផ្តល់ទិដ្ឋាការត្រូវរក្សាគល់សន្លឹកទិដ្ឋាការ និងគល់បង្កាន់ដៃបង់ប្រាក់សម្រាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់, **(ទទួលបន្ទុកដោយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)** | រៀងរាល់ត្រីមាស | | - ការរក្សាគល់សន្លឹកទិដ្ឋាការ និងគល់បង្កាន់ដៃបង់ប្រាក់ |
| ៤ | ជំរុញអនុវត្តនីតិវិធីនៃការកត់ត្រា តាមដានសន្និធិសន្លឹកទិដ្ឋាការ និងសន្និធិបង្កាន់ដៃបង់ប្រាក់ទៅតាមវិធីសាស្ត្រឃ្លាំងសន្និធិ (Stock Inventory), **(ទទួលបន្ទុកដោយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)** | ២០១៥ | | - យន្តការជំរុញអនុវត្តនីតិវិធី |
| ៥ | រៀបចំសារាចរណែនាំស្តីពីការគ្រប់គ្រងចំណូលពីអាករស្នាទទូត និងគ្រប់-គ្រងសន្លឹកទិដ្ឋាការ ដើម្បីជាបន្ទាត់ក្នុងការផ្ទៀងផ្ទាត់បញ្ជាំងរវាងសន្លឹកទិដ្ឋាការ ដែលបានប្រើប្រាស់ និងចំណូលពីអាករស្នាទទូត, **(ទទួលបន្ទុកដោយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរ-ជាតិ)** | | ២០១៧ | - សារាចរណែនាំស្តីពីការគ្រប់គ្រងចំណូលពីអាករស្នាទទូត និងគ្រប់គ្រងសន្លឹកទិដ្ឋាការត្រូវបានដាក់ឱ្យអនុវត្ត |
| ៦ | រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរតាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ។ **(ទទួលបន្ទុកដោយក្រសួងការបរទេស និងសហប្រតិ-បត្តិការអន្តរជាតិ)** | | ២០១៦ | - កម្រៃសេវាធ្វើដំណើរត្រូវបានដាក់ឱ្យអនុវត្ត |
| ៥.៣.៥ | **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍** | | | |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ១ | លើកកម្ពស់ និងពង្រឹងប្រសិទ្ធភាពការងារនៃក្រុមការងារអន្តរក្រសួងសម្រាប់ទារបំណុលវិស័យទូរគមនាគមន៍, **(ទទួលបន្ទុកដោយក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលទទួលបន្ទុកប្រមូលចំណូលមិនមែនសារពើពន្ធ)** | ២០១៥ | | - ចំនួនបំណុលដែលទារបាន |
| ២ | ជំរុញការរៀបចំ និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលគ្រប់គ្រងព័ត៌មានទូរគមនាគមន៍ (DMC) ឱ្យបានឆាប់, **(ទទួលបន្ទុកដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)** | ២០១៥ | | - មជ្ឈមណ្ឌលគ្រប់គ្រងព័ត៌មានទូរគមនាគមន៍ត្រូវបានដាក់ឱ្យដំណើរការ |
| ៣ | ដកហូត ឬលុបចោលនូវអាជ្ញាបណ្ណ ឬកិច្ចសន្យាណា ដែលមិនត្រូវបានអនុវត្ត, **(ទទួលបន្ទុកដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)** | ២០១៥ | | - ចំនួនកិច្ចសន្យា ឬអាជ្ញាបណ្ណ ដែលបានដកហូត និងលុបចោល |
| ៤ | ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍, **(ទទួលបន្ទុកដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)** | ២០១៦ | | - ការដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍ |
| ៥ | រៀបចំ និងធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃសណីយ៍, **(ទទួលបន្ទុកដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)** | | ២០១៦ | - ការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃសណីយ៍ |
| ៦ | រៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយប្រៃសណីយ៍ និងទូរគមនាគមន៍, គោលនយោបាយប្រដែបនជាតិ (National Broadband Policy) និងគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។ **(ទទួលបន្ទុកដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)** | | ២០១៧ | - ការដាក់ឱ្យអនុវត្តគោលនយោបាយប្រៃសណីយ៍ និងទូរគមនាគមន៍, គោលនយោបាយប្រដែបនជាតិ, និងគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ |
| ៥.៣.៦ | ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងចំណូលពីផល-អនុផលព្រៃឈើ | | | |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ១ | រៀបចំ និងដាក់ឱ្យអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ស្តីពីការលក់ និងផ្ទេរសិទ្ធសម្បទានដីសេដ្ឋកិច្ច, ប្រកាសរួមស្តីអំពីនីតិវិធីនៃការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច និងប្រកាសរួមស្តីពីការបង្កើតយន្តការ និងនីតិវិធីក្នុងការគ្រប់គ្រង និងការប្រមូលចំណូលពីផល-អនុផលព្រៃឈើលើសម្បទានដីសេដ្ឋកិច្ច, រ៉ាវីអគ្គិសនី, ទំនប់អាងស្រោចស្រព និងពីប្រភពផ្សេងៗទៀត, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន)** | ២០១៥ | | - ប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ២ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ត្រូវជំរុញឱ្យសម្បទានិកបង់ និងបង់រំលឹកចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋតាមគោលការណ៍របស់រាជរដ្ឋាភិបាលនៅលើដី ដែលបានអនុញ្ញាតឱ្យឈួសឆាយ ក្នុងតម្លៃ ៥ ដុល្លារអាមេរិក/ហិកតា/ឆ្នាំ ចាប់ពីឆ្នាំទី ៦ បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច, **(ទទួលបន្ទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថាន)** | ២០១៥ | | - បរិមាណចំណូលពីការបង់រំលឹក |
| ៣ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានត្រូវរៀបចំទិន្នន័យសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដើម្បីគ្រប់គ្រង និងតាមដានការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ក្នុងនោះរួមមានការតាមដានការបង់ចំណូលជូនរដ្ឋផងដែរ, **(ទទួលបន្ទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន)** | ២០១៥ | | - ទិន្នន័យសម្បទានដីសេដ្ឋកិច្ចទាំងអស់ និងលទ្ធផលនៃការគ្រប់គ្រង និងតាមដានត្រូវបានរៀបចំ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៤ | រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងសម្បទានដីសេដ្ឋកិច្ច និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន, **(ទទួលបន្ទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន)** | ២០១៥ | | - ការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ៥ | សិក្សាលើគោលនយោបាយតម្លៃសម្បទានដីសេដ្ឋកិច្ច ដោយពិចារណាទៅលើភាពទាក់ទាញសម្រាប់អ្នកវិនិយោគ និងផលប្រយោជន៍សមស្របជូនរាជរដ្ឋាភិបាល, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន)** | | ២០១៦ | - លទ្ធផលនៃការសិក្សាលើគោលនយោបាយតម្លៃសម្បទានដីសេដ្ឋកិច្ច និងការសម្រេចណាមួយ |
| ៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានត្រូវធ្វើបញ្ជីសារពើភ័ណ្ឌសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដោយធានាឱ្យមានសង្គតិភាពទៅនឹងការចុះបញ្ជីដីរដ្ឋ។ **(ទទួលបន្ទុកដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន)** | | ២០១៧ | - បញ្ជីសារពើភ័ណ្ឌសម្បទានដីសេដ្ឋកិច្ចទាំងអស់ត្រូវបានរៀបចំ និងបញ្ចប់ |
| **៥.៣.៧** | **ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍** | | | |
| ១ | រៀបចំនិងដាក់ឱ្យអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្ដីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាន ដើម្បីពិនិត្យតាមដានឱ្យបានម៉ឺងម៉ាត់លើការអនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុន, កាតព្វកិច្ចបង់ចំណូលជូនរដ្ឋ និងដាក់អនុវត្តយន្តការតឹងទារបំណុល, ពិន័យ ឬស្នើលុបកិច្ច-សន្យា និងរឹបអូសប្រាក់កក់ជាយថាហេតុ ទន្ទឹមនឹងបន្តជំរុញការអនុវត្ត | ២០១៥ | | - ប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្ដីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយ-ដ្ឋានត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
| --- | --- | --- | --- | --- |
| | គម្រោងអភិវឌ្ឍកោះ និងឆ្នេរទាំងនោះ ដើម្បីធ្វើពិពិធកម្មផលិតផលទេសចរណ៍, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)** | | | |
| ២ | រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន។ **(ទទួលបន្ទុកដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - ការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ៥.៣.៨ | ចំណូលពីសហគ្រាសសាធារណៈ | | | |
| ១ | សហគ្រាសសាធារណៈត្រូវរៀបចំផែនការ និងគោលនយោបាយអភិវឌ្ឍន៍រយៈពេលវែងឱ្យបានច្បាស់លាស់, **(ទទួលបន្ទុកដោយសហគ្រាសសាធារណៈនីមួយៗ)** | ២០១៥ | | - ផែនការ និងគោលនយោបាយអភិវឌ្ឍន៍រយៈពេលវែង |
| ២ | ពង្រឹងតួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យអមសហគ្រាសនីមួយៗ ក្នុងការផ្តល់ព័ត៌មាន និងរបាយការណ៍លម្អិតស្តីពីស្ថានភាពហិរញ្ញវត្ថុ, ការគ្រប់គ្រងសហគ្រាស និងបញ្ហាសំខាន់ផ្សេងៗមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដាក់ជាវិធានការទាន់ពេលវេលា, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - វិធានការស្តីពីការពង្រឹងតួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣ | រៀបចំកិច្ចប្រជុំយ៉ាងតិច ២ដង ក្នុងមួយឆ្នាំ រវាងសមាជិកក្រុមប្រឹក្សាភិបាលជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, មន្ត្រីត្រួតពិនិត្យរដ្ឋ, | រៀងរាល់ឆមាស | | - លទ្ធផលនៃកិច្ចប្រជុំរវាងសមាជិកក្រុមប្រឹក្សាភិបាលជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, មន្ត្រីត្រួត- |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | ថ្នាក់ដឹកនាំសហគ្រាស និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | | ពិនិត្យរដ្ឋ, ថ្នាក់ដឹកនាំសហគ្រាស និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងវិធានការជាបន្តបន្ទាប់ |
| ៤ | សហគ្រាសសាធារណៈទាំងអស់មានកាតព្វកិច្ចបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋតាមការកំណត់នៃបទប្បញ្ញត្តិជាធរមាន, **(ទទួលបន្ទុកដោយសហគ្រាសសាធារណៈនីមួយៗ)** | រៀងរាល់ឆ្នាំ | | - បរិមាណនៃការបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋតាមការកំណត់នៃបទប្បញ្ញត្តិជាធរមាន |
| ៥ | សហគ្រាសសាធារណៈត្រូវធ្វើសវនកម្មពេញលេញលើផ្នែកហិរញ្ញវត្ថុពីក្រុមហ៊ុនសវនកម្មឯកជន ដែលមានការទទួលស្គាល់តាមផ្លូវច្បាប់នៅក្នុងប្រទេសកម្ពុជា និងតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **(ទទួលបន្ទុកដោយសហគ្រាសសាធារណៈនីមួយៗ)** | រៀងរាល់ឆ្នាំ | | - របាយការណ៍នៃការធ្វើសវនកម្មផ្នែកហិរញ្ញវត្ថុរបស់សហគ្រាសនីមួយៗ |
| ៦ | ពង្រឹងការត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំនិងធ្វើការផ្ទៀងផ្ទាត់ស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌរបស់សហគ្រាសសាធារណៈ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងករណីចាំបាច់ ការតាមដាន និងការត្រួតពិនិត្យនឹងត្រូវធ្វើដោយក្រុមចម្រុះ ដែលមានការចូលរួមពីអគ្គនាយកដ្ឋានពន្ធដារ, អគ្គាធិការដ្ឋាន, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស)** | រៀងរាល់ឆ្នាំ | | - យន្តការនៃការពង្រឹងការត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៧ | សិក្សា និងរៀបចំកែលម្អបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសហគ្រាសសាធារណៈ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាលបច្ចេកទេស)** | | ២០១៧ | - លទ្ធផលនៃការសិក្សា និងការកែលម្អបទដ្ឋានគតិ-យុត្តពាក់ព័ន្ធការគ្រប់គ្រងសហគ្រាសសាធារណៈ |
| ៨ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសិក្សា និងដឹកនាំរៀបចំនិយាមលើមុខចំណាយសម្រាប់សហគ្រាសនីមួយៗ។ ក្នុងករណី ដែលសហគ្រាសមិនគោរពតាមនិយាម ដែលបានកំណត់សហគ្រាសនោះត្រូវប្រឈមនឹងវិធាន-ការវិន័យ និងទោសទណ្ឌជាធរមាន។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៧ | - និយាមលើមុខចំណាយសម្រាប់សហគ្រាសនីមួយៗ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ៥.៣.៩ | **គ្រឹះស្ថានសាធារណៈរដ្ឋបាល** | | | |
| ១ | ពង្រឹងតួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យអមគ្រឹះស្ថានសាធារ-ណៈនីមួយៗក្នុងការផ្តល់ព័ត៌មាន និងរបាយការណ៍លម្អិតស្តីពីស្ថានភាពហិរញ្ញវត្ថុ, ការគ្រប់គ្រងគ្រឹះស្ថាន និងបញ្ហាសំខាន់ផ្សេងៗមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដាក់ជាវិធានការទាន់ពេលវេលា, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - វិធានការស្តីពីការពង្រឹងតួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ២ | រៀបចំកិច្ចប្រជុំយ៉ាងតិច ២ដង ក្នុងមួយឆ្នាំ រវាងសមាជិកក្រុមប្រឹក្សាភិបាលជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, មន្ត្រីត្រួតពិនិត្យរដ្ឋ, ថ្នាក់ដឹកនាំគ្រឹះស្ថាន និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | រៀងរាល់ឆមាស | | - លទ្ធផលនៃកិច្ចប្រជុំ និងវិធានការជាបន្តបន្ទាប់ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៣ | ពិនិត្យកាត់បន្ថយតាមស្ថានភាពជាក់ស្តែងនូវឧបត្ថម្ភធនពីថវិការដ្ឋ សម្រាប់ដំណើរការរដ្ឋបាលដូចជា ថ្លៃទឹក, ភ្លើង, ទូរស័ព្ទ, សំរាម និងចំណាយផ្សេងៗ ព្រមទាំងកាត់បន្ថយចំណាយវិនិយោគសេដ្ឋកិច្ច និងសង្គមដែលមិនមានប្រសិទ្ធភាព, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - លទ្ធផលនៃការពិនិត្យ និងបរិមាណនៃការកាត់បន្ថយឧបត្ថម្ភធន |
| ៤ | ត្រួតពិនិត្យកិច្ចប្រតិបត្តិការទាំងចំណូល និងចំណាយជាប្រចាំ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | រៀងរាល់ឆមាស | | - លទ្ធផលនៃការត្រួតពិនិត្យ និងវិធានការដាក់ចេញ |
| ៥ | ពង្រឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គ្រប់ប្រភេទចំណូល និងចំណាយ រួមទាំងផែនការអភិវឌ្ឍន៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | រៀងរាល់ឆ្នាំ | | - វិធានការស្តីពីការពង្រឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ |
| ៦ | សិក្សា និងរៀបចំឡើងវិញគ្រប់ជ្រុងជ្រោយនូវក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគ្រឹះស្ថានសាធារណៈរដ្ឋបាល រួមទាំងពិនិត្យលទ្ធភាពឱ្យសហគ្រាសសាធារណៈរដ្ឋបាលដែលមានអតិរេកសាច់ប្រាក់បង់ចូលថវិការដ្ឋ និងកែលម្អលក្ខន្តិកៈគតិយុត្តគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំគ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន, **(ទទួលបន្ទុកដោយក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៦ | - លទ្ធផលនៃការសិក្សា និងការរៀបចំក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគ្រឹះស្ថានសាធារណៈរដ្ឋបាល |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៧ | ពិនិត្យលទ្ធភាពដាក់គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងឡាយណា ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាសហគ្រាសសាធារណៈ, **(ទទួលបន្ទុកដោយក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៧ | - ចំនួនគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលក្លាយទៅជាសហគ្រាសសាធារណៈ |
| ៨ | ពិនិត្យលទ្ធភាពដាក់អង្គភាពរដ្ឋទាំងឡាយណា ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ **(ក្រសួងសាមីនីមួយៗ)** | | ២០១៦ | - ការដាក់អង្គភាពរដ្ឋណាមួយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល |
| **៥.៣.១០** | **ធនធានធម្មជាតិ** | | | |
| ១ | ក្រសួងរ៉ែ និងថាមពលត្រូវរៀបចំទិន្នន័យ និងប្រព័ន្ធតាមដានកាតព្វកិច្ចហិរញ្ញវត្ថុទៅលើកិច្ចសន្យា និងអាជ្ញាបណ្ណដែលក្រសួងបានធ្វើ ឬចេញទៅឱ្យនីតិបុគ្គល ឬរូបវន្តបុគ្គលឯកជន ដោយបញ្ជាក់ផងដែរនូវកិច្ចសន្យា ឬអាជ្ញាបណ្ណដែលបានចេញ, កំពុងអនុវត្តនិងមិនមានដំណើរការ និងការអនុវត្តកិច្ចសន្យា និងអាជ្ញាបណ្ណពាក់ព័ន្ធ, **(ទទួលបន្ទុកដោយក្រសួងរ៉ែ និងថាមពល)** | ២០១៦ | | - ការដាក់ឱ្យប្រើប្រាស់ទិន្នន័យ និងប្រព័ន្ធតាមដាន |
| ២ | រាល់កិច្ចសន្យា និងអាជ្ញាបណ្ណពាក់ព័ន្ធនឹងការចាត់ចែងរ៉ែ និងថាមពលត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីមានសុពលភាពគតិយុត្តស្របតាមមាត្រា ១៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, **(ទទួលបន្ទុកដោយក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ចំនួនកិច្ចសន្យា និងអាជ្ញាបណ្ណ ដែលមិនមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣ | ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធត្រូវផ្សព្វផ្សាយណែនាំដល់រូបវន្ត | ២០១៥ | | - ការផ្សព្វផ្សាយណែនាំ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | បុគ្គល និងនីតិបុគ្គលឯកជនអំពីច្បាប់, បទប្បញ្ញត្តិជាធរមាន និងកាតព្វកិច្ចក្នុងការបង់សួយសារ និងចំណូលដទៃទៀតជូនរដ្ឋ, **(ទទួលបន្ទុកដោយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ)** | | | |
| ៤ | ពង្រឹងកិច្ចសហការបន្ថែមទៀតឱ្យកាន់តែមានប្រសិទ្ធភាពរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងរ៉ែ និងថាមពល, ក្រសួងធនធានទឹក និងឧតុនិយម, ធនាគារជាតិនៃកម្ពុជា, ធនាគារពាណិជ្ជ, អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងមន្ទីរជំនាញពាក់ព័ន្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការកំណត់ការបង់ចំណូលសួយសារ និងការជំរុញឱ្យបង់ចំណូលសួយសារលើអាជីវកម្មធនធានរ៉ែ, សាច់ដី និងខ្សាច់តាមអភិក្រមទីផ្សារ, **(ទទួលបន្ទុកដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងរ៉ែ និងថាមពល, ក្រសួងធនធានទឹក និងឧតុនិយម, ធនាគារជាតិនៃកម្ពុជា, ធនាគារពាណិជ្ជ, អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - វិធានការស្តីពីយន្តការពង្រឹងកិច្ចសហការ និងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការពង្រឹងកិច្ចសហការ |
| ៥ | រៀបចំ និងដាក់ឱ្យអនុវត្តយន្តការផាកពិន័យអន្តរការណ៍ ចំពោះបទល្មើសក្នុងវិស័យធនធានរ៉ែ, **(ទទួលបន្ទុកដោយក្រសួងរ៉ែ និងថាមពល)** | ២០១៥ | | - ការដាក់ឱ្យអនុវត្តយន្តការផាកពិន័យអន្តរការណ៍ចំពោះបទល្មើសក្នុងវិស័យធនធានរ៉ែ |
| ៦ | សិក្សា និងរៀបចំធ្វើការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណ និងកម្រៃសួយសារសម្រាប់ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទ, **(ទទួលបន្ទុកដោយក្រសួងរ៉ែ និងថាមពល)** | | ២០១៦ | - ការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណ និងកម្រៃសួយសារ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៧ | សិក្សា និងរៀបចំកំណត់សន្ទស្សន៍ថ្លៃផលិតផលរ៉ែសម្រាប់គោលដៅវាយតម្លៃសួយសាររ៉ែ។ **(ទទួលបន្ទុកដោយក្រសួងរ៉ែ និងថាមពល)** | | ២០១៧ | - ការសម្រេចបាននូវសន្ទស្សន៍ថ្លៃផលិតផលរ៉ែសម្រាប់គោលដៅវាយតម្លៃសួយសារ |
| ៥.៣.១១ | **ចំណូលពីឯកជនភាវូបនីយកម្ម (ការលក់-ដោះដូរ) និងការជួលទ្រព្យសម្បត្តិរដ្ឋ** | | | |
| ១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យជាក់ស្តែងលើលក្ខខណ្ឌនៃកិច្ច-សន្យាជួលទ្រព្យសម្បត្តិរដ្ឋ, ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យពិភាក្សាថ្លៃឈ្នួលឡើងវិញជាមួយភាគីជួល ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃទីផ្សារ និងឈរលើគោលការណ៍ស្រុះស្រួលគ្នា និងធានាផលប្រយោជន៍ដល់ភាគីទាំង-សងខាង, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - លទ្ធផលនៃការពិនិត្យពិភាក្សាថ្លៃឈ្នួលឡើងវិញ |
| ២ | ជំរុញឱ្យធ្វើបណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋទាំងអស់ ពិសេសទ្រព្យសម្បត្តិរដ្ឋដែលបានជួលឱ្យភាគីឯកជន, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - វិធានការជំរុញឱ្យធ្វើបណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋទាំងអស់ |
| ៣ | សិក្សា និងពិនិត្យលទ្ធភាពកែប្រែកិច្ចសន្យាមួយចំនួន ដែលមិនបានផ្តល់ផលប្រយោជន៍សមរម្យដល់ភាគីរដ្ឋ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៦ | - ចំនួនកិច្ចសន្យាដែលត្រូវបានសិក្សា និងពិនិត្យ |
| ៤ | រៀបចំការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋទាំងអស់, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៧ | - ចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋទាំងអស់ |
| ៥ | ជំរុញការធ្វើបណ្ណកម្មសិទ្ធិរាល់ទ្រព្យសម្បត្តិរដ្ឋទាំងអស់របស់ស្ថាប័នថ្នាក់- | | ២០១៧ | - វិធានការជំរុញការធ្វើបណ្ណកម្មសិទ្ធិរាល់ទ្រព្យសម្បត្តិ |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ, **(ទទួលបន្ទុកដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ)** | | | រដ្ឋទាំងអស់ |
| ៦ | ជំរុញការចុះបញ្ជីសារពើភ័ណ្ឌលើទ្រព្យសម្បត្តិរដ្ឋទាំងអស់ រួមបញ្ចូលទាំងទ្រព្យដែលរឹបអូសបានពីបទល្មើសផ្សេងៗ, ការបញ្ចប់គម្រោងនានារបស់ស្ថាប័នថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ, អំណោយរបស់ដៃគូអភិវឌ្ឍន៍, អង្គការក្រៅរាជរដ្ឋាភិបាល និងសប្បុរសជននានា, **(ទទួលបន្ទុកដោយក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ)** | | ២០១៧ | - យន្តការជំរុញការចុះបញ្ជីសារពើភ័ណ្ឌលើទ្រព្យ-សម្បត្តិរដ្ឋទាំងអស់ |
| ៧ | ជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ដែលស្ថិតនៅក្រៅតារាងតម្លៃពន្ធអចលនទ្រព្យ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៦ | - វិធានការជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ |
| ៨ | ជំរុញការចុះបញ្ជីសារពើភ័ណ្ឌនូវដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៦ | - យន្តការជំរុញការចុះបញ្ជីសារពើភ័ណ្ឌនូវដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់ |
| ៥.៣.១២ | ចំណូលពីកាស៊ីណូ | | | |
| ១ | ខិតខំកៀរគរប្រមូលចំណូលឱ្យអស់លទ្ធភាពពីអាជីវកម្មល្បែងភ្នាល់គ្រប់ប្រភេទដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល, **(ទទួល** | ២០១៥ | | - វិធានការកៀរគរប្រមូលចំណូលឱ្យអស់លទ្ធភាព |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | បន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | | | |
| ២ | រៀបចំយន្តការទប់ស្កាត់ និងហាមឃាត់ជាដាច់ខាតនូវសកម្មភាពល្បែងភ្នាល់គ្រប់ប្រភេទ ដែលគ្មានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ)** | ២០១៥ | | - យន្តការទប់ស្កាត់ និងហាមឃាត់ជាដាច់ខាតនូវសកម្មភាពល្បែងភ្នាល់គ្រប់ប្រភេទ ដែលគ្មានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣ | ពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលតាមរបបម៉ៅការក្នុងពេលរង់ចាំច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ការដាក់ចេញជាវិធានការពង្រឹងប្រសិទ្ធភាព |
| ៤ | ជំរុញការរៀបចំ និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៦ | - វិធានការជំរុញការរៀបចំ និងអនុម័តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ |
| ៥.៣.១៣ | ចំណូលពីការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) | | | |
| ១ | ខិតខំជំរុញការអនុវត្តប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្មឱ្យមានប្រសិទ្ធភាព ដោយត្រូវផ្តល់សេវាសាធារណៈឱ្យបានល្អ និងមានតម្លាភាព ដើម្បីបង្កលក្ខណៈងាយស្រួល និងមានទំនុកចិត្តដល់អ្នកទទួលសេវា, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម)** | ២០១៥ | | - វិធានការនៃការជំរុញការអនុវត្តប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្មឱ្យមានប្រសិទ្ធភាព |
| ២ | ជំរុញការកត់ត្រាបញ្ជីគណនេយ្យស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃការប្រមូលចំណូល ព្រមទាំងអាចវាស់វែង និងវាយតម្លៃពីសមិទ្ធកម្ម, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - វិធានការជំរុញការកត់ត្រាបញ្ជីគណនេយ្យស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃការប្រមូលចំណូល |

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| | | | | ព្រមទាំងអាចវាស់វែង និងវាយតម្លៃពីសមិទ្ធកម្ម |
| ៣ | លើកកម្ពស់ការផ្តល់សេវាដល់ម្ចាស់រោងចក្រ-សហគ្រាស ដើម្បីជួយឱ្យដំណើរការផលិតកម្មបានល្អប្រសើរ និងទទួលបានបរិមាណផលិតផលខ្ពស់។ **(ទទួលបន្ទុកដោយក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម)** | ២០១៥ | | - យន្តការលើកកម្ពស់ការផ្តល់សេវាដល់ម្ចាស់រោងចក្រ-សហគ្រាស ដើម្បីជួយឱ្យដំណើរការផលិតកម្មបានល្អប្រសើរ និងទទួលបានបរិមាណផលិតផលខ្ពស់ |
| ៥.៣.១៤ | ចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ | | | |
| ១ | ពង្រឹងការគោរពតាមបទប្បញ្ញត្តិស្តីពីនីតិវិធីហិរញ្ញវត្ថុនៅក្នុងការផ្តល់កិច្ច-សន្យាវិនិយោគ និងកិច្ចសន្យានានារួមមានទាំងវិធានការដាក់ទោសទណ្ឌចំពោះអង្គភាពដែលមិនគោរពតាមនីតិវិធីជាធរមានផងដែរ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - វិធានការពង្រឹងការគោរពតាមបទប្បញ្ញត្តិស្តីពីនីតិវិធីហិរញ្ញវត្ថុ |
| ២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចាត់មន្ត្រីជំនាញចុះពិនិត្យការអនុវត្តសៀវភៅបន្ទុក និងកិច្ចសន្យា សម្បទានទ្រព្យសម្បត្តិសាធារណៈគ្រប់-ប្រភេទយ៉ាងតិច ២ដង ក្នុង ១ឆ្នាំ ដើម្បីចាត់វិធានការឱ្យបានទាន់ពេល-វេលា, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | រៀងរាល់ឆមាស | | - ការចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យការអនុវត្តសៀវភៅបន្ទុក និងកិច្ចសន្យាសម្បទានទ្រព្យសម្បត្តិសាធារណៈគ្រប់ប្រភេទយ៉ាងតិច ២ដង ក្នុង ១ឆ្នាំ ដើម្បីចាត់វិធានការឱ្យបានទាន់ពេលវេលា |
| ៣ | អាជ្ញាធររាជធានី-ខេត្ត ត្រូវដឹកនាំ និងសហការជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំយន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ត្រួតពិនិត្យជាប្រចាំលើការអនុវត្តសៀវភៅបន្ទុកសម្បទាននានា ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន, **(ទទួលបន្ទុកដោយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - យន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ត្រួតពិនិត្យជាប្រចាំលើការអនុវត្តសៀវភៅបន្ទុកសម្បទាននានា ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន |

| ល.រ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៤ | រៀបចំ និងដាក់ឱ្យអនុវត្តយន្តការព្រមានជាដំណាក់កាល និងដកអាជ្ញាបណ្ណអាជីវកម្ម ឬលុបចោលកិច្ចសន្យាភាសុី ក្នុងករណីមិនគោរពតាមនីតិវិធីហិរញ្ញវត្ថុ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - យន្តការជាដំណាក់កាល និងដកអាជ្ញាបណ្ណអាជីវកម្ម ឬលុបចោលកិច្ចសន្យាភាសុី ក្នុងករណីមិនគោរពតាមនីតិវិធីហិរញ្ញវត្ថុ, |
| ៥ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពង្រឹងការរៀបចំផែនការចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋប្រចាំឆ្នាំនីមួយៗ ដោយសហការជាមួយអាជ្ញាធរខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ការដាក់ចេញនូវវិធានការពង្រឹងការរៀបចំផែនការចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋប្រចាំឆ្នាំនីមួយៗ ដោយសហការជាមួយអាជ្ញាធរខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត។ |

## ឧបសម្ព័ន្ធ ៤: វិធានការសំខាន់ៗក្នុងការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន

| លរ | វិធានការ | រយៈពេលខ្លី | រយៈពេលមធ្យម | សូចនាករ |
|---|---|---|---|---|
| ៦.១ | ការកែលម្អប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ | | | |
| ១ | សិក្សា និងរៀបចំឯកសារគោល (Blueprint) ស្តីពីការកែលម្អប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ៤ ឆ្នាំ | - ឯកសារគោល (Blueprint) ស្តីពីប្រព័ន្ធសារពើពន្ធ និងមិនមែនសារពើពន្ធនឹងត្រូវបានរៀបចំ |
| ៦.២ | ការពង្រឹងយន្តការស្ថាប័ន | | | |
| ១ | ដាក់ឱ្យដំណើរការឡើងវិញនូវការប្រជុំជាប្រចាំរបស់ក្រុមការងារចម្រុះពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ដោយចាត់តាំងថ្នាក់ដឹកនាំជាន់ខ្ពស់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយរូប ដើម្បីដឹកនាំការប្រជុំនេះ និងធានាពង្រឹងការអនុវត្តការងាររបស់ក្រុមការងារនេះ និងធ្វើការត្រួតពិនិត្យ ព្រមទាំងវាយតម្លៃកិច្ចសហការរបស់អគ្គនាយកដ្ឋានទាំងពីរ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | ជាប្រចាំ | - កិច្ចប្រជុំ និងរបាយការណ៍វឌ្ឍនភាពនៃកិច្ចដំណើរការចែករំលែកព័ត៌មានរបស់អគ្គនាយកដ្ឋានទាំងពីរ |
| ២ | កិច្ចសន្យាសម្បទាន, កិច្ចសន្យាលទ្ធកម្ម, កិច្ចសន្យាផ្សេងៗ, កិច្ចព្រមព្រៀង, ទិន្នន័យនៃការចុះបញ្ជីអចលនទ្រព្យ, ទិន្នន័យនៃការចុះបញ្ជីយានយន្ត ឬលិខិតអនុញ្ញាត ព្រមទាំងឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងកាតព្វកិច្ចពន្ធ និងអាករ និងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋទាំងអស់ រវាងអ្នកជាប់ពន្ធជាមួយរាជរដ្ឋាភិបាល ត្រូវតែផ្តល់ជូន | ២០១៥ | | - កិច្ចសន្យាសម្បទាន, កិច្ចសន្យាលទ្ធកម្ម, កិច្ចសន្យាផ្សេងៗ, កិច្ចព្រមព្រៀង, ទិន្នន័យនៃការចុះបញ្ជីអចលនទ្រព្យ, ទិន្នន័យនៃការចុះបញ្ជីយានយន្ត ឬលិខិតអនុញ្ញាតព្រមទាំងឯកសារផ្សេងទៀត ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចពន្ធ និងអាករ និងកាតព្វកិច្ច |

| | | | | |
|---|---|---|---|---|
| | អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | | ហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋទាំងអស់រវាងអ្នកជាប់ពន្ធជាមួយរាជរដ្ឋាភិបាលនឹងត្រូវបានផ្ញើជូនមកអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| ៣ | បង្កើតក្រុមការងារដើម្បីសិក្សាអំពីលក្ខខណ្ឌ, វិសាលភាព និងតម្រូវការព័ត៌មានរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែកព័ត៌មានផ្ទាល់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ក្រុមការងារសិក្សាអំពីលក្ខខណ្ឌ, វិសាលភាព និងតម្រូវការព័ត៌មានរវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែកព័ត៌មានផ្ទាល់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននឹងត្រូវបានបង្កើតឡើង |
| ៤ | បង្កើតនិងដាក់ឱ្យដំណើរការគណៈកម្មាធិការគោលនយោបាយសារពើពន្ធដើម្បីធ្វើការកែសម្រួលរចនាសម្ព័ន្ធពន្ធនាំចេញ-នាំចូល និងមូលដ្ឋានគិតពន្ធដោយមានការគិតគូរច្បាស់លាស់ពីទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមដោយឈរលើគោលការណ៍សមធមិ, យុត្តិធមិសង្គម, ប្រសិទ្ធភាពសេដ្ឋកិច្ច, តម្លាភាព និងគណនេយ្យភាព, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - បង្កើត និងដាក់ឱ្យដំណើរការគណៈកម្មាធិការគោលនយោបាយ និងដោះស្រាយវិវាទសារពើពន្ធនឹងត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការ |
| ៥ | រៀបចំអនុក្រឹត្យស្តីពីគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ ដើម្បីដោះស្រាយវិវាទសារពើពន្ធ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - អនុក្រឹត្យនឹងត្រូវបានរៀបចំ និងអនុវត្ត |
| ៦.៣ | ការកែលម្អគោលនយោបាយ និងក្របខ័ណ្ឌអនុវត្តលើចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមួយចំនួន | | | |

| ៦.៣.១ | អាករពិសេសលើទំនិញ និងសេវាមួយចំនួន | | | |
|---|---|---|---|---|
| ១ | បន្តពង្រឹងការដាក់មន្ត្រីពន្ធដារប្រចាំការនៅតាមរោងចក្រផលិតផលិតផលក្នុងស្រុក ដែលត្រូវជាប់អាករពិសេសដូចជាស្រា, ស្រាបៀរ, បារី, ភេសជ្ជៈគ្រប់ប្រភេទ។ល។, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - មន្ត្រីពន្ធដារនឹងត្រូវបានដាក់ឱ្យប្រចាំការនៅតាមរោងចក្រផលិតផលិតផលក្នុងស្រុក ដែលជាប់អាករពិសេស |
| ២ | រៀបចំប្រកាសស្តីពីការកំណត់ឱ្យបិទតែមប្រើលើទំនិញជាប់អាករពិសេសមួយចំនួនទៀត, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ប្រកាសនឹងត្រូវបានរៀបចំកែប្រែ និងដាក់ឱ្យអនុវត្ត |
| ៣ | ពិនិត្យលទ្ធភាពនៃការដំឡើងអាករពិសេសលើទំនិញអេឡិចត្រូនិច និងផលិតផលប្លាស្ទិកបន្ថែមទៀត, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាពីលទ្ធភាពដំឡើងអាករពិសេសលើទំនិញអេឡិចត្រូនិក |
| ៤ | ពិនិត្យឡើងវិញលើបញ្ជីទំនិញនាំចូល ដែលត្រូវជាប់អាករពិសេស, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២-៤ឆ្នាំ | - អនុក្រឹត្យ និងប្រកាសនឹងត្រូវបានកែប្រែ និងដាក់ឱ្យអនុវត្ត |
| ៥ | ដំឡើងអត្រា និងកែប្រែមូលដ្ឋានគិតអាករពិសេសលើមុខទំនិញប៉ះពាល់សុខភាពមួយចំនួន ដូចជា បារី, ស្រា, ស្រាបៀរ និងភេសជ្ជៈមានជាតិអាល់កុល, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២-៤ឆ្នាំ | - អនុក្រឹត្យ និងប្រកាសនឹងត្រូវបានកែប្រែ និងដាក់ឱ្យអនុវត្ត |
| ៦ | ធ្វើការសិក្សាលើការកែរបៀបយកពន្ធពីការយកពន្ធតាមអត្រា ទៅជាការយកពន្ធតាមឯកតាជាមួយនឹងការបង់អាករពិសេសចាប់ពីកម្រិតអប្បបរមាមួយ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ៣ ឆ្នាំ | - មូលដ្ឋានគិតអាករពិសេសថ្មីត្រូវបានសិក្សា |
| ៧ | រៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអាករពិសេស ឬរដ្ឋាករ។ | | ៣-៤ឆ្នាំ | - សេចក្តីព្រាងច្បាប់ |

| | | | | |
|---|---|---|---|---|
| | (ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) | | | |
| ៦.៣.២ | អាករលើតម្លៃបន្ថែម | | | |
| ១ | រៀបចំកែប្រែអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - អនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែមនឹងត្រូវបានកែប្រែ និងដាក់ឱ្យអនុវត្ត |
| ២ | បញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យ ដែលមិនមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ៣-៤ឆ្នាំ | - ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យ ដែលមិនមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធនឹងត្រូវបានបញ្ឈប់ |
| ៣ | បង្កើតយន្តការបង្វិលសងចំពោះការទិញទំនិញនាំចេញដោយជនបរទេសនៅអាកាសយានដ្ឋានអន្តរជាតិ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ៣-៤ឆ្នាំ | - យន្តការបង្វិលសងនឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ៦.៣.៣ | របបពន្ធម៉ៅការ | | | |
| ១ | រៀបចំបទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ រួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញក្នុងមួយឆមាសម្តង ឬមួយឆ្នាំម្តង ដើម្បីបន្ថយបន្ទុករបស់អ្នកជាប់ពន្ធ និងផ្ទេរមន្ត្រីទៅបម្រើការងារនៅកន្លែង ដែលមានចំណូលខ្ពស់, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - បទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆមាស ឬប្រចាំឆ្នាំនឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| ២ | ធ្វើយុទ្ធនាការផ្ទេរអ្នកជាប់ពន្ធក្នុងរបបម៉ៅការ ដែលមានកម្រិតផលរបរត្រូវជាប់ពន្ធក្នុងរបបស្វ័យប្រកាសឱ្យចូលក្នុងរបបស្វ័យប្រកាស, **(ទទួល** | ២០១៦ | | - យុទ្ធនាការផ្ទេរអ្នកជាប់ពន្ធក្នុងរបបម៉ៅការទៅក្នុងរបបស្វ័យប្រកាសនឹងត្រូវបានអនុវត្តទូទាំងប្រទេស |

| | | | | |
|---|---|---|---|---|
| | **បន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | | |
| ៣ | រៀបចំ និងដាក់ឱ្យអនុវត្តនូវរបបស្វ័យប្រកាសបំពេញ និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញ សម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - បញ្ជីគណនេយ្យលក្ខណៈសាមញ្ញនឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត |
| **៦.៣.៤** | **ពិនិត្យឡើងវិញរបបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគ** | | | |
| ១ | ពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគដោយបញ្ចូលការលើកទឹកចិត្តពន្ធក្នុងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ៣-៤ឆ្នាំ | - ច្បាប់ និងអនុក្រឹត្យនឹងត្រូវបានធ្វើវិសោធនកម្ម |
| **៦.៣.៥** | **កិច្ចព្រមព្រៀងពន្ធអន្តរជាតិ** | | | |
| ១ | ជំរុញក្រុមការងារអន្តរក្រសួង ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកនាំមុខ និងក្រុមការងារកម្រិតបច្ចេកទេស ដើម្បីរៀបចំធ្វើការចរចាជាមួយប្រទេសជាដៃគូ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - ក្រុមការងារអន្តរក្រសួងនឹងត្រូវបានបង្កើត<br>- ក្រុមការងារកម្រិតបច្ចេកទេសនឹងត្រូវបានបង្កើត |
| ២ | ជ្រើសរើសប្រទេសសម្រាប់ធ្វើការចរចាដំបូង និងបន្តបន្ទាប់ទៀត ពិសេសប្រទេសអាស៊ាន និងប្រទេស ដែលមានការវិនិយោគច្រើននៅកម្ពុជា, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - កម្មវិធីចរចាជាមួយប្រទេសជាដៃគូនឹងត្រូវបានរៀបចំ |
| ៣ | រៀបចំបទប្បញ្ញត្តិដែលពាក់ព័ន្ធ ដើម្បីធ្វើវិសោធនកម្មបទប្បញ្ញត្តិនានាដែលខ្វះចន្លោះ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | ២០១៧ | - ប្រកាសមួយចំនួននឹងត្រូវបានរៀបចំ<br>- បទប្បញ្ញត្តិច្បាប់នឹងត្រូវបានអនុម័ត |
| ៤ | បង្កើនចំនួនមន្ត្រី និងបន្តធ្វើការបណ្ដុះបណ្ដាលធនធានមនុស្សសម្រាប់ | ២០១៥ | | - ចំនួនមន្ត្រីនឹងត្រូវបានបង្កើន និងទទួលការបណ្ដុះ |

| | | | | |
|---|---|---|---|---|
| | ដំណើរការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | | បណ្តាល |
| ៥ | បន្តធ្វើការចរចា និងចុះកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាជាមួយបណ្តាប្រទេសក្នុងអាស៊ាន និងប្រទេសដទៃទៀត, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ៣-៤ឆ្នាំ | - បណ្តាប្រទេសក្នុងអាស៊ាននឹងត្រូវបានដំណើរការចរចាចប់សព្វគ្រប់ |
| ៦ | បន្តការងារពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការងារនេះ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ជាប្រចាំ | ជាប្រចាំ | - ចំនួនកម្មវិធីបណ្តុះបណ្តាល |
| **៦.៣.៦** | **ពន្ធលើអចលនទ្រព្យ** | | | |
| ១ | ចុះធ្វើសវនកម្ម និងអនុវត្តតាមច្បាប់ចំពោះម្ចាស់អចលនទ្រព្យដែលបានប្រកាសបង់ពន្ធមិនត្រឹមត្រូវ និងមិនទាន់ដាក់លិខិតប្រកាសបង់ពន្ធលើអចលនទ្រព្យរបស់ខ្លួននៅឡើយ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | រៀងរាល់ឆ្នាំ | - សវនកម្មលើពន្ធអចលនទ្រព្យនឹងត្រូវបានអនុវត្ត |
| ២ | ពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធពិសេសអាជ្ញាធរមូលដ្ឋានក្នុងការប្រមូលពន្ធលើអចលនទ្រព្យ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ធ្វើជាប្រចាំ | | - របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការ |
| ៣ | កែលម្អសេវា និងផ្តល់ការសម្រួលដល់អ្នកជាប់ពន្ធ ពិសេសរៀបចំយន្តការបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមប្រព័ន្ធធនាគារ និងប្រព័ន្ធអេឡិចត្រូនិក, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - យន្តការបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមប្រព័ន្ធធនាគារ និងប្រព័ន្ធអេឡិចត្រូនិកនឹងត្រូវបានដាក់ឱ្យអនុវត្ត |
| ៤ | ពង្រីកវិសាលភាពប្រមូលពន្ធលើអចលនទ្រព្យដល់ទីប្រជុំជនស្រុក, ទីប្រជុំជនសំខាន់ៗ និងតំបន់អភិវឌ្ឍន៍តាមព្រំដែន និងបន្តបន្ទាប់ទូទាំង | | ២-៤ឆ្នាំ | - វិសាលភាពប្រមូលពន្ធនេះនឹងត្រូវបានពង្រីកដល់ទីប្រជុំជនស្រុក ទីប្រជុំជនសំខាន់ៗ និងតំបន់អភិវឌ្ឍន៍ |

| | | | | |
|---|---|---|---|---|
| | ប្រទេស, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | | តាមព្រំដែន |
| ៥ | កែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រមូលពន្ធលើអចលនទ្រព្យ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២ ឆ្នាំ | - ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យនឹងត្រូវបានកែសម្រួល និងដាក់ឱ្យអនុវត្ត |
| **៦.៣.៧** | **ពន្ធលើចំណូលរូបវន្តបុគ្គល** | | | |
| ១ | សិក្សាអំពីការរៀបចំបទប្បញ្ញត្តិ និងយន្តការគាំទ្រទាំងឡាយ សម្រាប់ត្រៀមឱ្យអនុវត្តពន្ធលើចំណូលរូបវន្តបុគ្គល ដែលមានលក្ខណៈពេញលេញ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ៣ ឆ្នាំ | - របាយការណ៍លទ្ធផលស្តីពីការសិក្សានឹងត្រូវបានបញ្ចប់ |
| **៦.៣.៨** | **ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ** | | | |
| ១ | ជំរុញការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៥ | | - សេចក្តីព្រាងច្បាប់ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធនធានរ៉ែនឹងត្រូវបានដាក់ចូលប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី |
| ២ | រៀបចំលិខិតបទដ្ឋានគតិយុត្តអនុវត្តពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | ២០១៦ | | - លិខិតបទដ្ឋានគតិយុត្តអនុវត្តន៍ពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធនធានរ៉ែនឹងត្រូវបានរៀបចំបញ្ចប់ត្រឹមកម្រិតអគ្គនាយកដ្ឋានពន្ធដារ |
| **៦.៣.៩** | **ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ** | | | |
| ១ | ធ្វើការសិក្សា និងពិនិត្យឡើងវិញអំពីប្រព័ន្ធពន្ធដារ និងបទប្បញ្ញត្តិស្តីពីពន្ធដារនូវចំណុចខ្វះចន្លោះ និងភាពមិនច្បាស់លាស់ ហើយរៀបចំធ្វើវិសោធនកម្មបទប្បញ្ញត្តិពាក់ព័ន្ធតាមការចាំបាច់។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២-៤ឆ្នាំ | - សេចក្តីព្រាងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារនឹងត្រូវបានអនុម័ត ដូចជា÷<br>• សហគ្រាសធានារ៉ាប់រងលើអាយុជីវិត,<br>• កែប្រែពន្ធប៉ាតង់,<br>• កែប្រែពន្ធសត្តឃាត, |

| | | | | |
|---|---|---|---|---|
| | | | | • កែប្រែពន្ធតែមប្រិ៍សារពើពន្ធ,<br>• កែប្រែពន្ធលើដីធ្លីមិនបានប្រើប្រាស់,<br>• រៀបចំប្រកាសស្តីពីពន្ធចំណេញលើមូលធន<br>• រៀបចំប្រកាសស្តីពីការកំណត់និយមន័យពាក្យ បច្ចេកទេស ដែលនៅខ្វះចន្លោះ ដូចជា ផលរបរ, សួយសារ,សេវាគ្រប់គ្រង, សេវា បច្ចេកទេស និងសេវាពិគ្រោះយោបល់,<br>• រៀបចំប្រកាសស្តីពីភតិសន្យាហិរញ្ញវត្ថុ,<br>• រៀបចំប្រកាសស្តីពីការកំណត់សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ។ល។ |
| **៦.៣.១០** | **ការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី** | | | |
| ១ | វាយតម្លៃរៀងរាល់ត្រីមាសលើការបាត់បង់ចំណូលពន្ធអាករគយពីការ-អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត និងស្នើឡើងនូវវិធានការសមស្រប។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | រៀងរាល់ត្រីមាស | | - របាយការណ៍វាយតម្លៃចំណូល ដែលបាត់បង់នឹងត្រូវបានធ្វើឡើងជារៀងរាល់ខែ |
| **៦.៣.១១** | **ការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** | | | |
| ១ | រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៦ | - ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| ២ | រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, | | ២០១៦ | - ច្បាប់ស្តីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |

| | | | | |
|---|---|---|---|---|
| | **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | | |
| ៣ | ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវធ្វើការស្រាវជ្រាវ និងលើកសំណើរៀបចំ និងធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានគ្រប់ប្រភេទរបស់រដ្ឋ រួមមានជាអាទិ៍ ច្បាប់ស្តីពីរ៉ែ, ច្បាប់ស្តីពីប្រេងកាត និងច្បាប់ស្តីពីសម្បទានជាដើម ដោយធានាឱ្យមានសង្គតិភាព និងការបំពេញឱ្យគ្នាជាមួយនឹងច្បាប់ស្តីពីសារពើពន្ធ, ច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ **(ទទួលបន្ទុកដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)** | | ២០១៦ | - សំណើវិសោធនកម្មច្បាប់, កែប្រែបទប្បញ្ញត្តិ ឬកិច្ចសន្យាណាមួយដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរដ្ឋនឹងត្រូវបានរៀបចំឡើង |